# គតិធម៌

សុ.



ទី. អ.

ធម្មទានឈ្នះអស់ទានទាំងពួង

រៀបរៀងដោយ

ខ្ញុំព្រះករុណា

ខ្ញុំបាទ **ប៊ុត សាវង្ស**

សម្រាប់ចែកជាធម្មទាន

# ពាក្យផ្ដើម

សៀវភៅ **គតិធម៌** នេះ អធិប្បាយអំពីដំណើរធម៌ ២ ផ្នែក គឺ

**១- ដំណើរធម៌ពិតជីវិតសត្វលោក** បានរៀបរាប់អំពីរឿងរ៉ាវនៅក្នុងព្រះជាតកខ្លីៗ ដើម្បីអប់រំគំនិតទៅតាមដំណើរធម៌ដែលជាធម្មជាតិ ។ មានរឿងខ្លះផ្ដល់នូវការសិក្សា តាមចរិយាប្រព្រឹត្តរបស់សត្វ មានស្វា អណ្ដើក និង សត្វលាជាដើម ដែលការសិក្សានេះបានជាគតិនៃលោកុត្តរធម៌ទៀតផង ។ មានរឿងខ្លះទៀត បង្ហាញនូវដំណើរធម៌ដែលជាឧបនិស្ស័យធ្លាប់សន្សំមក ជាបរមត្ថ-ធម៌សុទ្ធៗ ដែលមិនគួរប្រកាន់ទៅលើបុគ្គលណាឡើយ ដូចជារឿងក្នុង **ចូឡបរិយាយជាតក** ជាដើម ។

គតិធម៌ គឺជាដំណើរធម៌ពិតៗ សិក្សារឿងរ៉ាវក្នុងព្រះជាតកហើយ អាចពិចារណាឃើញទៅតាមគោលនៃ

អរិយសច្ចធម៌ទាំង ៤ យ៉ាងបាន ដូចជាភិក្ខុដែលបានស្ដាប់នូវ **តរហិតជាតក** ហើយស្ដាប់សច្ចធម៌សម្រេចមគ្គផលដូច្នោះឯង ។

គតិធម៌ម្យ៉ាងទៀត គឺជាដំណើរនៃប្រាជ្ញាញាណគតិបណ្ឌិត និង ដំណើរនៃការយល់ដឹងហេតុផលជាដើមរបស់ព្រះបរមពោធិសត្វគ្រប់ព្រះជាតកទាំងអស់ ។

**២- ដំណើរធម៌សប្បុរសដោះស្រាយបញ្ហា** បានរៀបរាប់អំពីបញ្ហាមួយចំនួន ដែលត្រូវដោះស្រាយតាមប្រាជ្ញាញាណនៃអ្នកប្រាជ្ញ។ ជីវិតមនុស្សយើងមិនអាចអត់មានបញ្ហាឯង១ទៅនោះទេ ដូច្នេះកាលបើមានបញ្ហាអ្វីមួយមកដល់ កុំចេះតែចង់មិនឱ្យមាននូវបញ្ហានោះតែត្រូវដោះស្រាយដោយគតិធម៌របស់បណ្ឌិត គឺប្រាជ្ញាញាណនៃអ្នកប្រាជ្ញ ដោយបញ្ហាប្រៀបដូចជាសំណួរ រីឯគតិធម៌របស់បណ្ឌិត ប្រៀបដូចជាការឆ្លើយតបសំណួរ ។

ជីវិតជោគជ័យ មិនមែនព្រោះតែជីវិតអត់បញ្ហា

នោះទេ តាមពិត បញ្ហាជាឧបសគ្គផ្សេងៗ បានជាប់មកជាមួយនឹងជីវិតហើយស្រេច ដូច្នេះគតិធម៌របស់បណ្ឌិតពិតជាចាំបាច់បំផុតសម្រាប់ជីវិតជោគជ័យ ។

ជីវិតមនុស្សមានតម្លៃក្នុងភាពជាមនុស្ស ព្រោះជាកុសលវិបាកបដិសន្ធិ និង ព្រោះជាបុញ្ញកម្មជ្ឈរូប នេះគឺជាជោគជ័យដ៏ធំមួយរួចហើយស្រេច ព្រោះបានឈ្នះនូវបាបកម្មផ្សេងៗដ៏ច្រើន ហើយបុណ្យបាននាំជីវិត ឱ្យមកកើតជាមនុស្ស ។ មិនត្រឹមតែប៉ុណ្ណោះ ជីវិតនៅរស់ដល់សព្វថ្ងៃ សុទ្ធតែជាជីវិតជោគជ័យ ព្រោះបុណ្យជាបច្ច័យក្នុងការរក្សាជីវិត ដោយបានរារាំងនូវសេនារបស់មច្ចុរាជ ។ ព្រោះហេតុដូច្នេះ មនុស្ស ត្រូវតែតស៊ូយកជោគជ័យជាទីបំផុត គឺកម្ចាត់បង់កិលេសអំពីសន្តាន ធ្វើជីវិតឱ្យមានតម្លៃជាភិយ្យោភាព ជាមួយនឹងការងារជាប្រយោជន៍បន្តទៀត ព្រោះថាជីវិតមានតម្លៃ និង ជីវិតទទួលជោគជ័យជាទីបំផុតបាន មិនមែនឯងៗទៅនោះទេ

ត្រូវមានសម្មាទិដ្ឋិឈរខាងបុណ្យកុសល រាប់ទទួលគុណ គឺសេចក្ដីល្អគ្រប់យ៉ាង និង ព្យាយាមអប់រំបញ្ញា ។

សៀវភៅ **គតិធម៌** នេះ គាំទ្រឱ្យជីវិតបានសម្រេចជោគជ័យដល់ទីបំផុត ។

គតិធម៌សមអប់រំគំនិត ដំណើរធម៌ពិតជីវិតធម្មតា
ធម្មជាតិព្រៃព្រឹក្សដួងព្រះសុរិយា ផ្ដល់ការសិក្សាសង្ខារឃ្លាឃ្លាត ។
គតិធម៌សមអប់រំបញ្ញា ដោះស្រាយបញ្ហាសិក្សាធម្មជាតិ
សិក្សាចងចាំខន្ធប្រាំអាពាធ មុខតែនឹងឃ្លាតរៀនឃ្លាតឱ្យហើយ ។

**សូមអនុមោទនាធម្មយាត្រាទៅកាន់ដែនពុទ្ធភូមិ !**

ភ្នំពេញថ្ងៃ ១៥ កើត ខែផល្គុន ព.ស. ២៥៥៥

**ខ្ញុំព្រះករុណា ខ្ញុំបាទ ប៊ុត សាវង្ស**

# មាតិកា

ឈ្មោះអត្ថបទ ទំព័រ


១. កឡាយមុដ្ឋិជាតក .............................. ១

២. កច្ឆបជាតក .................................... ៦

៣. សីហចម្មជាតក ............................... ១២

៤. សីលានិសំសជាតក ........................... ១៨

៥. មិត្តាមិត្តជាតក ................................ ២៨

៦. រាធជាតក ..................................... ៣៤

៧. សាធុសីលជាតក ............................. ៤០

៨. គរហិតជាតក ................................. ៤៥

៩. បលាយិជាតក ................................ ៥៦

១០. អសិតាភុជាតក .............................. ៦៧

១១. មូលបរិយាយជាតក .......................... ៨០

. គោតមកសូត្រ ............................... ៨៨

១២. មេត្តាត្រាប្រណី ............................ ៩៣
១៣. ដំណោះស្រាយបញ្ហា ........................ ៩៥
១៤. បញ្ហាខកចិត្ត ................................ ៩៨
១៥. បញ្ហាបែកបាក់គ្នា .......................... ១០២
១៦. បញ្ហាចង់ឱ្យគេទទួលស្គាល់ ................. ១០៨
១៧. បញ្ហាមិនស្មោះត្រង់ ....................... ១១២
១៨. បញ្ហាហួងហែងហួស ...................... ១១៥
១៩. បញ្ហាលោភៈ ................................ ១១៨
២០. បញ្ហាទោសៈ ............................... ១២៤
២១. បញ្ហាច្រណែន ............................ ១៣០
២២. បញ្ហាកំណាញ់ ............................ ១៣៣
២៣. បញ្ហាស្ដាយក្រោយ ....................... ១៣៦

# ១. កន្ឡាយមុដ្ឋិជាតក

(បិដកលេខ ៥៨, ទំព័រ ៨៤)

អមាត្យពោធិសត្វ ក្រាបទូលថា :

បពិត្រព្រះអង្គជាធំជាងជន ស្វានេះល្ងង់ ប្រាជ្ញារបស់វាមិនមានទេ វាបានបាចសណ្ដែកមួយកម្សង់ចោលអស់ ទើបទៅស្វែងរកសណ្ដែកមួយគ្រាប់ដែលជ្រុះទៅ ។

បពិត្រព្រះរាជា យើងទាំងឡាយក្ដី ជនទាំងឡាយដទៃដែលល្មោភក្រៃលែងក្ដី រមែងលះបង់របស់ច្រើន ព្រោះតែរបស់តិច ដូចជាស្វា បានលះបង់សណ្ដែកច្រើន ព្រោះតែសណ្ដែកតិច ដូច្នោះឯង ។

ព្រះអានន្ទត្ថេរក្នុងកាលនោះ ជាព្រះរាជាក្រុងពារាណសី ស្ដេចយាងដាក់ដំណាក់នៅក្នុងព្រះឧទ្យាន ចំណែកព្រះពោធិសត្វជាអមាត្យ ជាអ្នកសម្រេចរាជកិច្ចទូទៅ និង ជាធម្មានុសាសកៈ បានឋិតនៅជិតទីប្រថាប់

ព្រះរាជា ។ គ្រានោះ មានស្វាមួយ ចុះពីលើដើមឈើ ឆក់យកសណ្តែកជាចំណីនៃសេះ ដោយដាក់ពេញក្នុងមាត់ ហើយក្តាប់យកនឹងដៃទៅទៀតផង វាលោតឡើងទៅអង្គុយលើដើមឈើ ប្រុងនឹងស៊ី ស្រាប់តែមានសណ្តែកមួយគ្រាប់ជ្រុះពីដៃមកដី ពេលនោះ ស្វាបានចោលគ្រាប់សណ្តែកទាំងអស់ក្នុងមាត់និងក្នុងដៃ ចុះពីលើដើមឈើ មករកមើលសណ្តែកមួយគ្រាប់ កាលដែលរកមិនឃើញ ទើបវាត្រឡប់ឡើងទៅលើដើមឈើវិញ អង្គុយសោកសៅ ខូចចិត្ត ដូចជាអ្នកចាញ់ក្តីគេ ដូច្នោះឯង ។

## លះសុខតូចដូរយកសុខធំ

ក្នុងធម្មបទដ្ឋកថា បកិណ្ណកវគ្គ ក្នុងរឿងបុព្វកម្មរបស់ព្រះអង្គ ព្រះបរមសាស្តាទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលនោះ តថាគតជាសង្ខព្រាហ្មណ៍ តថាគតបានដកស្មៅក្នុងលានព្រះចេតិយនៃព្រះបច្ចេកពុទ្ធព្រះនាមសុសិមៈ ដោយផលនៃបុញ្ញកម្មនោះ ជនទាំង-

ឡាយទើបធ្វើផ្លូវ ៨ យោជន៍ឱ្យរាបស្មើដោយល្អ ប្រាស-ចាកបន្ទានិងដង្គត់ ។ តថាគតចាក់ខ្សាច់កៀរឱ្យស្មើក្នុងលានព្រះចេតិយនោះ ដោយផលនៃបុញ្ញកម្មនោះ ជនទាំងឡាយទើបចាក់ខ្សាច់កៀរឱ្យស្មើក្នុងផ្លូវ ៨ យោជន៍ ។ តថាគត ធ្វើការបូជាដោយផ្កាឈើព្រៃចំពោះព្រះចេតិយនោះ ដោយផលនៃបុញ្ញកម្មនោះ ជនទាំងឡាយទើបរោយផ្កាឈើមានពណ៌ផ្សេងៗ នៅតាមផ្លូវចម្ងាយ ៨ យោជន៍ ទន្លេគង្គាក្នុងទីប្រមាណមួយយោជន៍ដេរដាសទៅដោយផ្កាបទុម ៥ ពណ៌ ។ តថាគតបានប្រោះព្រំក្នុងទីលានព្រះចេតិយនោះ ដោយទឹកក្នុងល័ក្កចាន់ ដោយផលនៃបុញ្ញកម្មនោះ ភ្លៀងបោក្ខរព័សីធ្លាក់ចុះនៅក្រុងវេសាលី ។ តថាគតបានលើកទង់ផ្ទាំងសំពត់ឡើង និងចងឆត្រទុកលើព្រះចេតិយនោះ ដោយផលនៃបុញ្ញកម្មនោះ ចក្កវាឡទាំងមូលទើបហាក់ដូចជាមានមហោស្រពជាមួយគ្នា ដោយទង់ជ័យ ទង់ផ្ទាំងសំពត់ និង ឆត្ររួតរហូតដល់អកនិដ្ឋព្រហ្ម ។ ម្នាលភិក្ខុទាំងឡាយ ព្រោះ

ហេតុដូច្នោះឯង ទើបការបូជានេះកើតឡើងដល់តថាគត មិនមែនដោយពុទ្ធានុភាព ឬដោយអានុភាពនៃពួកនាគ ទេវតា ឥន្ទព្រហ្មនោះក៏មិនមែនដែរ តែនេះ កើតឡើង ដោយអានុភាពនៃការបរិច្ចាគមានប្រមាណតិច នៅក្នុង អតីតកាល ។ រួចហើយព្រះដ៏មានព្រះភាគទ្រង់ត្រាស់នូវ ព្រះគាថា

**មត្តាសុខបរិច្ចាគា ปสฺเส เจ วิปุลํ สุขํ**
**จเช มตฺตาสุขํ ธีโร สมฺปสฺสํ วิปุลํ สุขํ ។**

បើឃើញសេចក្តីសុខដ៏ធំទូលាយ ព្រោះលះបង់ សុខល្មមប្រមាណ អ្នកមានប្រាជ្ញា កាលឃើញសុខធំ ទូលាយ គប្បីលះសុខល្មមប្រមាណចេញ ។

**អដ្ឋកថា** បណ្តាបទទាំងនោះ បទថា **មត្តាសុខ-បរិច្ចាគា** ដោយសេចក្តីថា ព្រោះលះសុខតិចតួចល្មម ប្រមាណ ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា **មត្តា-សុខំ** ។ សុខដ៏ធំទូលាយ បានដល់សុខគឺព្រះនិព្វាន

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា **ទិបុលំ សុខំ** ដោយសេចក្តីថា បើបុគ្គលបានឃើញនូវសេចក្តីសុខដ៏ធំទូលាយនោះ ។

ដែលឈ្មោះថា សុខល្មមប្រមាណ រមែងកើតឡើងដល់បុគ្គល គឺអ្នកដែលចាត់ចែងឱ្យគេរៀបចំភោជនមួយថាស ហើយបរិភោគ ។ ចំណែកដែលឈ្មោះថា និព្វានសុខ ជាសុខដ៏ធំទូលាយ រមែងកើតឡើងដល់បុគ្គលដែលជាអ្នកលះសុខល្មមប្រមាណនោះចេញហើយ ធ្វើឧបោសថផង ឱ្យទានផង ។ ព្រោះហេតុនោះ បើបុគ្គលឃើញសុខដ៏ធំទូលាយ ព្រោះមកអំពីលះបង់នូវសុខល្មមប្រមាណនោះ កាលបើដូច្នោះ បណ្ឌិតកាលឃើញសុខដ៏ធំទូលាយ គប្បីលះសុខល្មមប្រមាណចេញ ។

# ២. កច្ឆបជាតក

(បិដកលេខ ៥៨, ទំព័រ ៨៥)

អណ្តើកនិយាយថា :

ខ្ញុំនៅក្នុងភក់ដោយគិតថា ខ្ញុំកើតហើយ ខ្ញុំចម្រើនហើយនៅក្នុងទីនេះ ភក់បានកប់សង្កត់ធ្វើឱ្យខ្ញុំដល់នូវទុព្វលភាព បពិត្រភគ្គវៈ ខ្ញុំសូមពោលនូវហេតុនោះនឹងអ្នក អ្នកចូរស្តាប់នូវពាក្យរបស់ខ្ញុំចុះ ។

បុគ្គលបានសេចក្តីសុខក្នុងទីណា ទោះក្នុងស្រុក ឬក្នុងព្រៃក៏ដោយ ទីនោះហើយដែលជាទីកើត ជាទីចម្រើនរបស់បុរសអ្នកចេះដឹង (នូវប្រយោជន៍និងមិនមែនប្រយោជន៍) បុគ្គលគប្បីរស់នៅបានក្នុងទីណា គប្បីទៅក្នុងទីនោះចុះ កុំគប្បីឱ្យទីដែលធ្លាប់នៅ សម្លាប់ខ្លួនបានឡើយ ។

ក្នុងកាលនោះ ព្រះអានន្ទត្ថេរជាសត្វអណ្តើក នៅ

នឹងស្រះធំមួយជិតក្រុងពារាណសី ។ ស្រះធំនោះមាន ទឹកទន្លេហូរចូល និងហូរចេញតាមពេលដែលទឹកឡើង ទឹកស្រក ។ ក្រោយមក ត្រីនិងអណ្ដើកដែលកើតនៅនឹង ស្រះធំនោះបានដឹងថា តទៅនឹងត្រូវរាំងភ្លៀង ក៏នាំគ្នា ចេញអំពីស្រះ តាមទឹកដែលនៅមានចូលមកក្នុងទន្លេ ។ ប៉ុន្តែអណ្ដើកជាព្រះអានន្ទក្នុងកាលនោះ មិនព្រមចេញ ទៅ ដោយគិតថា នេះជាទីកើតរបស់យើងនិងជាទីធំ ឡើងនៃរូបកាយរបស់យើង ទាំងជាទីដែលឪពុកម្ដាយ របស់យើងធ្លាប់អាស្រ័យនៅ ដូច្នេះយើងមិនអាចលះបង់ នូវទីនេះបានឡើយ ។ ក្រោយមក ទឹកទន្លេក៏ស្រកដាច់ ពីទឹកស្រះ ភ្លៀងក៏រាំងរហូតដល់ទឹកស្រះរីងអស់ អណ្ដើក នោះឯង បានចេញមកកាយដីកប់ខ្លួន ត្រង់ទីដែល ព្រះពោធិសត្វជីកយកដីត្រង់នោះមកធ្វើឆ្នាំង ជាមុខរបរ ចិញ្ចឹមបុត្រភរិយា ។ កាលដែលព្រះពោធិសត្វ មាន បំណងនឹងយកដី ទើបយកចបធំជីកដី ក៏ត្រូវចំអណ្ដើក កាលដែលគាស់អណ្ដើកឡើងមក ឃើញអណ្ដើកត្រូវ

របួសជាទម្ងន់ ដល់នូវទុក្ខវេទនា ទាំងដែលពោលរៀបរាប់ថា ព្រោះយើងមិនបានលះទីដែលធ្លាប់នៅ ទើបដល់នូវសេចក្ដីវិនាសយ៉ាងនេះ ហើយបានពោលនូវគាថាដែលមានសេចក្ដីខាងដើមស្រាប់ ។

បទថា **ន និកេតហតោ សិយា** ប្រែថា កុំគប្បីឱ្យទីដែលធ្លាប់នៅ សម្លាប់ខ្លួនបានឡើយ ។ ដោយសេចក្ដីថា មានការអាឡោះអាល័យចំពោះកន្លែងដែលធ្លាប់នៅហើយ មិនទៅក្នុងទីដទៃ ត្រូវទីនោះឯងសម្លាប់ ដូច្នេះទើបមិនគួរឱ្យមានមរណទុក្ខបែបនេះឡើយ ។

ក្នុងកាលនោះ អណ្ដើកដែលជាព្រះអានន្ទត្ថេរពោលចំពោះព្រះពោធិសត្វរួចហើយ ក៏ស្លាប់ទៅ ។ ព្រះពោធិសត្វ បានលើកយកអណ្ដើកនោះទៅ ឱ្យអ្នកស្រុកអ្នកភូមិទាំងអស់មកប្រជុំគ្នា ។ កាលដែលនឹងត្រូវណែនាំអប់រំមនុស្សទាំងឡាយ ទើបពោលយ៉ាងនេះថាពួកអ្នកទាំងឡាយ ចូរមើលអណ្ដើកនេះ ក្នុងពេលដែលត្រីនិងអណ្ដើកដទៃទៀតចុះទៅកាន់ទន្លេ អណ្ដើកនេះ

មិនអាចកាត់នូវសេចក្ដីអាល័យក្នុងលំនៅរបស់ខ្លួនបាន គឺគេមិនអាចទៅបានជាមួយនឹងសត្វដទៃទៀតឡើយ គេនៅដេកក្នុងទីដែលយើងត្រូវជីកយកដី នៅពេលដែលយើងជីកដី បានជីកត្រូវមួយចបយ៉ាងខ្លាំងពីលើខ្នង មុននឹងស្លាប់ គេបានពោលរៀបរាប់នូវកម្មរបស់ខ្លួនពីរគាថាទាំងសោកសៅ អណ្ដើកនេះស្លាប់ទៅព្រោះធ្វើនូវសេចក្ដីអាល័យចំពោះទីដែលខ្លួនធ្លាប់នៅ ។ អ្នកទាំងឡាយកុំដូចជាសត្វអណ្ដើកនេះឡើយ គឺចាប់តាំងអំពីពេលនេះទៅ អ្នកទាំងឡាយមិនត្រូវប្រកាន់ដោយអំណាចតណ្ហាប្រព្រឹត្តទៅក្នុងគ្រឿងឧបភោគបរិភោគថា រូប សំឡេង ក្លិន រស ផោដ្ឋព្វៈជារបស់យើង បុត្ររបស់យើង ធីតារបស់យើង ទាសាទាសីរបស់យើង មាសប្រាក់របស់យើងដូច្នេះឡើយ ។ តាមពិត ដំណើរជីវិតសត្វតែឯងប៉ុណ្ណោះត្រូវត្រាច់រង្គាត់វិលវល់ក្នុងភពទាំងបី ។ ព្រះពោធិសត្វបានប្រទានឱវាទដល់មហាជនដោយព្រះពុទ្ធលីលា មានប្រការដូច្នេះឯង ឱវាទនោះ ផ្សាយទៅពេញជម្ពូទ្វីប តាំង

នៅរហូតប្រមាណ ៧ ពាន់ឆ្នាំ ។ មហាជន តាំងនៅក្នុងឱវាទរបស់ព្រះបរមពោធិសត្វ ធ្វើបុណ្យមានទានជាដើម គឺនាំគ្នាធ្វើផ្លូវទៅទេវលោកឱ្យពេញបរិបូណ៌ ។

## ស្លាប់ទាំងរស់ ស្អុយទាំងស្រស់

បាទនៃព្រះគាថាធម្មបទ ក្នុងអប្បមាទវគ្គ ព្រះដ៏-មានព្រះភាគទ្រង់ត្រាស់ថា **យេ បមត្តា យថា មតា** ដោយសេចក្ដីថា ពួកសត្វណាដែលប្រមាទហើយ ពួកសត្វនោះ រមែងដូចជាបុគ្គលដែលស្លាប់ ព្រោះដាច់នូវជីវិតិន្ទ្រិយ មានវិញ្ញាណប្រាសទៅហើយ ដូចជាអង្កត់អុសដូច្នោះឯង ។ ពិតណាស់ សូម្បីចិត្តមួយដួងដែលគិតថា យើងនឹងថ្វាយទាន យើងនឹងរក្សាសីល យើងនឹងធ្វើឧបោសថកម្ម ដូច្នេះ រមែងមិនកើតឡើងឡើយ នេះចំពោះគ្រហស្ថ បើជាបព្វជិតវិញ សូម្បីចិត្តមួយដួងដែលគិតថា យើងនឹងបំពេញវត្តទាំងឡាយ មានអាចរិយវត្តនិងឧបជ្ឈាយវត្តជាដើម ឬយើងនឹងសមាទាននូវធុតង្គ

យើងនឹងចម្រើនភាវនា ដូច្នេះ រមែងមិនកើតឡើងដល់បព្វជិតនោះឡើយ គឺដូចចិត្តមួយដួងក៏មិនកើតដល់សត្វស្លាប់ហើយ ដូច្នោះឯង ។ បុគ្គលដែលប្រមាទហើយនោះ តើមានអ្វីដែលធ្វើឱ្យផ្សេងគ្នា ខុសអំពីបុគ្គលដែលស្លាប់បាត់បង់ជីវិតទៅនោះ ព្រោះដូច្នោះ បុគ្គលប្រមាទរមែងមិនខុសពីអ្នកស្លាប់ទៅហើយនោះទេ ។

## គំនិតយល់ដឹង

ស្លាប់ទាំងរស់ ព្រោះមិនធ្វើកិច្ចដែលត្រូវធ្វើ ។

ស្អុយទាំងស្រស់ ព្រោះធ្វើកិច្ចដែលមិនត្រូវធ្វើ ។

មនុស្សស្លាប់ដាច់ជីវិតិន្ទ្រិយ វិញ្ញាណទាំងអស់ត្រូវរលត់ ប៉ុន្តែ មនុស្សស្លាប់សតិ ជាបុគ្គលប្រមាទហើយ គឺស្លាប់តែកុសលចិត្ត រលត់តែវិញ្ញាណល្អៗប៉ុណ្ណោះឯង ចំណែកវិញ្ញាណអាក្រក់ទាំងឡាយនៅរស់ ទើបឈ្មោះថា មនុស្សខ្មោចគួរឱ្យខ្លាច ។

# ៣. សីហចម្មជាតក

( បិដកលេខ ៥៨, ទំព័រ ៩២ )

អ្នកស្រែពោធិសត្វ ពោលថា នោះមិនមែនសម្រែកសីហៈ មិនមែនសម្រែកខ្លាធំ មិនមែនសម្រែកខ្លាដំបងទេ គឺជាសត្វលាដ៏លាមកគ្របដណ្ដប់ដោយស្បែកសីហៈ ស្រែកទេតើ ។

ពាណិជម្ចាស់លា ពោលថា លាដណ្ដប់ដោយស្បែកសីហៈ ស៊ីស្រូវសន្ទូងនោះ អស់កាលជាយូរណាស់ហើយ ទាល់តែស្រែកឱ្យគេដឹងទើបបានជាប្រទូស្តជាមួយនឹងខ្លួនឯង ។

កាលនោះ គោកាលិកភិក្ខុ លោកកើតជាសត្វលាដែលម្ចាស់ជាអ្នកជំនួញ តែងតែដាក់ទំនិញលើខ្នង ។ ឈ្មួញនោះ កាលដែលទៅដល់កន្លែងហើយ ដាក់អីវ៉ាន់ចុះពីខ្នងលា រួចយកស្បែកសីហៈគ្របដណ្ដប់ឱ្យលា លែង

ឱ្យទៅរកស៊ី ។ លាបានទៅស៊ីស្រូវសន្ទូងរបស់អ្នកស្រុក។ អ្នករក្សាស្រែឃើញហើយ មិនហ៊ានចូលទៅជិត ដោយយល់ថាជាសីហៈ (មានពួកសីហៈខ្លះ បរិភោគស្មៅជាអាហារ ហៅថា តិណសីហៈ )។ លាស៊ីស្រូវអ្នកស្រុករឿយ១ ថ្ងៃមួយ ពួកអ្នកភូមិទាំងអស់ ខ្លះកាន់អាវុធ ខ្លះផ្លុំស័ង្ខ ខ្លះទូងស្គរ ស្រែកហ៊ោទាំងអស់គ្នា ចូលទៅជិតសត្វលាកំពុងស៊ីស្រូវក្នុងស្រែ ។ លាខ្លាចស្លាប់ទើបបន្លឺសំឡេងរបស់ខ្លួន ។ ក្នុងកាលនោះ ព្រះពោធិសត្វជាអ្នកស្រែ បានពោលគាថាប្រាប់ថាជាសត្វលា ដែលមានសេចក្តីខាងដើមស្រាប់ ។ សូម្បីពួកអ្នកស្រុក ក៏ដឹងថាជាសត្វលា ទើបនាំគ្នាចូលទៅវាយឱ្យទាល់តែដួល បែកក្បាលបាក់ឆ្អឹង ហើយនាំគ្នាយកស្បែកសីហៈនោះទៅ ។

កាលដែលនាយឈ្នួញជាម្ចាស់លានោះ មកឃើញលាដល់នូវសភាពបែបនេះ ទើបពោលគាថាទី ២ មានសេចក្តីដូចខាងដើម ។

បទថា **ចិរម្បិ ខោ** ដោយសេចក្តីថា

កាលដែលស្រែកដោយសំឡេងជាសត្វលា ក៏ប្រទូសរ៉ាយនឹងខ្លួនឯង ។ នេះមិនមែនជាកំហុសរបស់ស្បែកសីហៈឡើយ ។

កាលដែលនាយឈ្មួញ ពោលយ៉ាងនេះហើយ លាក៏ដេកស្លាប់ក្នុងទីនោះទៅ ។

## រស់នៅជាមួយនឹងខ្លួនឯងពិត ហើយរក្សាខ្លួនឯង

នៅក្នុងព្រះគាថាធម្មបទ អត្តវគ្គ ព្រះអង្គទ្រង់ត្រាស់ថា **អត្តានញ្ចេ បិយំ ជញ្ញា** បើបុគ្គលដឹងថា ខ្លួនជាទីស្រឡាញ់នៃខ្លួនឯង **រក្ខេយ្យ នំ សុរក្ខិតំ** គប្បីរក្សាខ្លួនឱ្យជាការរក្សាដ៏ល្អ ។

ធម្មបទ ភិក្ខុវគ្គ ព្រះអង្គត្រាស់ថា

**អត្តនា ចោទយត្តានំ បដិមំសេតមត្តនា**
**សោ អត្តគុត្តោ សតិមា សុខំ ភិក្ខុ វិហាហិសិ ។**

អ្នកចូរដាស់តឿនខ្លួនដោយខ្លួនឯង ចូរពិនិត្យខ្លួនដោយខ្លួនឯង ម្នាលភិក្ខុ កាលដែលអ្នកជាបុគ្គលមាន

ស្មារតី គ្រប់គ្រងខ្លួនបានហើយ នឹងនៅជាសុខ ។

**អត្តា ហិ អត្តនោ នាថោ  អត្តា ហិ អត្តនោ គតិ**
**តស្មា សញ្ញម អត្តានំ  អស្សំ ភទ្រំវ វាណិជោ។**

មែនពិត ខ្លួនជាទីពឹងរបស់ខ្លួន ខ្លួនជាគតិរបស់ខ្លួន ព្រោះហេតុនោះ អ្នកចូរសង្រួម គឺប្រយ័ត្នប្រយែងខ្លួន ដូចជានាយពាណិជថែរក្សាសេះ ដែលជាសេះដ៏ចម្រើន ដូច្នោះឯង ។

## គំនិតយល់ដឹង

នៅក្នុងពិភពលោកនេះ មានមនុស្សរាប់ពាន់លាននាក់ ទាំងទេវតាឥន្ទព្រហ្មក៏ច្រើន ប៉ុន្តែមានតែយើងម្នាក់គត់ ដែលជាខ្លួនយើង ។ បើយើងប្រព្រឹត្តអាក្រក់ហើយ ខ្លួនយើងក៏ទៅជាមនុស្សអាក្រក់ហើយដែរ តើយើងទៅយកមនុស្សល្អណា មកធ្វើជាខ្លួនយើងបានទៀត បើខ្លួនយើងមានតែម្នាក់ហ្នឹង ។ ខ្លួនយើងក្រណាស់ មានតែមួយគត់ ចាំបាច់ត្រូវតែថែរក្សាឱ្យល្អជាទីបំផុត ជាប្រយោជន៍ដើម្បីជួយខ្លួនឯង ។

ការលះបង់កិលេសជាគ្រឿងសៅហ្មងចិត្ត យើងមិនអាចពឹងអំណាចអ្នកដទៃបានឡើយ គឺត្រូវតែពឹងខ្លួនឯង ដែលខ្លួនឯងបានហ្វឹកហាត់អប់រំដល់កម្រិតកំពូលហើយនោះ ។ ការដែលពឹងអំណាចខាងក្រៅដើម្បីប្រព្រឹត្តបាបកម្ម ឈ្មោះថា មិនស្រឡាញ់ខ្លួន នាំសត្រូវគឺបាបកម្មមកសម្លាប់ខ្លួនឯងចោល ដូចជាសត្វលាដណ្តប់ស្បែកសីហៈ ហើយចូលស៊ីសន្ទូងអ្នកស្រែ ត្រូវអ្នកស្រែវាយសម្លាប់ ដូច្នោះឯង ។

មនុស្សអាចអប់រំខ្លួន រហូតដល់បានជាព្រះសម្មាសម្ពុទ្ធ ដូច្នេះ យើងត្រូវកុំបោះបង់ខ្លួនឯងចោលឱ្យសោះ ត្រូវរស់នៅជាមួយនឹងខ្លួនឯង ស្មោះត្រង់ ថែរក្សា ហ្វឹកហាត់អប់រំចម្រើនបញ្ញា ទាល់តែបានជាទីពឹងនៃខ្លួនឯងជាទីពឹងដែលគេបានដោយកម្របំផុត ។

ដូចនាយពាណិជ អាស្រ័យសេះដ៏ចម្រើន គឺសេះអាជានេយ្យ ហើយប្រាថ្នានូវលាភ ទើបង្ងូតទឹកឱ្យសេះនិង ឱ្យសេះបរិភោគមួយថ្ងៃបីដង ធ្វើឱ្យសេះអាជានេយ្យ

មានកម្លាំងកាយចិត្ត ធ្វើការនាំលាភមកឱ្យខ្លួន យ៉ាងណា ការដែលបុគ្គលស្ងួនគ្រងរក្សាខ្លួនដោយស្មារតី រមែងបាន នូវលាភគឺគុណវិសេស ទាំងលោកិយ ទាំងលោកុត្តរ ដូច្នោះឯង ។

គួរគិតថា ដើម្បីរក្សាជីវិតនេះ យើងអាចលះបង់ ទ្រព្យសម្បត្តិដែលយើងមានទាំងអស់ក៏បាន មានករណី ខ្លះ ទោះជាយើងព្រមលះបង់អ្វីៗគ្រប់យ៉ាង ក៏មិនអាច រក្សាជីវិតបានទៀតផង ដូច្នេះ ឥឡូវនេះ យើងបាននៅ រស់ហើយ គួរកំណាញ់ទេ គួររស់នៅដោយអត់សីលទេ ។ បើឱ្យទាន ថាស្ដាយទ្រព្យ បើកាន់សីល ខ្លាចលំបាក ចុះ បើយើងត្រូវស្លាប់បាត់ តើបានទ្រព្យ បានសប្បាយមក ពីណា ។

# ៤. សីលានិសំសជាតក

(បិដកលេខ ៥៨, ទំព័រ ៩៣)

**បស្ស សទ្ធាយ សីលស្ស ចាគស្ស ច អយំ ផលំ**
**នាគោ នាវាយ វណ្ណេន សទ្ធំ វហតុបាសកំ ។**
**សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ**
**សតំ ហិ សន្និវាសេន សោត្ថឹ គច្ឆតិ ន្ហាបិតោតិ។**

(សមុទ្ទទេវតាពោធិសត្វ ពោលថា) អ្នកចូរឃើញផលនៃសទ្ធា សីល និងចាគៈនេះចុះ ស្តេចនាគនិម្មិតខ្លួនជាសំពៅ នាំឧបាសកដែលជាអ្នកមានសទ្ធាទៅ ។

បុគ្គល គប្បីសេពគប់ជាមួយនឹងពួកសប្បុរសទាំងឡាយ គប្បីធ្វើនូវសេចក្តីស្និទ្ធស្នាលជាមួយនឹងពួកសប្បុរស ព្រោះថា ជាងកាត់សក់ដល់នូវសេចក្តីចម្រើនដោយសុខសួស្តី ព្រោះនៅរួមជាមួយនឹងពួកសប្បុរស ។

កាលព្រះបរមសាស្តាទ្រង់គង់ប្រថាប់នៅនាព្រះ-

ជេតពនមហាវិហារ មានឧបាសកម្នាក់ជាអរិយសាវ័កធ្វើដំណើរមកគាល់ព្រះអង្គ ។ ឧបាសកនោះមកដល់មាត់ស្ទឹងអចិរវតីនៅវេលាល្ងាច អ្នកអុំទូកចម្លងនាំគ្នាទៅស្តាប់ធម៌ឯវត្តអស់ ម៉្លោះហើយ ឧបាសកកាន់យកគុណព្រះពុទ្ធមកជាអារម្មណ៍ ពេលនោះបីតិកើតឡើងធ្វើឱ្យស្រាលខ្លួនរហូតដល់អាចដើរលើទឹកឆ្លងស្ទឹងទៅកាន់វត្តគាល់ព្រះដ៏-មានព្រះភាគបាន ។ កាលដែលឧបាសកក្រាបទូលព្រះ-ដ៏មានព្រះភាគ អំពីដំណើរមកដល់របស់ខ្លួន ព្រះអង្គទ្រង់ត្រាស់ថា កាលអំពីមុនក៏មានឧបាសករលឹកដល់ព្រះពុទ្ធ-គុណហើយបាននូវទីពឹងដែរ ។

កាលដែលឧបាសកអារាធនាហើយ ព្រះដ៏មាន-ព្រះភាគទ្រង់ត្រាស់សម្តែង ។ ក្នុងសាសនាព្រះកស្សប-សម្មាសម្ពុទ្ធ មានឧបាសកជាសោតាបន្នបុគ្គលម្នាក់ បានចុះសំពៅទៅជាមួយនឹងជាងកាត់សក់ ។ សំពៅត្រូវលិចកណ្តាលសមុទ្ទ ទាំងពីរនាក់តោងបន្ទះក្តារហើយបណ្តែតខ្លួនមកដល់កោះមួយ ។ ជាងកាត់សក់សម្លាប់សត្វនៅ

លើកោះបរិភោគ ទាំងបានចម្អិនឱ្យឧបាសកទៀត តែឧបាសកមិនព្រមបរិភោគឡើយ ។ ឧបាសកគិតថា ក្នុងទីនេះ ក្រៅអំពីព្រះរតនត្រ័យហើយ មិនមានទីពឹងដទៃសម្រាប់យើងឡើយ ទើបរលឹកគុណព្រះរតនត្រ័យ ។ កាលដែលឧបាសកកំពុងតែមាននូវអនុស្សតិដូច្នេះ ស្ដេចនាគដែលកើតនៅនឹងកោះនោះ បាននិម្មិតនូវរូបកាយរបស់ខ្លួនជាសំពៅដ៏ធំមួយ ដោយមានទេវតាប្រចាំសមុទ្រធ្វើជាមាណពម្ចាស់សំពៅ ចំណែកនៅក្នុងសំពៅ ពេញទៅដោយកែវប្រាំពីរប្រការ ។ ទេវតាឈរនៅលើសំពៅប្រកាសថា មានអ្នកទៅជម្ពូទ្វីបដែរទេ ? ឧបាសកតបថា យើងទៅ ។ ទេវតាថា បើដូច្នោះ អ្នកចូរឡើងសំពៅមក ។ កាលដែលឧបាសកហៅជាងកាត់សក់ឡើងសំពៅ ទេវតាពោលថា បានតែឧបាសកម្នាក់ឯងប៉ុណ្ណោះ ម្នាក់ទៀតនោះ ពុំបានឡើយ ។ ឧបាសកសួរថា ព្រោះហេតុអ្វី ? ទេវតាតបថា ព្រោះគេមិនមាននូវគុណ មានសីល-គុណជាដើម ទើបខ្ញុំនាំសំពៅមក សម្រាប់តែឧបាសក

ប៉ុណ្ណោះ មិនសម្រាប់គេទេ ។ ឧបាសកប្រកាសថា បើដូច្នោះ យើងឱ្យចំណែកបុណ្យដល់គេ ចំពោះទានដែលយើងបានឱ្យហើយ សីលរក្សាហើយ ភាវនាចម្រើនហើយ ។ កាលដែលឧបាសកជូនបុណ្យដល់ជាងកាត់សក់ហើយ ជាងកាត់សក់ក៏បានអនុមោទនា ។ ទេវតាពោលថា ខ្ញុំនាំអ្នកទាំងពីរទៅ អ្នកទាំងពីរចូរឡើងសំពៅមក ។ ទេវតាបាននាំឧបាសកនិងជាងកាត់សក់ដល់ក្រុងពារាណសី ដោយអានុភាពរបស់ខ្លួន ទាំងជូនកែវកងក្នុងសំពៅទាំងអស់ឱ្យដល់អ្នកទាំងពីរទៀតផង ។

កាលដែលពោលដល់គុណនៃការសេពគប់ជាមួយនឹងបណ្ឌិត ទេវតាទើបពោលនូវគាថាទាំងពីរគាថា ដែលព្រះអដ្ឋកថាមានការពន្យល់ដូចតទៅ :

ក្នុងបទទាំងនោះ បទថា **បស្ស** បានដល់ការហៅឱ្យមកមើល ដោយមិនកំណត់ចំពោះអ្នកណាៗឡើយ ។

បទថា **សទ្ធាយ** គឺដោយលោកិយសទ្ធា និងលោកុត្តរសទ្ធា ។ សូម្បីសីលក៏មានន័យដូចគ្នានឹងសទ្ធា

ដែរ ។

បទថា **ចាគស្ស** បានដល់ បរិច្ចាគទេយ្យធម៌ និង បរិច្ចាគកិលេស ។

បទថា **អយំ ផលំ** បានដល់ នេះជាផល គឺជាគុណ ជាអានិសង្ស ។ ម្យ៉ាងទៀត គប្បីជ្រាបសេចក្តីអធិប្បាយក្នុងបទនេះថា ចូរមើលផលនៃការបរិច្ចាគចុះ ស្តេចនាគនេះប្លែងភេទជាសំពៅ ។

បទថា **នាវាយ វណ្ណេន** គឺដោយសណ្ឋានជានាវា បានដល់សំពៅ ។

បទថា **សទ្ធំ** គឺមានសទ្ធាតាំងនៅក្នុងគុណនៃព្រះរតនត្រ័យ ។

បទថា **សព្ភិរេវ** គឺពួកបណ្ឌិតនោះឯង ។

បទថា **សមាសេថ** បានដល់ គប្បីធ្វើការសេពគប់ ។

បទថា **សន្ថវំ** បានដល់ ស្និទ្ធស្នាល គឺស្និទ្ធស្នាល

ក្នុងភាពជាមិត្ត មិនគប្បីធ្វើសេចក្ដីស្និទ្ធស្នាលដោយតណ្ហា ជាមួយនឹងអ្នកណា១ឡើយ ។

បទថា **ឆ្លាចិតោ** បានដល់ ជាងកាត់សក់ ។

ទេវតាប្រចាំសមុទ្ទ ឈរក្នុងអាកាសសម្ដែងធម៌យ៉ាងនេះហើយ ទើបនាំស្ដេចនាគត្រឡប់ទៅវិមានរបស់ខ្លួនវិញ ។

ព្រះបរមសាស្ដាទ្រង់នាំព្រះធម៌ទេសនានេះ មកហើយ ទ្រង់ប្រកាសសច្ចធម៌ ហើយទ្រង់ប្រជុំជាតក ។ ក្នុងពេលចប់សច្ចធម៌ ឧបាសកដែលឆ្លងស្ទឹងអចិរវតី ដោយដើរលើទឹកនោះឯង បានតាំងនៅក្នុងសកទាគាមិផល ។ ឧបាសកជាសោតាបន្នបុគ្គលក្នុងសាសនាព្រះពុទ្ធកស្សបៈនោះ កាលចម្រើននូវមគ្គឱ្យក្រៃលែងឡើង១ ក៏បរិនិព្វានទៅ ។ ស្ដេចនាគបានមកជាសារីបុត្ត ចំណែកទេវតាប្រចាំសមុទ្ទ គឺជា **តថាគត** នេះឯង ។

**មនុស្សល្អ ព្រោះបានរស់នៅជាមួយនឹងសេចក្ដីល្អ**

ក្នុងព្រះធម្មបទ បាបវគ្គ ព្រះអង្គទ្រង់ត្រាស់ថា

**មាវមញ្ញេថ បុញ្ញស្ស ន មត្តំ អាគមិស្សតិ**
**ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ**
**អាបូរតិ ធីរោ បុញ្ញស្ស ថោកំ ថោកំបិ អាចិនំ។**

បុគ្គល មិនគួរមើលងាយបុណ្យថា មានប្រមាណតិច នឹងមិនឱ្យផលដូច្នេះឡើយ ប្រៀបដូចក្អមទឹក រមែងពេញបានដោយតំណក់ទឹកដែលធ្លាក់ចុះ យ៉ាងណា អ្នកមានប្រាជ្ញា កាលសន្សំបុណ្យបន្តិចម្ដងៗ គង់ពេញបានដោយបុណ្យ យ៉ាងនោះឯង ។

## គំនិតយល់ដឹង

១. ប្រាក់មិនអាចលះបង់កិលេស ដែលជាគ្រឿងសៅហ្មងចិត្តបានឡើយ ។ បើមិនបានលះបង់នូវកិលេសទេ តើក្នុងលោកនេះ យើងគិតថាបានអ្វី ។

២. ពាក្យថា « បាននេះ បាននោះ » គឺគ្រាន់តែសន្មតប៉ុណ្ណោះ តាមបរមត្ថ « អ្នកបាន » អត់មានក្នុងលោកនេះទេ ។

៣. កិលេសប្រកាន់បញ្ចក្ខន្ធ ធ្វើឱ្យមានគំនិតយល់ខុសកើតឡើង គិតថាជាខ្លួនយើង រួចទៅទើបគិតថា ខ្លួនយើងបាននេះ បាននោះ ម្ល៉ោះហើយ ទើបសត្វលោកចេះតែខ្វល់នឹងខ្លួនឯង ។

៤. ក្រៅអំពីវិថីចិត្តដឹងនូវអារម្មណ៍តាមទ្វារ ៦ ទ្វារណាមួយ និង ការសប្បាយចិត្តទៅតាមការសោយអារម្មណ៍មួយពេល មួយគ្រាប៉ុណ្ណឹង តើមានអ្វីទៀតទៅដែលឱ្យសម្គាល់ថា យើងសំខាន់ណាស់នោះ ។

៥. អ្វីៗទាំងអស់ ដែលយើងរីករាយជាមួយ បើមិនបានលះបង់នូវបាបធម៌ក្នុងចិត្តយើងទេ អ្វីៗទាំងអស់នោះ សុទ្ធតែជាគ្រឿងញៀន គ្រឿងស្រវឹង នាំឱ្យស្វែងរក នាំឱ្យជាប់ជំពាក់ និង នាំឱ្យកើតទុក្ខ សោកសៅ ។

៦. នៅពេលដែលយើងត្រេកអរនឹងការបាននូវអ្វី

មួយ ឧទាហរណ៍ថា បានផ្ទះធំស្អាតមួយ យើងគួររលឹកដឹងថា តើយើងដែលជាអ្នកបាននោះ គឺជាអ្វីទៅ កុំចេះតែត្រេកអរថា យើងបានផ្ទះ ឬបានរបស់នេះ របស់នោះដូច្នោះឡើយ ។

៧. បើយើងកើតស្រែងរមាស់ តើយើងគួរត្រេកអរនឹងចុងក្រចក ហើយទុកស្រែងឱ្យនៅរមាស់គ្រាន់អេះ ឬត្រូវប្រើថ្នាំកម្ចាត់បង់នូវរោគស្រែងនោះ ចោលចេញវិញ ? បញ្ចក្ខន្ធកើតឡើងដូចជារោគស្រែងរមាស់ ។ បច្ច័យ ៤ គឺគ្រឿងស្លៀកដណ្តប់ បាយទឹក ផ្ទះសំបែង ថ្នាំកែរោគ និង អ្វីៗទៀតទាំងអស់ ដែលសម្រាប់យកមកដោះស្រាយឱ្យបញ្ចក្ខន្ធ បច្ច័យ ៤ នេះដូចជាចុងក្រចកដែលសម្រាប់អេះ ។ តើគួរត្រេកអរនឹងបច្ច័យ ៤ ឬត្រូវកំណត់ដឹងនូវបញ្ចក្ខន្ធ ជាប្រយោជន៍ដល់ការមិនចាប់ប្រកាន់ថាជាខ្លួនយើង និង ជាប្រយោជន៍ដល់ការអស់បញ្ចក្ខន្ធវិញ ?

សរុបគំនិតយល់ដឹងទាំង ៧ ចំណុចខាងលើនេះ

មក គឺយើងត្រូវតែទទួលស្គាល់បុណ្យ ហើយសេពគប់ជាមួយនឹងបុណ្យ ត្រេកអរក្នុងការលះបង់បាបកម្ម និងកិលេសតណ្ហាទាំងពួង ដូចជាងកាត់សក់បានសេពគប់នឹងឧបាសក អនុមោទនាបុណ្យរបស់ឧបាសក ទើបបានឡើងកាន់សំពៅរតនៈ ផុតភ័យដល់នូវសួស្តី ដូច្នោះឯង ។

លាមក សូម្បីតែបន្តិចបន្តួចក៏ធ្វើឱ្យយើងមានសេចក្តីដឹងខ្លួនថារំខានដែរ ព្រោះមិនស្អាតហើយមានក្លិនស្អុយ ផ្ទុយមកវិញ ផ្កាម្លិះតែមួយ ក៏ធ្វើឱ្យយើងមានចិត្តរីករាយនឹងក្លិនក្រអូប ទាំងពណ៌សម្បុររូបរាងផងដែរ ។ បាបដូចជាលាមក ទោះជាបន្តិចបន្តួចក៏ត្រូវលះបង់លាងសម្អាតដោយពិត ឯចំណែកបុណ្យកុសលវិញមិនថាតិចច្រើន តូចធំ អ្នកណាដឹង អ្នកណាមិនដឹងឡើយ គប្បីសន្សំអប់រំជានិច្ច ព្រោះនាំមកនូវការរីករាយគ្រប់កាលទាំងពួង ។

# ៥. មិត្តាមិត្តជាតក

(បិដកលេខ ៥៨, ទំព័រ ៩៨)

ព្រះពោធិសត្វពោលថា បុគ្គលជាសត្រូវ ឃើញបុគ្គលនោះហើយ មិនញញឹមរកផង មិនរីករាយតបនឹងបុគ្គលនោះផង មិនឱ្យភ្នែកចំពោះបុគ្គលនោះ គឺមិនសម្លឹងចំភ្នែកគ្នាផង ។

បុគ្គលជាបណ្ឌិត ឃើញហើយ ឮហើយ រមែងស្គាល់នូវបុគ្គលដែលជាសត្រូវ ដោយអាការទាំងឡាយណា អាការទាំងឡាយនោះ រមែងតាំងនៅក្នុងសត្រូវពិតមែន ។

នៅវត្តជេតពន មានភិក្ខុមួយអង្គកាន់យកដោយវិស្សាសៈ គឺសេចក្ដីស្និទ្ធស្នាល នូវសំពត់សេសសល់មួយផ្ទាំងរបស់ព្រះឧបជ្ឈាយ៍ ដោយគិតថា កាលដែលយើងកាន់យកហើយ ព្រះឧបជ្ឈាយ៍របស់យើងមិនក្រោធឡើយ

ហើយក៏យកទៅធ្វើជាថង់ដាក់ស្បែកជើង ។ ក្រោយមក ទើបភិក្ខុអង្គនោះ ទូលដល់ព្រះឧបជ្ឈាយ៍ ។ ព្រះ-ឧបជ្ឈាយ៍សួរថា ព្រោះហេតុអ្វីទើបយក ? ភិក្ខុតបថា កាន់យកដោយវិស្សាសៈ ។ ព្រះឧបជ្ឈាយ៍បានពោលថា ឈ្មោះថាវិស្សាសៈរបស់លោកជាមួយនឹងយើង យ៉ាង ម៉េចកើតទៅ ។ ព្រះឧបជ្ឈាយ៍ក្រោកចេញដោយក្រោធ។ អាការទាំងឡាយនៃព្រះឧបជ្ឈាយ៍នោះ បានប្រាកដដល់ ពួកភិក្ខុ ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងព្រះជាតក ប្រារព្ធដល់ព្រះឧបជ្ឈាយ៍និងភិក្ខុនោះឯង ។ ព្រះបរម-ពោធិសត្វ ក្នុងកាលនោះ កើតក្នុងត្រកូលព្រាហ្មណ៍ក្នុង ដែនកាសី ចម្រើនវ័យហើយ បានបួសជាតាបសសម្រេច សមាបត្តិ និង អភិញ្ញា ហើយបានជាគ្រូលើពួកតាបស ទាំងឡាយ ក្នុងព្រៃហិមពាន្ត ។ ក្នុងពួកតាបសនោះ មាន តាបសមួយអង្គ មិនស្តាប់ពាក្យណែនាំនៃព្រះបរមពោធិ-សត្វ បានចិញ្ចឹមកូនដំរីកំព្រាមួយ ។ លុះកូនដំរីនោះធំ

ឡើង បានសម្លាប់តាបសនោះ ហើយចូលព្រៃបាត់ទៅ ។ ពួកតាបស បានធ្វើឈាបនកិច្ចចំពោះសពហើយ ទើបនាំគ្នាចូលទៅរកព្រះបរមពោធិសត្វ ទូលសួរថា បពិត្រព្រះគុណម្ចាស់ ភាពជាមិត្ត ឬភាពជាសត្រូវ តើអាចដឹងបានដោយហេតុដូចម្តេច ? ព្រះបរមពោធិសត្វ បានប្រកាសហេតុ ដោយការពោលនូវព្រះគាថាដែលមានសេចក្តីដូចខាងដើម ។ ចំណែកភាពជាមិត្ត គប្បីដឹងបានដោយអាការជួយគ្នាពីសត្រូវនោះឯង ។

ព្រះបរមពោធិសត្វ បានប្រាប់ហេតុនៃភាពជាមិត្ត និង ភាពជាសត្រូវដល់ពួកតាបសដូច្នេះឯង កាលដែលអស់ជីវិត ក៏បដិសន្ធិក្នុងព្រហ្មលោក ។

ព្រះបរមសាស្តាសម្មាសម្ពុទ្ធ ជាមកុដត្រៃលោក បាននាំយកព្រះធម៌ទេសនានេះមកហើយ ព្រះអង្គប្រជុំជាតក ។ តាបសដែលចិញ្ចឹមដំរីក្នុងកាលនោះ បានមកជាសទ្ធិវិហារិកក្នុងគ្រានេះ ដំរីបានមកជាព្រះឧបជ្ឈាយ៍ តាបសជាគ្រូប្រចាំគណៈគឺ **តថាគត** ។

# កុំចិញ្ចឹមសត្រូវនៅក្នុងចិត្ត

ក្នុងព្រះគាថាធម្មបទ បាបវគ្គ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា

**មាវមញ្ញេថ បាបស្ស    ន មត្តំ អាគមិស្សតិ**
**ឧទពិន្ទុនិបាតេន    ឧទកុម្ភោបិ បូរតិ**
**អាបូរតិ ពាលោ បាបស្ស    ថោកំ ថោកំបិ អាចិនំ។**

បុគ្គលមិនគួរមើលងាយបាបថា មានប្រមាណតិច នឹងមិនឱ្យផលដូច្នេះឡើយ ប្រៀបដូចក្អមទឹក រមែងពេញបានដោយតំណក់ទឹកដែលធ្លាក់ចុះ យ៉ាងណា បុគ្គលពាលកាលសន្សំបាបបន្តិចម្តងៗ គង់ពេញបានដោយបាប យ៉ាងនោះឯង ។

**វាណិជោវ ភយំ មគ្គំ    អប្បសត្ថោ មហទ្ធនោ**
**វិសំ ជីវិតុកាមោវ    បាបានិ បរិវជ្ជយេ ។**

បុគ្គលគប្បីចៀសវាងបាបទាំងឡាយ ឱ្យដូចពាណិជ ដែលមានទ្រព្យច្រើន តែមានគ្នាតិច ចៀសវាង

ផ្លូវដែលមានភ័យ មានចោរភ័យជាដើម ឬដូចជាបុរសដែលប្រាថ្នាការរស់នៅ រមែងចៀសវាងនូវការផឹកថ្នាំពិសដូច្នោះដែរ ។

នៅក្នុងព្រះធម្មបទ ពាលវគ្គ ព្រះអង្គត្រាស់ថា

**ចរន្តិ ពាលា ទុម្មេធា  អមិត្តេនេវ អត្តនា**
**ករោន្តា បាបកំ កម្មំ  យំ ហោតិ កដុកប្ផលំ ។**

ពួកជនពាលមិនមានប្រាជ្ញា មានខ្លួនដូចជាសត្រូវ តែងធ្វើកម្មដ៏លាមក ដែលជាអំពើមានផលក្ដៅក្រហាយ។

## គំនិតយល់ត្រូវ

១. សេចក្ដីទុក្ខគ្របសង្កត់បុគ្គលប្រមាទ តាមរយៈសេចក្ដីសុខ ដូចបុគ្គលបរិភោគត្រីមិនបានប្រយ័ត្ន ក៏ត្រូវស្លាក់ឆ្អឹង ដូច្នោះឯង ។

២. របស់ដែលមានអានិសង្សឱ្យសុខ ឱ្យសប្បាយ ត្រូវប្រយ័ត្នទោស ។

៣. របស់ដែលមានទោសឱ្យទុក្ខ ឱ្យលំបាក មិន

មែនឱ្យខូចចិត្តនោះទេ ព្រោះជាតិជាបណ្ឌិតតែងអប់រំចិត្ត នៅពេលមានវិបត្តិ ចំណែកបុគ្គលល្ងង់ខ្លៅវិញ បែរទៅជាខូចខ្លួន ខូចនិស្ស័យ ព្រោះអាស្រ័យបានសម្បត្តិ មានលាភ មានយស ។

៤. រសជាតិល្វីងអាចជាថ្នាំកែរោគ តែបើមិនប្រយ័ត្នជាមួយអ្វីដែលផ្អែមៗ នាំឱ្យឈឺ ។

៥. ជន្លេនក្នុងដីអាចឱ្យត្រីក្នុងទឹកជាប់មាត់នឹងផ្លែសន្ទូចបាន ព្រោះអំពើរបស់នាយព្រាន ដូច្នេះមនុស្សត្រូវប្រយ័ត្នចំពោះការស្រេកឃ្លានគ្រប់យ៉ាង ឃ្លានអ្វីក៏ដោយកុំឱ្យដូចត្រីដែលគិតខុសថា វាគ្រាន់តែជាសត្វជន្លេនមួយប៉ុណ្ណោះ គ្មានទោស គ្មានភ័យអ្វីទេ ស៊ីវាទៅ ។

សរុបអត្ថន័យទាំង ៥ ចំណុចខាងលើមក គឺកុំសេពគប់ជាមួយនឹងបាប ប្រយ័ត្នសត្រូវនៅក្នុងខ្លួន កុំមានខ្លួនជាសត្រូវនឹងខ្លួនឯង ។

# ៦. រាធជាតក

(បិដកលេខ ៥៨, ទំព័រ ៩៨)

**ន ខោ បនេតំ សុភណំ គិរំ សច្ចូបសញ្ហិតំ**
**សយេថ បោដ្ឋបាទោវ មុម្មុរេ ឧបកូសិតោតិ ។**

បុគ្គល កាលពោលវាចាដែលប្រកបដោយសច្ចៈ នេះ តែមិនល្អ គប្បីដេកដូចជាសេកឈ្មោះបោដ្ឋបាទ ត្រូវដុតក្នុងជើងក្រាន ដូច្នោះឯង ។

កាលដែលព្រះពោធិសត្វ កើតក្នុងកំណើតសត្វ សេកឈ្មោះរាធៈ កាលនោះ ព្រះអានន្ទកើតជាសេកប្អូន ឈ្មោះបោដ្ឋបាទ ។

ព្រានបានចាប់យកសេកទាំងពីរ ទៅឱ្យព្រាហ្មណ៍ ម្នាក់ក្នុងនគរពារាណសី ព្រាហ្មណ៍បានចិញ្ចឹមសេកបង ប្អូនទាំងពីរនោះ ទុកក្នុងឋានៈជាបុត្រ ។

ព្រាហ្មណីជាភរិយារបស់ព្រាហ្មណ៍ មិនរក្សាខ្លួន

ទុកក្នុងគុណធម៌ មិនចេះស្រឡាញ់ខ្លួន សេពគប់ជាមួយបាប ជាស្ត្រីទ្រុស្តសីល ប្រព្រឹត្តអនាចារជាមួយនឹងបុរសដទៃ នៅពេលដែលព្រាហ្មណ៍ជាប្តីចេញទៅធ្វើជំនួញ ។

សេកបោដ្ឋបាទចង់និយាយរឿងនោះចេញមក តែត្រូវសេកពោធិសត្វហាមឃាត់ ។ សេកបោដ្ឋបាទ អត់ទ្រាំមិនបាន មិនស្តាប់ពាក្យរបស់បង ទើបពោលនឹងព្រាហ្មណីថា ម៉ែ ម៉េចបានជាម៉ែប្រព្រឹត្តក្បត់ឪយ៉ាងនេះ ម៉ែធ្វើអំពើអាក្រក់ណាស់ ។ នាងព្រាហ្មណីចង់សម្លាប់សេកបោដ្ឋបាទ ក្លែងធ្វើជាស្រឡាញ់ ដោយពោលពាក្យផ្អែមល្ហែមហៅឱ្យមកជិតថា នែកូនសម្លាញ់ ! កូនរបស់ម៉ែ ! ចាប់តាំងពីថ្ងៃនេះទៅ ម៉ែឈប់ប្រព្រឹត្តទៀតហើយ កូនមកជិតម៉ែមកកូន ។ គ្រាន់តែសេកបោដ្ឋបាទមកជិតដៃភ្លាម ក៏ប្រញាប់ចាប់ត្រង់ក ហើយក្តាប់យ៉ាងខ្លាំង ពោលថា អាឯងនិយាយស្អី ចេះដឹងស្អី មិនចេះប្រមាណខ្លួនសោះ រួចច្របាច់កទាល់តែសេកបោដ្ឋបាទស្លាប់ ហើយបោះទៅក្នុងចង្ក្រានភ្លើង ។

ពេលដែលព្រាហ្មណ៍មកពីធ្វើជំនួញវិញ បានសាកសួរពីព្រាហ្មណីចំពោះសេកពោធិសត្វថា នៃរាធៈ ! ម៉ែរបស់កូនយ៉ាងម៉េចដែរ មានប្រព្រឹត្តអនាចារទេ ?

សេករាធៈជាព្រះពោធិសត្វបានពោលថា បពិត្របិតា ធម្មតាបណ្ឌិតទាំងឡាយ រមែងមិនពោលពាក្យពិតដែលពាក្យពិតនោះ មិនអាចធ្វើឱ្យផុតចាកទុក្ខបាននោះឡើយ ហើយក៏មិនពោលពាក្យមិនពិតដែរ ។ កាលដែលបញ្ជាក់សេចក្តីនេះ ទាំងដែលជម្រាបបិតាអំពីប្អូនរបស់ខ្លួនផង ទើបពោលគាថា ដែលមានសេចក្តីខាងដើម ។

## ជីវិតប្រសើរគឺរស់នៅដោយបញ្ញា

នៅក្នុងព្រះធម្មបទ ធម្មដ្ឋវគ្គ ព្រះអង្គត្រាស់ថា

**ន តេន បណ្ឌិតោ ហោតិ យាវតា ពហុ ភាសតិ**
**ខេមី អវេរី អភយោ បណ្ឌិតោតិ បវុច្ចតិ ។**

បុគ្គលនិយាយច្រើន ដោយហេតុមានប្រមាណប៉ុនណា ឈ្មោះថាជាបណ្ឌិត ដោយហេតុមានប្រមាណ

ប៉ុណ្ណោះ មិនទាន់បានទេ លុះត្រាតែបុគ្គលដែលមាន សេចក្ដីក្សេម មិនមានពៀរ មិនមានភ័យ ទើបហៅបាន ថាជាបណ្ឌិត ពិតប្រាកដមែន ។

នៅក្នុងព្រះធម្មបទ សុខវគ្គ ព្រះអង្គត្រាស់ថា

**ជយំ វេរំ បសវតិ ទុក្ខំ សេតិ បរាជិតោ**

**ឧបសន្តោ សុខំ សេតិ ហិត្វា ជយបរាជយំ ។**

អ្នកឈ្នះតែងប្រទះនូវពៀរ អ្នកចាញ់តែងដេកជាទុក្ខ ចំណែកបុគ្គលដែលលះបង់នូវការឈ្នះចាញ់ចោលហើយ ជាបុគ្គលស្ងប់ ដេកនៅជាសុខ ។

## គំនិតយល់ដឹង

១. ផែនដីនេះ មានភ្នំ មានជ្រោះ នឹងឱ្យលោកនេះរាបស្មើបានយ៉ាងដូចម្ដេចទៅ ។

២. ក្នុងលោកនេះ វរវឹកដោយរឿងនេះ រឿងនោះ អ៊ីចឹងឯង កុំចាំបាច់ឱ្យលោកនេះស្ងប់សិន សឹមយើងរកសុខនោះ ត្រូវអប់រំចិត្តឱ្យសុខស្ងប់ខ្លួនឯង ឥឡូវនេះ

តែម្តង ដោយការព្រមទទួលសេចក្តីពិត ព្រោះថា អ្វីៗ សុទ្ធតែពិតទៅតាមបច្ច័យទាំងអស់ ។

៣. កាលដែលព្រមទទួលសេចក្តីពិតហើយ រមែងរសាយនូវសេចក្តីទុក្ខក្នុងចិត្ត ចង់គេចពីការពិត នឹងកើតរោគសរសៃប្រសាទ ដូច្នេះ ត្រូវធ្វើចិត្តឱ្យសប្បាយៗ ដោះស្រាយបញ្ហាដែលត្រូវដោះ បានប្រយោជន៍ទាំងអស់គ្នា ។

៤. បើចិត្តមានបញ្ហាហើយ នឹងទៅដោះស្រាយបញ្ហាឯណាទៀតបានទៅ ត្រូវដោះក្នុងចិត្តរបស់ខ្លួនសិន ត្រូវយល់តាមបរមត្ថថា អ្វីៗគ្មានអ្នកណាធ្វើទេ វាជារបស់ក្នុងលោក យើងមិនអាចទាមទារតាមការពេញចិត្តបានឡើយ តែវាយ៉ាងម៉េច គឺវាអ៊ីចឹងហើយ យើងក៏មិនចង់ឱ្យលោកនេះ មិនមានការពិតនោះដែរ ព្រោះមានតែការពិតនេះឯងហើយ ដែលយើងអាចរកយុត្តិធម៌ឃើញ ហើយបានធ្វើឱ្យយើងសុខចិត្ត ។

៥. បើត្រូវស្ងៀមក៏ស្ងៀមដោយស្ងប់ បើត្រូវ

និយាយ ក៏និយាយតែពាក្យពិតហើយមានប្រយោជន៍ ជាពាក្យពីរោះប្រកបដោយចិត្តសប្បុរស ទាំងឱ្យត្រូវតាមកាលទៀតផង ។

៦. ពាក្យចាស់ពោលថា ឈើរលំដួល ដើរកន្លងបាន តែបើមនុស្សរលំដួលកុំកន្លងឱ្យសោះ ។ កុំដេញឆ្កែឱ្យទាល់ច្រក ព្រោះឆ្កែទាល់ច្រកវាបកខាំវិញ ម្យ៉ាងទៀតត្រូវប្រយ័ត្នឆ្កែឆ្កួតខាំ វានាំឱ្យឆ្លងឆ្កួត ។

៧. កុំយកកំហុសរបស់អ្នកដទៃ មកធ្វើជាការគ្រាន់បើរបស់ខ្លួន ។ ត្រូវប្រយ័ត្នការមាក់ងាយអ្នកដទៃ ព្រោះនាំឱ្យបាត់បង់មេត្តាចិត្តខ្លួនឯង ។

សរុបគំនិតយល់ដឹងទាំង ៧ ចំណុចខាងលើនេះមក គឺយើងត្រូវតែសិក្សាសច្ចធម៌ អភិវឌ្ឍនូវចំណេះដឹងនិងគុណធម៌ សម្រេចសេចក្ដីសុខក្នុងចិត្តរបស់ខ្លួន ។

# ៧. សាធុសីលជាតក

(បិដកលេខ ៥៨, ទំព័រ ១០០)

**អត្ថោ អត្ថិ សរីរស្មឹ     វណ្ណវន្តស្ស នមោ ករេ**
**អត្ថោ អត្ថិ សុជាតស្មឹ     សីលំ អស្មាក រុច្ចតីតិ។**

(អាចារ្យពោធិសត្វពោលថា) ប្រយោជន៍ក្នុងរាងកាយរមែងមាន ខ្ញុំសូមធ្វើនូវកិរិយាឱនលំទោនចំពោះបុគ្គលដែលចម្រើនដោយវ័យ ប្រយោជន៍រមែងមានក្នុងបុគ្គលដែលមានជាតិល្អ ប៉ុន្តែ សីលរមែងជាទីពេញចិត្តរបស់យើង ។

រឿងក្នុងអតីតកាល ព្រះបរមពោធិសត្វជាអាចារ្យទិសាបាមោក្ខ បានពោលនូវគាថាខាងលើនេះ ក្នុងពេលដែលមានព្រាហ្មណ៍ម្នាក់មកសាកសួរ ។ ព្រាហ្មណ៍ម្នាក់នោះ មានធីតាដ៏ស្រស់ស្អាតកំពុងពេញវ័យ ព្រមពេលគ្នាមានបុរស ៤ នាក់ត្រូវការធីតារបស់គាត់ជាភរិយា ។

ព្រាហ្មណ៍មិនដឹងថាត្រូវលើកឱ្យបុរសមួយណា ទើបបាន មកសួរព្រះបរមពោធិសត្វថា ខ្ញុំសូមសួរព្រាហ្មណ៍ជា លោកអាចារ្យ ក្នុងបណ្តាបុរស ៤ នាក់ ម្នាក់មានរូបរាង ល្អស្អាត ម្នាក់មានអាយុច្រើន ម្នាក់មានជាតិប្រសើរខ្ពស់ និង ម្នាក់ទៀត មានសីលល្អ តើលោកអាចារ្យពេញចិត្ត បុគ្គលបែបណា ? ព្រះពោធិសត្វក៏បានតបទៅព្រាហ្មណ៍ នោះវិញ ។

កាលដែលព្រាហ្មណ៍អ្នកជ្រើសរើសរកកូនប្រសា បានស្តាប់ពាក្យរបស់ព្រាហ្មណ៍ ជាព្រះបរមពោធិសត្វរួច ហើយ ក៏បានលើកកូនស្រីរបស់គាត់ឱ្យដល់បុរសអ្នកមាន សីលនោះឯង ។

បទថា **អត្ថោ អត្ថិ សរីរស្មឹ** ដោយសេចក្តីថា សេចក្តីចម្រើនក្នុងកាយសម្បទា ក៏វិសេសគួរឱ្យប្រាថ្នា ហើយ មិនមែនថាអត់ប្រយោជន៍នោះទេ ។

បទថា **វុឌ្ឍព្យស្ស នមោ ករេ** ដោយសេចក្តីថា យើងក៏ធ្វើនូវការឱនលំទោន នមស្ការចំពោះបុគ្គលដែល

ចម្រើនដោយវ័យដែរ ព្រោះបុគ្គលដែលចម្រើនដោយវ័យ រមែងគួរដល់ការក្រាបសំពះ គោរពរាប់អាន ។

បទថា **អត្ថោ អត្ថិ សុជាតស្មឹ** ដោយសេចក្ដីថា ភាពចម្រុងចម្រើនចំពោះមនុស្សដែលមានជាតិត្រកូលល្អខ្ពស់ ក៏មានពិតហើយ ព្រោះជាតិសម្បត្តិគួរជាទីប្រាថ្នានៃមហាជន ។

ព្រះបរមពោធិសត្វបញ្ចប់ដោយបទថា **សីលំ អស្មាកំ រុច្ចតិ** ប៉ុន្តែ យើងពេញចិត្តចំពោះអ្នកមានសីលតែប៉ុណ្ណោះ ។ អ្នកមានសីលសម្បូណ៌ដោយមារយាទ សូម្បីខ្វះខាតនូវសិរីសម្បត្តិ ក៏នៅតែគួរដល់ការបូជា គួរដល់ការសរសើរ ។

## ខ្លឹមសារនៃជីវិតគឺការប្រព្រឹត្តធម៌

ក្នុងព្រះគាថាធម្មបទ សហស្សវគ្គ ទ្រង់ត្រាស់ថា

**យោ ច វស្សសតំ ជីវេ ទុស្សីលោ អសមាហិតោ**
**ឯកាហំ ជីវិតំ សេយ្យោ សីលវន្តស្ស ឈាយិនោ។**

បុគ្គលណា រស់នៅអស់រយឆ្នាំ តែជាមនុស្ស ទ្រុស្តសីល មានចិត្តមិនបានតម្កល់ខ្ជាប់ខ្ជួន (បុគ្គលនោះ មិនប្រសើរ ) ចំណែកអ្នករស់នៅតែមួយថ្ងៃដែលមាន សីល មានការសម្លឹងពិនិត្យ ទើបប្រសើរ (គឺប្រសើរជាង ការរស់នៅអស់រយឆ្នាំដែលអត់សីល អត់តម្កល់ចិត្ត )។

## គំនិតយល់ដឹង

ព្រោះតែចិត្តកាចសាហាវ អាក្រក់ឃោរឃៅ លោកនេះពេញទៅដោយសត្រូវ គឺជាសត្រូវដែលចិត្តខ្លួន ឯងបានសាងឡើង ម្ល៉ោះហើយ ត្រូវភ័យខ្លាចជាមួយនឹង អារម្មណ៍ជុំវិញខ្លួន សូម្បីដេកពួនក្នុងវិមាន ក៏ដូចដេកក្នុង ព្រៃខ្មោចដែរ ។

ចិត្តមានមេត្តាសាងញាតិមិត្ត ចិត្តឃោរឃៅពិតសាងសត្រូវ
ស្អប់អ្នកដទៃគឺដើរផ្លូវ ទៅរកសត្រូវឱ្យខ្លួនឯង ។
ស្អប់គេគឺស្អប់ខ្លួនឯងជាង បាបតាមរូបរាងប្រាកដស្តែង
មុខមាត់ភាសាខ្វះកោតក្រែង ដុតចិត្តខ្លួនឯងចាញ់អាត្មា ។

ព្យេរមិនរំងាប់ដោយវេរា　　បើមិនស្មារលានឹងខ្លោចផ្សា
ដូចរឿងមេម្រឹគនិងមេខ្លា　　សងសឹកប្រហារតភពជាតិ ។
នឹកដល់ទីឃាវុកុមារ　　ស្ដាប់ពាក្យបិតាពេលបែកឃ្លាត
ធ្វើឱ្យសត្រូវក្លាយជាញាតិ　　រួមជាតិទាំងរួមរាជបុត្រី ។
ព្រះពុទ្ធោវាទនិងសុចរិត　　ជាព្រះក្នុងចិត្តគ្មានបាយសី
រស់នៅបានសុខមានសិរី　　រួចព្យេររួចភ័យប្រាំប្រការ ។
សីលប្រាំកម្មបថឫក្សពេលា　　អាពាហ៍ពិពាហ៍ចងហត្ថា
ចងឱ្យកូនចាំពាក្យមេបា　　រក្សាសង្គ្រោះរស់តាមធម៌ ។

ដោយ **ម.ស.វ.**

# ៨. គរហិតជាតក

( បិដកលេខ ៥៨, ទំព័រ ១១៣ )

ពានរពោធិសត្វពោលថា មនុស្សទាំងឡាយ ដែលល្ងង់ខ្លៅ មិនឃើញអរិយធម៌ ចេះតែនិយាយគ្នាថា ប្រាក់របស់យើង មាសរបស់យើង ដូច្នេះឯង ទាំងយប់ទាំងថ្ងៃ ។ ក្នុងផ្ទះមួយ មានម្ចាស់ផ្ទះពីរនាក់ ក្នុងបណ្ដាម្ចាស់ផ្ទះពីរនាក់នោះ មានម្នាក់អត់មានពុកមាត់ទេ មានដោះយារចុះ មានសក់បួងហើយ ចោះត្រចៀក ម្នាក់នោះ គេទិញមកដោយទ្រព្យដ៏ច្រើន តាំងពីមកដល់ តែងពោលពាក្យចាក់ដោតដល់ជនទាំងឡាយអ្នកនៅក្នុងផ្ទះនោះ ។

កាលដែលព្រះបរមសាស្ដា ទ្រង់គង់ប្រថាប់នៅនាមហាវិហារព្រះជេតពន មានភិក្ខុមួយអង្គលោកចង់សឹក ព្រោះអំណាចនៃកិលេស ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ ធម្មតាកិលេស សូម្បីពួកសត្វតិរច្ឆាន

ក្នុងកាលមុនក៏គង់តិះដៀលដែរ ចំណែកលោកបួសក្នុងព្រះសាសនាដូចនេះហើយ ហេតុដូចម្ដេចបានជាលុះក្នុងអំណាចកិលេស ចង់សឹកដូច្នេះទៅវិញ ។ កាលដែលពួកភិក្ខុអារាធនាហើយ ទើបទ្រង់ត្រាស់សម្ដែងនូវព្រះជាតកនោះ ។

នៅក្នុងអតីតកាល គ្រាដែលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី កាលនោះ ព្រះ-ពោធិសត្វកើតជាពានរក្នុងដែនដីនៃព្រៃហិមពាន្ត ។ ពានរពោធិសត្វត្រូវបានព្រានព្រៃចាប់មកថ្វាយព្រះរាជា ។ គ្រាកាលដែលនៅក្នុងព្រះរាជវាំងយូរទៅ ព្រះពោធិសត្វបានក្លាយជាសត្វមានរបៀបរៀបរយ ចេះដឹងនូវកិរិយាប្រព្រឹត្តដ៏ច្រើនរបស់ពួកមនុស្ស ធ្វើឱ្យព្រះរាជាជ្រះថ្លាក្នុងចរិយាវត្តរបស់ពានរពោធិសត្វនោះឯង ។ ព្រះរាជាមានព្រះហឫទ័យអនុគ្រោះ បានត្រាស់បង្គាប់ឱ្យព្រានព្រៃនាំព្រះពោធិសត្វ យកទៅលែងនៅកន្លែងដែលចាប់មក ។ ហ្វូងពានរ ដឹងថាព្រះពោធិសត្វមកវិញ ក៏នាំគ្នារីករាយ

សប្បាយ បានប្រជុំគ្នានៅលើផែនថ្មដ៏ធំមួយ សួរព្រះ-ពោធិសត្វថា បពិត្រមហាពានរ តើមហាពានរទៅនៅឯណា យូរម្ល៉េះ ?

ព្រះពោធិសត្វ : យើងទៅរស់នៅឯព្រះរាជ-និវេសន៍ ក្នុងនគរពារាណសី ណ៎ាសម្លាញ់ទាំងឡាយ ។

ហ្វូងពានរ : បើដូច្នោះ មហាពានររួចផុតមកបានដូចម្ដេច ?

ព្រះពោធិសត្វ : ព្រះរាជាធ្វើយើងឱ្យជាស្វាសម្រាប់លលេង ហើយទ្រង់ក៏បានជ្រះថ្លានឹងចរិយាវត្តរបស់យើង ទើបទ្រង់ឱ្យគេនាំយើងមកវិញ ។

ហ្វូងពានរ : តើកិរិយាប្រព្រឹត្តរបស់ពួកមនុស្ស-លោកយ៉ាងណាដែរ មហាពានរប្រាប់ពួកយើងមក ពួកយើងចង់ស្ដាប់ ចង់ដឹង ។

ព្រះពោធិសត្វ : ពួកអ្នកកុំសួរអំពីការប្រព្រឹត្តរបស់មនុស្សទាំងឡាយឡើយ ។

ហ្វូងពានរ : ប្រាប់មកចុះ ពួកយើងស្ដាប់ ។

ព្រះពោធិសត្វ ៖ ពួកមនុស្សទាំងនោះ មិនថាក្សត្រ មិនថាព្រាហ្មណ៍ សុទ្ធតែពោលថា របស់យើង របស់យើង រមែងមិនដឹងដល់ភាពមិនទៀងទាត់ ។ រួចហើយព្រះពោធិសត្វ បានពោលគាថា ដែលមានសេចក្ដីខាងដើមស្រាប់ ។ ពានរពោធិសត្វ បានតិះដៀលពួកមនុស្សថា ពួកមនុស្ស មិនសមគួរយ៉ាងពិតប្រាកដ ដោយប្រការដូច្នេះឯង ។

ហ្វូងពានរទាំងអស់ បានស្ដាប់ហើយ បានយកដៃទាំងពីរបិទត្រចៀកយ៉ាងណែន ពោលថា មហាពានរកុំពោលទៀតឡើយ ពួកយើងស្ដាប់អ្វីដែលមិនគួរស្ដាប់ ។ ពួកពានរ បាននាំគ្នាចេញពីទីប្រជុំនោះ ទៅកាន់ទីដទៃមិននៅឱ្យឃើញកន្លែង ដែលប្រជុំគ្នាស្ដាប់រឿងរបស់ពួកមនុស្សឡើយ ។

ព្រះបរមសាស្ដា ទ្រង់នាំព្រះធម៌ទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចធម៌ ប្រជុំជាតក ។ កាលចប់សច្ចធម៌ ភិក្ខុដែលប្រាថ្នាសឹកចាកផ្នួសព្រោះកិលេសនោះ

បានតាំងនៅក្នុងសោតាបត្តិផល ។ ហ្វូងពានរក្នុងកាល នោះ បានមកជាពុទ្ធបរិស័ទក្នុងគ្រានេះ ចំណែកស្តេច ពានរពោធិសត្វ គឺជា **តថាគត** ។

ព្រះអដ្ឋកថាគាថាទី ១ របស់ស្តេចពានរ គឺ

**ហិរញ្ញំ មេ សុវណ្ណំ មេ ឯសា រត្តិន្ទិវា គាថា**
**ទុម្មេធានំ មនុស្សានំ អរិយធម្មំ អបស្សតំ ។**

បណ្តាបទទាំងនោះ បទថា **ហិរញ្ញំ មេ សុវណ្ណំ មេ** នេះគ្រាន់តែជាប្រធាននៃទេសនា ដោយបទទាំងពីរ នេះ គឺ ស៊ីសេចក្តីរួមទាំងរតនៈដប់ប្រការ រួមទាំង បុព្វន្នជាតិ អបរន្នជាតិ ស្រែចម្ការច្បារដំណាំ សត្វ ជើងពីរ ជើង ៤ គ្រប់យ៉ាង ហើយហៅថា នេះជារបស់ យើង នោះក៏ជារបស់យើងដែរ ។

បទថា **ឯសា រត្តិន្ទិវា គាថា** ដោយសេចក្តីថា ពួកមនុស្សនិយាយគ្នាជានិច្ច ទាំងយប់ទាំងថ្ងៃថា នេះ របស់យើង នោះរបស់យើង ដោយមិនបានដឹងតាមពិត

ថា បញ្ចក្ខន្ធមិនទៀង មានហើយត្រឡប់ទៅជាមិនមានវិញ ដូច្នេះឡើយ ។

បទថា **ទុម្មេធានំ** គឺខ្សោយបញ្ញា ឬអត់បញ្ញា ពោលគឺល្ងង់ ។

បទថា **អរិយធម្មំ អបស្សតំ** ដោយសេចក្តីថា មិនឃើញធម៌របស់ព្រះអរិយបុគ្គល មានព្រះសម្មាសម្ពុទ្ធជាដើម ឬព្រះនព្វលោកុត្តរធម៌ដ៏ប្រសើរ ប្រាសចាកទោស គឺគេមិននិយាយយ៉ាងនេះថា របស់ណាមិនទៀង របស់នោះជាទុក្ខ ដូច្នេះឡើយ ។

## អ្វីដែលទៀងពិតប្រាកដគឺការមិនទៀង

ក្នុងជរាសូត្រ បិដកលេខ ៥៤ ទំព័រ ២៧៥ ព្រះអង្គទ្រង់ត្រាស់ថា

**សោចន្តិ ជនា មមាយិតេ   ន ហិ សន្តិ និច្ចា បរិគ្គហា**

**វិនាភាវសន្តមេវិទំ   ឥតិ ទិស្វា នាគារមាវសេ។**

ជនទាំងឡាយតែងសោយសោក ព្រោះវត្ថុដែល

ប្រកាន់ថា ជារបស់យើង វត្ថុដែលប្រកាន់ជារបស់ទៀង-ទាត់មិនមានឡើយ ជីវិតនេះ មានការព្រាត់ប្រាសចាករបស់ដែលមានជាធម្មតា អ្នកប្រាជ្ញលុះឃើញដូច្នេះហើយរមែងមិននៅគ្រប់គ្រងផ្ទះឡើយ ។

## គំនិតយល់ដឹង

១. នៅពេលបរិភោគអាហារ គឺអាហារមានរសជាតិផ្សេងៗ សន្ធឹកសន្ធាប់ច្រើនមុខ ប៉ុន្តែទីបំផុតចុងក្រោយ គឺត្រូវការទឹកសាបសុទ្ធ លាងមាត់លាងក ។

រឿងទឹកសាបសុទ្ធនេះ ជាឧទាហរណ៍ដ៏ល្អក្នុងជីវិត សម្រាប់ដាស់តឿនខ្លួនឯង ។ ទឹកសាបសុទ្ធ គឺជាទឹកធម្មតាដែលជីវិតត្រូវការរាល់ថ្ងៃ ទោះបីមានទឹកភេសជ្ជៈអ្វីៗ ថ្លៃពិសេសយ៉ាងណា ក៏មិនអាចអត់ទឹកសាបបានដែរ ។ ទឹកសាបធម្មតា មិនមានតម្លៃអ្វីឱ្យលំបាករកទិញទៅនោះទេ ទឹកទន្លេស្ទឹងបឹងបួ អណ្តូងស្រះ ឬជីកបុកយកពីក្នុងដីមកក៏បាន ។

ជីវិតមនុស្សយើង មិនបានត្រូវការអ្វីឱ្យសន្ធឹកសន្ធាប់ សម្បូណ៌បែបទៅនោះឡើយ គឺវាអាចរស់បានណាស់ទៅហើយ គ្រាន់តែពឹងពាក់អាស្រ័យរបស់ធម្មតាៗ មិនចាំបាច់ត្រូវការរបស់ពិសេស របស់ថ្លៃៗច្រើនៗទេ ។

តាមពិត មនុស្សយើងលំបាកលំបិន ស្ទើរស្លាប់ស្ទើររស់ ព្រោះតែផ្គាប់កិលេសខ្លួនឯង រឹតតែផ្គាប់កិលេសតណ្ហារឹតតែខ្លាំង ។

មនុស្សយើងគួរតែហ្វឹកហាត់កាត់បន្ថយ នាំខ្លួនឯងមករស់នៅជាមួយនឹងអ្វីដែលងាយៗ ស្រួលៗ យ៉ាងសាមញ្ញធម្មតា ពោលគឺ បរិភោគធម្មតា ស្លៀកពាក់ធម្មតា ទាំងដែលជាមនុស្សធម្មតា មិនប្រកាន់ខ្លួន កំណត់ត្រឹមតែថា បានរស់ហើយ សន្សំសេចក្តីល្អតែប៉ុណ្ណោះ ។

កេរ្តិ៍ឈ្មោះ ជាយីហោគឺគ្រឿងសម្គាល់សម្រាប់រស់នៅក្នុងសង្គម ប៉ុន្តែត្រឹមតែល្មមសមរម្យធម្មតា ក៏អាចរស់បានហើយ កុំឱ្យលំបាកជាមួយនឹងឈ្មោះនាមដែលគ្រាន់តែជាបញ្ញត្តិ ព្រោះអ្វីដែលជាសារៈនៃជីវិត គឺការ

ប្រព្រឹត្តធម៌ដ៏ប្រសើរ ។

២. មានឧទាហរណ៍មួយទៀត ដែលគួរលើកមក ដើម្បីយល់ដឹងក្នុងរឿងជីវិតនេះ ដូចជារូបកាយមនុស្ស យើងមិនមានក្លិនក្រអូបអ្វីទៅនោះទេ ប៉ុន្តែគ្រាន់តែយក ទឹកអប់មកបាញ់ដាក់ ឬយកម្សៅក្រអូបមកលាប ក៏អាច បញ្ឆោតគ្នាបានថា រូបកាយខ្លួនប្រាណមានក្លិនក្រអូប គួរ ឱ្យត្រេកអរទៅហើយ ។ នេះជាឧទាហរណ៍ដើម្បីឱ្យងាយ យល់ដល់គ្រឿងលាបរបស់លោកនេះ រឿងលាភយស កេរ្តិ៍ឈ្មោះសេចក្តីសរសើរ ឋានៈ បុណ្យស័ក្តិ សុខ សោមនស្សជាដើមនេះ សុទ្ធតែជាគ្រឿងលាបលោក ឬ ជាសំបកក្រៅដែលមិនមែនជាខ្លឹម ។

តាមពិត សង្ខារលោកសុទ្ធតែមិនទៀង របស់ ដែលមិនទៀងគឺជាទុក្ខជាទោស ។ ចំពោះមនុស្សយើង ម្នាក់ៗ មានអ្វីក្រៅអំពីខន្ធ ៥ ទៅទៀត ហើយមានខន្ធ មួយណាដែលថាជាសុខនោះ សុទ្ធតែមិនទៀងជាទុក្ខ ទាំងអស់ ដូចជារូបកាយដែលតែងតែមានក្លិនស្អុយអ៊ីចឹង

ប៉ុន្តែសត្វលោកយើងដែលល្ងង់ខ្លៅ វង្វេងវង្វេងជាមួយនឹងគ្រឿងលាបខាងក្រៅ ច្រឡំថាលោកនេះជាសុខ គួរឱ្យត្រេកអរសប្បាយរីករាយណាស់ ។

មនុស្សតាក់តែងរាងកាយបានស្អាត ដោយសារគ្រឿងស្លៀកពាក់ សំពត់អាវជាដើម ប៉ុន្តែមិនបានមួយថ្ងៃផងសម្លៀកបំពាក់ត្រូវប្រឡាក់មានក្លិនស្អុយដោយសារតែរូបកាយ យ៉ាងណា សុខសោមនស្សជាអានិសង្សរបស់ខន្ធ ៥ ក៏យ៉ាងនោះដែរ ដូចគ្រឿងស្លៀកដណ្តប់ខាងក្រៅកាយអ៊ីចឹង មិនយូរឡើយ ត្រូវប្រឡាក់ដោយអនិច្ចតាធម៌ក្លាយទៅជាវិបរិណាមទុក្ខ រកសុខជាទីពឹងពិតប្រាកដមិនមានឡើយ ។

បុគ្គលល្ងង់ខ្លៅ ត្រូវបានចាប់ចងឱ្យនៅទុក្ខលំបាកក្នុងពន្ធនាគារ គឺភព ចំណែកបុគ្គលដែលមានបញ្ញាកំណត់ដឹងទុក្ខទោសរបស់សង្ខារ **សិក្ខេ និព្វានមគ្គនោ** សិក្សានូវព្រះនិព្វានដើម្បីខ្លួន ពោលគឺរំលត់កិលេសខ្លួនឯង ដូចអ្នកដើរចេញពីគុក ឆ្ពោះមុខទៅផ្ទះរបស់ខ្លួន

ដោយមិនអាល័យដំណេក ឬបាយក្នុងគុកឡើយ ។

ការជាប់ជំពាក់នឹងគ្រឿងលាបដែលជាសំបក ធ្វើឱ្យមិនដឹងថាអ្វីគឺជាខ្លឹម ពោលគឺការមិនដឹងនូវសច្ចធម៌ ព្រោះតែវង្វេងជាមួយនឹងភាពមាយានៃលោកធម៌ ច្រឡំគ្រឿងកាឡៃថាជារបស់ពិត ។

សច្ចធម៌គឺជាធម៌ពិត មិនចាំបាច់អ្នកណាៗមកតែងតាំង មកតាក់តែងដាក់ពិន្ទុឱ្យខ្ពស់ឱ្យទាបអ្វីនោះឡើយ គឺសច្ចធម៌រមែងជាសច្ចធម៌ខ្លួនឯង អ្នកណាដឹងក៏ដោយ មិនដឹងក៏ដោយ ទទួលស្គាល់ក៏ដោយ មិនទទួលស្គាល់ក៏ដោយ សច្ចធម៌មិនលម្អៀងទៅរកអ្នកណាឡើយ។

រួមគំនិតយល់ដឹងទាំងពីរបែបខាងលើនេះមក គឺសិក្សាការពិត រស់នៅជាមួយនឹងជីវិតខ្លួនឯង ដោយសតិថ្នាក់សតិប្បដ្ឋាន មិនវង្វេងជាមួយនឹងគ្រឿងលាបជាសំបកនៃជីវិត មិនចាញ់បោកកលមាយានៃរបស់កាឡៃ ព្រោះបានឃើញសច្ចធម៌នៃជីវិត ។

# ៩. បលាយិជាតក

( បិដកលេខ ៥៨, ទំព័រ ១២០ )

ព្រះបាទព្រហ្មទត្ត ទ្រង់ត្រាស់ថា ក្រុងតក្កសិលា យើងឡោមព័ទ្ធជុំវិញហើយ ដោយពពកគឺពលដំរីដែលស្រែកសម្ការដ៏ប្រសើរ ដោយកម្រងផ្កាគឺពលសេះដ៏ប្រសើរ ដោយរលកទឹកគឺពលរថ ដោយភ្លៀងខ្លាំងគឺកូនសរ ដែលខ្មាន់ធ្នូជាអ្នកលបចាំប្រហារដ៏មាំទាំ ។

អ្នកទាំងឡាយ ចូរស្ទុះទៅ ចូរលោតផ្លោះទៅ និងចូរស្រែកសន្ធាប់ មួយអន្លើដោយពលដំរីទាំងឡាយដែលមានសំឡេងគឹកកង ប្រាកដដូចជាសំឡេងនៃរន្ទះ ចូរប្រព្រឹត្តទៅក្នុងថ្ងៃនេះ ឱ្យដូចជាផ្លេកបន្ទោរដែលលេចចេញអំពីមេឃងងឹត ព្រមដោយផ្គរគ្រហឹម ។

ព្រះបរមសាស្តា ទ្រង់គង់ប្រថាប់នៅនាមហាវិហារព្រះជេតពន ព្រះអង្គប្រារព្ធបរិព្វាជកម្នាក់ឈ្មោះ

បលាយិ ។

បរិព្វាជកនោះ ដើរទៅក្នុងជម្ពូទ្វីបដើម្បីលើកវាទៈ គឺសួរប្រស្នាជ្រៅៗតាមវាទៈរបស់ខ្លួន ដោយមិនបាន ទទួលការឆ្លើយតបអំពីអ្នកណាឡើយ រហូតដល់ក្រុង សាវត្ថីតាមលំដាប់ ។ បរិព្វាជក បានសួរពួកមនុស្សក្នុង ក្រុងថា អ្នកណាៗ អាចឆ្លើយឆ្លងវាទៈជាមួយនឹងយើង បានដែរទេ ? ពួកមនុស្សបាននាំគ្នាសរសើរព្រះពុទ្ធអង្គ ថា ព្រះមហាគោតមជាព្រះសព្វញ្ញូ ទ្រង់ប្រសើរលើស ជាងពួកសត្វជើងពីរ ទ្រង់ជាធំដោយធម៌ ញាំញីវាទៈអ្នក ដទៃ ព្រះអង្គពិតជាអាចឆ្លើយតបវាទៈជាមួយនឹងមនុស្ស ដូចជាអ្នក សូម្បីរាប់ពាន់នាក់បាន ។ អ្នកប្រាជ្ញដែលមាន វាទៈជំទាស់ កើតឡើងក្នុងជម្ពូទ្វីប អ្នកប្រាជ្ញទាំងអស់ នោះ មិនអាចមកប្រព្រឹត្តកន្លងចំពោះព្រះដ៏មានព្រះភាគ បានឡើយ គឺបណ្តាវាទៈទាំងពួងមកដល់បាទមូលរបស់ ព្រះពុទ្ធអង្គហើយ ក៏ទៅជាពុកផុយ ចាលចាញ់ដូចជា រលកសមុទ្ទមកផ្ទប់នឹងច្រាំងដូច្នោះឯង ។

បរិព្វាជកសួរថា ឥឡូវនេះ ព្រះអង្គគង់ប្រថាប់នៅក្នុងទីណា ? កាលដែលបានស្តាប់ថា ព្រះអង្គទ្រង់គង់ប្រថាប់នៅនាព្រះជេតពនមហាវិហារ ក៏បានពោលថា យើងនឹងទៅលើកវាទៈជាមួយនឹងព្រះអង្គក្នុងកាលឥឡូវនេះ ។ បរិព្វាជក ចោមរោមដោយមហាជន ទៅកាន់ព្រះជេតពនមហាវិហារ គ្រាន់តែឃើញខ្លោងទ្វារដែលព្រះរាជកុមារព្រះនាមថា ជេតៈ ទ្រង់លះបង់ទ្រព្យ ៩ កោដិ ដើម្បីសាងនូវខ្លោងទ្វារនេះ ក៏បានសួរថា នេះគឺប្រាសាទដែលជាទីគង់ប្រថាប់នៃព្រះសមណគោតមឬ ? កាលដែលបានស្តាប់ថា នេះគឺជាខ្លោងទ្វារចូលទៅកាន់មហាវិហារ ទើបសួរបន្តថា គ្រាន់តែខ្លោងទ្វារអស្ចារ្យយ៉ាងនេះទៅហើយ ចុះកន្លែងព្រះអង្គគង់ប្រថាប់នោះយ៉ាងម៉េចទៅ ? មហាជនប្រាប់ថា ព្រះគន្ធកុដិដែលព្រះអង្គគង់ប្រថាប់ប្រមាណមិនត្រូវឡើយ ។ បរិព្វាជកពោលថា អ្នកណានឹងអាចឆ្លើយឆ្លងវាទៈជាមួយនឹងព្រះ-សមណគោតមដែលមានសភាពបែបនេះបាន រួចហើយ

ក៏គេចចេញអំពីទីនោះទៅ ។

កាលដែលឧបាសកឧបាសិកាទាំងឡាយ ក្រាបទូលរឿងនោះដល់ព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអ្នកទាំងឡាយ បរិព្វាជកនេះ ឃើញខ្លោងទ្វាររបស់តថាគតហើយគេចចេញទៅ មិនមែនទើបតែពេលនេះទេ សូម្បីក្នុងកាលមុនក៏គេចទៅដូចគ្នាដែរ ។ ពួកឧបាសកឧបាសិកាបានអារាធនា ព្រះអង្គទើបទ្រង់ត្រាស់សម្តែង ។

ក្នុងអតីតកាល ព្រះបរមពោធិសត្វសោយរាជ្យ-សម្បត្តិក្នុងក្រុងតក្កសិលាដែនគន្ធារៈ ។ ព្រះបាទព្រហ្មទត្តសោយរាជ្យសម្បត្តិក្នុងក្រុងពារាណសីដែនកាសី ។ ព្រះ-បាទព្រហ្មទត្តទ្រង់ព្រះតម្រិះថា យើងនឹងវាយយកក្រុងតក្កសិលា ហើយបានលើកចតុរង្គសេនាទៅព័ទ្ធក្រុង ត្រាស់បញ្ជាឱ្យរៀបក្បួនទ័ពសេះ ទ័ពរថ និង ទ័ពថ្មើរជើង ព្រមទាំងត្រូវប្រើអាវុធយ៉ាងនេះៗ ដោយត្រាស់នូវគាថាដែលមានសេចក្តីដូចខាងដើមស្រាប់ ។

ព្រះបាទព្រហ្មទត្ត ទ្រង់ត្រួតពល ក្រើនឱ្យកងទ័ព

មានសេចក្តីក្លាហាន ដូច្នេះហើយ បានវិលទ័ពទៅដល់ទ្វារក្រុង ។ ទ្រង់ទតឃើញខ្លោងទ្វារហើយ ត្រាស់សួរថា នេះគឺជាព្រះរាជមណ្ឌលឬ ? ពួករាជបុរសក្រាបទូលថា នេះគឺខ្លោងទ្វារព្រះនគរ ។ ត្រាស់សួរបន្តថា គ្រាន់តែខ្លោងទ្វារប៉ុណ្ណឹងហើយ ចុះព្រះរាជមណ្ឌលប៉ុនណាទៅ ? ពួករាជបុរសក្រាបទូលថា បានស្តាប់មកថា ដូចជាវេជយន្តប្រាសាទរបស់ព្រះឥន្ទអ៊ីចឹងព្រះអង្គ ។ ព្រះរាជាទ្រង់ត្រាស់ថា យើងមិនអាចច្បាំងជាមួយនឹងព្រះរាជាដែលដល់ព្រមដោយយសយ៉ាងនេះបានឡើយ ។ ស្តេចទតព្រះនេត្រមើលខ្លោងទ្វារហើយ ក៏លើកទ័ពត្រឡប់ចូលព្រះនគរពារាណសីវិញ ។

ព្រះបរមសាស្តា ទ្រង់នាំយកព្រះធម៌ទេសនានេះមកហើយ ទ្រង់ប្រជុំជាតក ។ ព្រះបាទក្រុងពារាណសីក្នុងកាលនោះ បានមកជាបលាយិបរិព្វាជកក្នុងគ្រានេះ ចំណែកព្រះរាជានគរតក្កសិលា គឺ **តថាគត** ។

## ចិត្តចង្អៀតនាំឱ្យសម្បូណ៌បញ្ហា

នៅក្នុងកលហវិវាទសូត្រ បិដកលេខ ៥៤ ទំព័រ ២៩០ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា

**បិយប្បហូតា កលហា វិវាទា**
**បរិទេវសោកា សហមច្ឆរា ច**
**មានាតិមានា សហបេសុណា ច**
**មច្ឆេរយុត្តា កលហា វិវាទា**
**វិវាទជាតេសុ ច បេសុណានិ ។**

ការឈ្លោះប្រកែកទាស់ទែងគ្នា សេចក្ដីសោក សេចក្ដីខ្សឹកខ្សួល និង សេចក្ដីកំណាញ់ ព្រមទាំងការប្រកាន់ ការមើលងាយ ការញុះញង់ ទាំងអស់នេះកើតមកអំពីរបស់ជាទីស្រឡាញ់ ។ កិលេសធម៌ មានការឈ្លោះប្រកែកទាស់ទែងគ្នានេះ រមែងប្រកបក្នុងសេចក្ដីកំណាញ់ (មិនមែនមានតែរបស់ជាទីស្រឡាញ់ដែលជាហេតុនោះទេ សេចក្ដីកំណាញ់ក៏ជាហេតុនៃការឈ្លោះ

ប្រកែកទាស់ទែងគ្នានេះដែរ ។) កាលបើវិវាទកើតឡើងហើយ ពាក្យញុះញង់ចាក់ដោតក៏កើតមានដែរ ។

## គំនិតយល់ដឹង

បើអប់រំចិត្តឱ្យបានទូលាយ បញ្ហាទាំងឡាយនឹងដោះស្រាយបាន ។

បញ្ហាឈ្លោះប្រកែកទាស់ទែង កើតមកអំពីសេចក្ដីកំណាញ់ ៥ យ៉ាង ណាមួយ មានកំណាញ់ទ្រព្យសម្បត្តិជាដើម ។ សេចក្ដីកំណាញ់ កើតមកអំពីការស្រឡាញ់និងការស្អប់ គឺស្រឡាញ់របស់ទ្រព្យ ស្អប់អ្នកសូម ។ បើពោលតាមព្រះអភិធម្ម សេចក្ដីកំណាញ់កើតជាមួយនឹងទោសមូលចិត្ត មានលោភៈជាឧបនិស្សយប្បច្ច័យ ។

ចិត្តកំណាញ់ គឺជាចិត្តចង្អៀតចង្អល់មួយបែបដែលជាគូជាមួយនឹងឥស្សាការច្រណែន ។ សេចក្ដីកំណាញ់និងការច្រណែន បានសាងបញ្ហាសន្ធឹកសន្ធាប់ក្នុងជីវិតប្រចាំថ្ងៃ ដូចជាការចាំចាប់កំហុសអ្នកដទៃ ពាក្យសម្ដីមិន

ពីរោះជាដើម ដែលនាំទៅដល់ការឈ្លោះវិវាទ ទាស់ទែង ពាក្យសម្ដី ប្រមូលបក្សពួក ហើយធ្វើការញុះញង់ចាក់ដោតដោយលំពែងគឺមាត់ ។ ទាំងអស់នេះ គ្មានអ្វីក្រៅអំពីការដែលមិនបានត្រាស់ដឹងនូវសច្ចធម៌ហ្នឹងឯង ។

គួរហ្វឹកហាត់អប់រំចិត្ត ឱ្យចេះធ្វើទាន មានសីលល្អ មានមេត្តាករុណាជាដើម រហូតដល់មានបញ្ញាកំណត់ដឹងធម៌ទាំងឡាយដែលពិតទៅតាមបច្ច័យ ក្នុងជីវិតប្រចាំថ្ងៃ មានអ្វីដែលមិនមែនជាធម៌ពិតនោះ ។ កាលណាអប់រំចិត្តឱ្យឋិតនៅក្នុងកុសលធម៌ទាំងពួង ចិត្តក៏បានទូលាយរីករាយនឹងអំពើរបស់ខ្លួន ដឹងខ្លួនថាមានទីពឹងក្នុងជីវិត មិនគិតច្រណែននឹងអ្នកណាៗឡើយ ។

ការគិតតែពីខ្លួនឯង ព្រោះវង្វេងក្នុងបញ្ចក្ខន្ធ ហើយប្រកាន់ថាជាតួខ្លួន នាំឱ្យមានចិត្តចង្អៀតចង្អល់ដ៏ក្រៃលែង ម៉្លោះហើយ បញ្ហាផ្សេងៗក៏កើតមាន រឿងដែលត្រូវដោះស្រាយឱ្យស្រួលបាន ទៅជាទាល់ច្រក ។

សតិប្បដ្ឋាន ៤ គឺជាខ្លោងទ្វារចូលទៅកាន់អមត-

មហានគរ ។ ខ្មាំងសត្រូវគឺកិលេសមិនអាចចូលក្នុងមហានគរគឺព្រះនិព្វានបានឡើយ គ្រាន់តែមកដល់ខ្លោងទ្វារគឺសតិប្បដ្ឋានក៏ត្រូវចាលចាញ់រត់ខ្វាត់ខ្វាត់បាត់អស់ ។ ផ្លូវដែលចូលពីខ្លោងទ្វារមកនោះ គឺអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ ជាផ្លូវដ៏បរិសុទ្ធ ជាផ្លូវរបស់ព្រះអរិយបុគ្គលតែប៉ុណ្ណោះ ។

សតិប្បដ្ឋាន ៤ គឺសតិរលឹកបានដោយប្រពៃចំពោះកាយ វេទនា ចិត្ត ធម៌ ។ កាយ វេទនា ចិត្ត ធម៌ ទាំង ៤ ផ្នែកនេះ រមែងមានក្នុងជីវិតរាល់ថ្ងៃ គ្រប់អង្គនិងគ្រប់គ្នា ។ កាលដែលសតិរលឹកបាន គ្រាន់តែជាកាយ គ្រាន់តែជាវេទនា គ្រាន់តែជាចិត្ត គ្រាន់តែជាធម៌ តាមសេចក្ដីពិត រលត់សេចក្ដីប្រកាន់ថាជាសត្វបុគ្គលតួខ្លួន នេះគឺជាខ្លោងទ្វារដ៏ធំមហិមា ត្រូវបានសាងដោយបញ្ញាថ្នាក់ស្ដាប់យល់នូវព្រះធម៌ដែលព្រះពុទ្ធបរមគ្រូទ្រង់ត្រាស់សម្ដែង ។

សតិប្បដ្ឋាន ៤ មិនមែនជាការរៀបចំនូវបញ្ហៈណាមួយក្នុងពួកកាយ ក្នុងពួកវេទនា ក្នុងពួកចិត្ត និង ក្នុងពួក

ធម៌ ដើម្បីឱ្យសតិរលឹកដឹងនោះឡើយ ពោលគឺអត់មានគំនិតជាតួខ្លួនយើងឱ្យសតិរលឹកនោះទេ ។ បច្ច័យនៃសតិគឺជាការយល់ត្រូវចំពោះជីវិតប្រចាំថ្ងៃ សុទ្ធតែជាតួធម៌ស្រេចទៅហើយ អត់មានគំនិតថា យើងត្រូវបានធម៌អ្វីនោះឡើយ មានតែការឃើញធម៌ដែលកំពុងប្រាកដជាក់-ស្តែង ហើយអស់ការខ្វាយខ្វល់នឹងខ្លួនឯង ។

បើយើងគិតថា យើងទៅធ្វើធម៌ តើធ្វើធម៌អ្វី ? ធ្វើដើម្បីអ្វី ? អ្នកណាជាអ្នកបាន ? ធ្វើបានពិតមែនឬ ?

តាមពិត គំនិតដែលគិតថា យើងទៅធ្វើធម៌ គ្មានអ្វីក្រៅអំពីការដែលមិនបានដឹងនូវកាយ វេទនា ចិត្ត ធម៌ក្នុងជីវិតប្រក្រតីនេះឡើយ ហើយសិក្សាស្តាប់យល់ច្រឡំចំពោះប្រក្រតីនៃជីវិតភិក្ខុអង្គនោះៗថា ទាល់តែធ្វើដូចជាអង្គនោះអីចឹង ទើបឈ្មោះថាបដិបត្តិធម៌ ។

ចំពោះភិក្ខុដែលបានសម្រេចមគ្គផល អង្គខ្លះនៅក្នុងព្រៃ អង្គខ្លះនៅជាមួយនឹងព្រះដ៏មានព្រះភាគ អង្គខ្លះលោតពីលើភ្នំ អង្គខ្លះយកកាំបិតប្រុងអារបំពង់ក អង្គខ្លះ

បានអារជាច់បំពង់កហើយ អង្គខ្លះកំពុងសម្តែងធម៌ និង អង្គដ៏ច្រើនទៀតកំពុងតែស្តាប់ព្រះធម៌ទេសនា ។

វិបស្សនាកើតព្រោះមានហេតុ អង្គខ្លះសម្រេចមគ្គផលពេលនៅក្នុងមាត់ខ្លា អង្គខ្លះកំពុងត្រូវលំពែង អង្គខ្លះបាក់ស្មង មានអង្គខ្លះទៀតសម្រេចពេលអស់ជីវិត ដូច្នេះ ការឃើញធម៌ គឺអាចឃើញបានគ្រប់ពេលវេលា គ្រប់ទីកន្លែង ឱ្យតែមានសតិប្បដ្ឋាន ។

ព្រោះតែប្រកាន់ធម៌ដែលកំពុងប្រាកដថា ជាតួខ្លួន ទើបបានជាវិលមួយសង្សារវដ្ត ។ ការស្វែងរករបស់ខាងក្រៅ បានប៉ុនណាៗ មិនអាចអស់វិលបានឡើយ ទាល់តែកំណត់ធម៌តាមពិត ឃើញតួធម៌ធ្វើកិច្ចគ្រប់គ្រា ទើបអស់រឿងវិលខ្វាយខ្វល់គ្រប់យ៉ាង ។

# ១០. អសិតាភុជាតក

(បិដកលេខ ៥៨, ទំព័រ ១២៥)

ព្រះនាងអសិតាភូ ពោលថា

**ត្វមេវទានិមករិ　　យំ កាមោ ព្យគមា តយិ**
**សោ យំ អប្បដិសន្ធិកោ　　ខរា ឆិន្នំវ អេណុកំ ។**

ខ្ញុំម្ចាស់ ប្រាសចាកនូវសេចក្តីស្រឡាញ់ចំពោះព្រះអង្គ ព្រោះអំពើណា ព្រះអង្គបានធ្វើនូវអំពើនោះក្នុងកាលឥឡូវនេះ សេចក្តីស្រឡាញ់នោះ មិនតជាប់វិញឡើយ ដូចជាភ្លុកដំរីដែលគេកាត់ដាច់ដោយរណារដូច្នោះឯង ។

ព្រហ្មទត្តរាជកុមារ មានព្រះបន្ទូលថា

**អត្រិច្ឆា អតិលោភេន　　អតិលោភមទេន ច**
**ឯវំ ហាយតិ អត្ថម្ហា　　អហំវ អសិតាភុយាតិ ។**

បុគ្គលមានសេចក្តីប្រាថ្នាលើសលប់ រមែងសាប-

សូន្យចាកប្រយោជន៍ ព្រោះលោភៈហួសហេតុផង ព្រោះសេចក្ដីស្រវឹងក្នុងការចង់បានហួសហេតុផង ដូចយើងនេះឯង បានសាបសូន្យចាកព្រះរាជធីតា ឈ្មោះអសិតាភូ ។

ព្រះបរមសាស្ដា កាលដែលទ្រង់គង់ប្រថាប់នៅនាមហាវិហារព្រះជេតពន ព្រះអង្គប្រារព្ធកុលធីតាម្នាក់ត្រាស់សម្ដែងនូវព្រះធម៌ទេសនានេះឯង ។

បានស្ដាប់មកថា នៅក្នុងត្រកូលឧបដ្ឋាកនៃព្រះ-អគ្គសាវ័កទាំងពីរ មានត្រកូលមួយក្នុងក្រុងសាវត្ថីមានកុមារិកាម្នាក់ ។ កុមារិកានោះ ចម្រើនវ័យ ពេញរូបពេញរាងស្អាតស្រស់ផូរផង់ ដល់ព្រមដោយលម្អដ៏លើសបានទៅកាន់ត្រកូលដែលមានជាតិស្មើគ្នា ។ ក្រោយមកស្វាមីរបស់នាង បានបាត់បង់នូវសេចក្ដីស្រឡាញ់ចំពោះនាង ហើយបានចេញទៅរកស្រីក្រៅផ្ទះ តាមការពេញចិត្តរបស់ខ្លួន។ កុលធីតាជាភរិយា នាងមិនបានយកចិត្តទុកដាក់ក្នុងរឿងដែលស្វាមីបោះបង់ខ្លួនចោលនោះឡើយ នាងបាននិមន្តព្រះអគ្គសាវ័កទាំងពីរអង្គមកថ្វាយទាន និង

ស្តាប់ធម៌ បានតាំងនៅក្នុងសោតាបត្តិផល ។ ចាប់តាំងពីនោះមក នាងបានញុំាងពេលឱ្យកន្លងទៅដោយសេចក្តីសុខក្នុងជីវិត ដែលបានសម្រេចមគ្គផលហើយនោះឯង ហើយនាងក៏បានគិតថា បើស្វាមីមិនត្រេកអរជាមួយនឹងយើងហើយ យើងក៏មិនមានកិច្ចអ្វីសម្រាប់ឃរាវាសទៀតដែរ យើងនឹងបួស ។ នាងបានជម្រាបលាមាតាបិតា ហើយចេញបួសក្នុងសម្នាក់ព្រះភិក្ខុនី ក្រោយមក ក៏បានសម្រេចព្រះអរហត្តផល អស់ខ្វល់រឿងក្នុងលោក ។

គ្រាមួយ ភិក្ខុទាំងឡាយសន្ទនាគ្នាថា ម្នាលអាវុសោទាំងឡាយ ធីតាក្នុងត្រកូលនោះ ជាស្ត្រីស្វែងរកប្រយោជន៍ ដឹងថាស្វាមីមិនត្រេកអរជាមួយខ្លួន បានស្តាប់ព្រះធម៌របស់ព្រះអគ្គសាវក័ តាំងនៅក្នុងសោតាបត្តិផល ហើយ នៅលាមាតាបិតាមកបួសទៀត រហូតទាល់តែបានសម្រេចព្រះអរហត្តផល ។ ម្នាលអាវុសោទាំងឡាយ ស្ត្រីនោះ ជាអ្នកស្វែងរកប្រយោជន៍យ៉ាងនេះឯង ។

ព្រះបរមសាស្តា ស្តេចយាងមកដល់ហើយ ទ្រង់

ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កុលធីតានោះ ជាស្ត្រីស្វែងរកប្រយោជន៍ មិនមែនត្រឹមតែពេលនេះទេ សូម្បីក្នុងកាលមុន ក៏ជាស្ត្រីស្វែងរកប្រយោជន៍ដូចគ្នាដែរ ។ កាលពួកភិក្ខុអារាធនាហើយ ព្រះអង្គទ្រង់នាំរឿងក្នុងអតីតជាតិមកត្រាស់សម្តែង ។

ក្នុងអតីតកាល គ្រាព្រះបាទព្រហ្មទត្តសោយរាជ្យ-សម្បត្តិក្នុងក្រុងពារាណសី ព្រះបរមពោធិសត្វបួសជាតាបស ញុំាងសមាបត្តិនិងអភិញ្ញាឱ្យកើតហើយ អាស្រ័យនៅនាដែនដីនៃព្រៃហិមពាន្ត ។ ក្នុងកាលនោះ ព្រះរាជាបាននិរទេសព្រះរាជបុត្ររបស់ព្រះអង្គ ឱ្យចេញអំពីដែន ព្រោះហេតុមានរឿងចង្អៀតចង្អល់ក្នុងព្រះហឫទ័យ ។ ព្រហ្មទត្តកុមារ បាននាំព្រះទេវីរបស់ព្រះអង្គព្រះនាមថា អសិតាភូ ចូលទៅកាន់ព្រៃហិមពាន្ត សោយសាច់ សោយត្រី និង ផ្លែឈើ ហើយសម្នាក់នៅនឹងបណ្ណសាលា ។ ព្រហ្មទត្តកុមារនោះ បានឃើញនាងកិន្នរីក្នុងព្រៃ ក៏មានចិត្តប្រតិព័ទ្ធ គិតថានឹងយកនាងកិន្នរីនេះជាជាយា ទើប

ទៅតាមស្នាមជើងនាងកិន្នរីនោះឯង មិនបានគិតដល់ព្រះនាងអសិតាភូឡើយ ។

ព្រះនាងអសិតាភូ ឃើញព្រហ្មទត្តកុមារតាមនាងកិន្នរីទៅដូច្នេះ ក៏គិតថា ព្រះស្វាមីតាមនាងកិន្នរីទៅដោយមិនគិតយើងឡើយ យើងនឹងត្រូវការអ្វីពីព្រហ្មទត្ត-កុមារជាស្វាមីនេះ ។ ព្រះនាងមានព្រះហឫទ័យនឿយ-ណាយ រសាយស្នេហ៍ បានចូលទៅរកព្រះបរមពោធិសត្វនមស្ការហើយសូមព្រះកម្មដ្ឋាន បានសម្លឹងកសិណញ៉ាំងសមាបត្តិ និង អភិញ្ញាឱ្យបានសម្រេចក្នុងទីនោះឯង ។ ព្រះនាងបាននមស្ការព្រះបរមពោធិសត្វ ហើយក៏ត្រឡប់មកកាន់បណ្ណសាលារបស់ខ្លួនវិញ ។ ចំណែកព្រហ្មទត្ត-កុមារ ដេញតាមនាងកិន្នរីទៅមិនបានសម្រេចតាមប្រាថ្នាឡើយ បាត់ដានមិនបានដឹងសូម្បីតែផ្លូវដែលនាងកិន្នរីនោះទៅ អស់សង្ឃឹម ទើបត្រឡប់មកបណ្ណសាលាវិញដែរ ។ ព្រះនាងអសិតាភូ ទតឃើញព្រហ្មទត្តកុមារស្ដេចត្រឡប់មកវិញ ក៏ហោះអណ្ដែតទៅក្នុងអាកាសវេហា

ឈរក្នុងអាកាសនោះឯង មានពណ៌ដូចកែវមណី ត្រាស់ថា បពិត្រព្រះរាជឱរស ខ្ញុំម្ចាស់បាននូវសេចក្ដីសុខនេះព្រោះអាស្រ័យព្រះអង្គ ហើយបានពោលគាថា ។

ក្នុងបទនៃព្រះគាថានោះ បទថា **តូមេវនាសិមករិ** ដោយសេចក្ដីថា បពិត្រព្រះអយ្យបុត្រ ព្រះអង្គហ្នឹងឯង ដែលបានលះបង់នូវខ្ញុំម្ចាស់ ហើយជាប់តាមនាងកិន្នរីទៅ គឺព្រះអង្គបានធ្វើនូវហេតុនេះក្នុងកាលឥឡូវនេះ ។

បទថា **យំ កាមោ ព្យគមា តយិ** ដោយសេចក្ដីថា គឺជាហេតុដែលធ្វើឱ្យសេចក្ដីស្រឡាញ់របស់ខ្ញុំម្ចាស់ចំពោះព្រះអង្គបានដាច់ទៅហើយ គឺលះបានដោយការគ្របសង្កត់កិលេស ។ ខ្ញុំម្ចាស់ដល់នូវភាពពិសេសយ៉ាងនេះ ក៏ព្រោះលះបង់បាននូវសេចក្ដីស្រឡាញ់ហ្នឹងឯង ។

បទថា **សោ យំ អប្បដិសន្ធិកោ** ដោយសេចក្ដីថា ការស្រឡាញ់នោះ មិនអាចត្រឡប់មកតជាប់គ្នាវិញបានឡើយ គឺមិនអាចនឹងតបានក្នុងពេលនេះ ។

បទថា **ខរា ឆិន្នំវ អរេណុគំ** ដោយសេចក្តីថា ប្រៀបដូចភ្លុកដំរីដែលត្រូវអារកាត់ដាច់ហើយ មិនអាចតឱ្យជាប់វិញបានទេ គឺមិនអាចបិទភ្ជាប់ឱ្យដូចដើមឡើយយ៉ាងណា ការដែលនឹងផ្សារភ្ជាប់ចិត្តរបស់ខ្ញុំម្ចាស់ជាមួយនឹងព្រះអង្គឱ្យជាប់ស្និទ្ធដូចមុនទៀត គឺមិនបានយ៉ាងនោះឯង ។

គ្រាកាលដែលព្រះនាងពោលគាថារួចហើយ បានហោះទៅកាន់ទីដទៃ ទាំងដែលព្រះរាជកុមារកំពុងសម្លឹងមើលដោយអាល័យនោះឯង ។ លុះព្រះនាងអសិតាភូទៅផុតហើយ ព្រហ្មទត្តកុមារក៏បានខ្សឹកខ្សួលពោលគាថាស្តីបន្ទោសឱ្យខ្លួនឯង ។

ក្នុងបទនៃព្រះគាថានោះ បទថា **អត្រិច្ឆា** ដោយសេចក្តីថា ការប្រាថ្នារកទីបំផុតមិនបាន ពោលគឺសេចក្តីប្រាថ្នាក្នុងរបស់នោះៗ ហើយស្វែងរកទាំងដែលជាការស្វែងរកដោយលោភៈហួសប្រមាណ នេះហៅថា អតិលោភៈ ។

បទថា **អតិលោភមទេន** ច បានដល់ សេចក្តីស្រវឹងដោយអតិលោភៈ គឺថា អតិលោភៈនេះឯងដែលនាំឱ្យកើតសេចក្តីស្រវឹងដល់បុរសទាំងឡាយ ហើយធ្វើឱ្យវិនាសសាបសូន្យចាកប្រយោជន៍ ដូចព្រហ្មទត្តកុមារដែលបានបាត់បង់នូវព្រះរាជធីតា ឈ្មោះអសិតាភូ ។

ព្រហ្មទត្តកុមារ សោកសៅនៅក្នុងព្រៃតែមួយព្រះអង្គឯង កាលព្រះរាជបិតាសោយព្រះទិវង្គតហើយទើបបានត្រឡប់ទៅគ្រងរាជ្យសម្បត្តិ ។

ព្រះបរមសាស្តា ទ្រង់នាំព្រះធម៌ទេសនានេះមកហើយ ទ្រង់ប្រជុំជាតក ។ ព្រះរាជបុត្រនិងព្រះរាជធីតាក្នុងកាលនោះ បានមកជាជនទាំងពីរ គឺកុលធីតានិងស្វាមីចំណែកតាបសពោធិសត្វ គឺ **តថាគត** នេះឯង ។

## ផ្លូវនៃជីវិត

ក្នុងព្រះធម្មបទ មគ្គវគ្គ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា **មគ្គានដ្ឋង្គិកោ សេដ្ឋោ** ផ្លូវមានអង្គ ៨ ប្រសើរ

ជាងផ្លូវទាំងឡាយ ។

## គំនិតយល់ដឹង

មនុស្សយើង គួរពិចារណាផ្លូវនៃជីវិតរបស់ខ្លួនឯងថា តើអាត្មាអញដើរនៅលើផ្លូវដូចម្តេច ។ ជីវិតគឺជាការដើរផ្លូវ ផ្លូវរលាក់ មិនប្រាកដថាអាក្រក់ ព្រោះជាផ្លូវត្រូវដល់ទិសដៅសុខសាន្ត តែក៏មានដែរ ផ្លូវដែលរលាក់ហើយមានគ្រោះថ្នាក់ ជាផ្លូវដែលមានភ័យ ឯចំណែកផ្លូវធំទូលាយស្អាតក៏ដូចគ្នា វាស្រេចតែទិសដៅទៅណា ។ ចូរកុំភ្លេចថា អាត្មាអញដើរផ្លូវ មិនមែនដេកផ្លូវទេ ត្រូវឱ្យប្រាកដចំពោះទិសដៅ ជាទិសដែលមិនមានភ័យ ហើយព្យាយាមដើរទៅ ត្រូវប្រយ័ត្នគ្រឿងលួងលោមតាមផ្លូវទាំងត្រូវប្រយ័ត្នវង្វេងផ្លូវទៀតផង ។

សេចក្តីចម្រើនដែលតាំងនៅលើទីតម្កល់ គឺគុណធម៌ ទើបបានយឺនយូរ ។ បើប្រាសចាកនូវគុណធម៌ជាគ្រឹះហើយ លាភយសសរសើរសុខនឹងត្រូវបាក់ស្រុតក្នុងពេល

ដ៏ឆាប់ ដូចជាសំណង់ដែលអត់មានគ្រឹះ ដូច្នោះឯង ។

បុគ្គលដែលប្រាសចាកនូវគុណធម៌ រមែងមានប្រក្រតីទម្លាយខ្លួនឯងហើយជាស្រេច ដោយមិនចាំបាច់អ្នកដទៃណាទម្លាយ ផ្តួលរំលំអ្វីនោះឡើយ ដូចជាច្រែះកើតពីដែកណា រមែងស៊ីនូវដែកនោះរហូតពុកផុយអស់អ៊ីចឹងឯង ។

កិលេសអាស្រ័យចិត្តនៃបុគ្គលណា រមែងដុតចិត្តបុគ្គលនោះ ដូចភ្លើងអាស្រ័យអុសណា ក៏រមែងដុតកម្ទេចនូវអុសនោះ យ៉ាងនោះដែរ ។

ក្នុងសមរភូមិ បើមិនបាញ់សម្លាប់សត្រូវទេ សត្រូវនឹងបាញ់សម្លាប់យើង យ៉ាងណា ក្នុងសមរភូមិនៃជីវិតនេះ បើមិនសម្លាប់សត្រូវគឺកិលេសទេ កិលេសនឹងសម្លាប់យើង ពោលគឺសម្លាប់សេចក្តីសុខចម្រើនគ្រប់យ៉ាង សម្លាប់ទាំងជីវិតព្រមទាំងរាំងផ្លូវនៃសុគតិទៀត។

កុំបង្អែបង្អង់រង់ចាំ ក្នុងការនាំយកធម៌ល្អមកបង្កបង្កើតក្នុងចិត្តឡើយ ពេលវេលាមិនមែនមានតម្លៃដោយ

ខ្លួនឯង ឯងៗស្រេចស្រាប់ទៅនោះទេ គឺទាល់តែយកពេលវេលានោះមកចម្រើនគុណ លះទោស ទើបពេលវេលាមានតម្លៃពិតប្រាកដ ដូច្នេះទើបមិនត្រូវបង្អែបង្អង់ឱ្យខាតពេល ឬទុកពេលឱ្យកិលេសមានឱកាសវាយបកនោះឡើយ ។

ដាច់ខាត កុំវង្វេងច្រឡំចិញ្ចឹមកិលេស ថាជាការទំនុកបម្រុងខ្លួននិងស្រឡាញ់ខ្លួនឱ្យសោះ ព្រោះវាគ្រោះថ្នាក់ជាងការចិញ្ចឹមពស់វែកទុកឱ្យនៅក្នុងបន្ទប់ដេក ទៅទៀត ។

កុំគិតតែពីខ្លួនឯង វង្វេងរកកាមគុណចោលប្រពន្ធកូន ។ កាមគុណមិនបានតបស្នងអ្វីទេ មានតែឱ្យទុក្ខក្តៅក្រហាយស្តាយក្រោយ ដូចបរិភោគទឹកឃ្មុំលាយដោយថ្នាំពិស ។ កើតមកជាមនុស្ស គួរតែមានការយល់ដឹងអំពីហេតុផល ហើយចេះសាងប្រយោជន៍ទុកក្នុងលោកបានសុខដល់អ្នកដទៃ ប្រៀបបីដូចផ្កាដែលមានរូបរាងពណ៌សម្បុរល្អស្អាត ទាំងក្លិនក៏ក្រអូប មនុស្សក្នុងពិភព-

លោកតែងតែចូលចិត្ត យ៉ាងនោះឯង ។ មនុស្សយើងមិនមែនមានតម្លៃដោយខ្លួនឯងតែម្តងទៅនោះទេ ទាល់តែមានប្រយោជន៍ទើបមានតម្លៃ បើរស់នៅឥតប្រយោជន៍ មានតែឱ្យទុក្ខឱ្យភ័យដល់ខ្លួនឯងនិងអ្នកដទៃ តើវាមានតម្លៃស្អីទៅ អ្នកណាគេត្រូវការ គេប្រាកដជាបោះចោល ដូចជាផ្លែឈើស្អុយអ៊ីចឹងឯង ។ មនុស្សសោះកក្រោះអត់រសជាតិ គឺជាមនុស្សដែលគិតតែពីខ្លួនឯងដោយអំណាចលោភៈហ្នឹងឯង ព្រមទាំងកេងប្រវ័ញ្ចយកចំណេញពីអ្នកដទៃទៀតផង ខ្វះការឱ្យទាន មិនមានមេត្តា ឧបមាដូចជាផ្លែក្រូចស្អក ។ មិនមានការចាញ់ក្តីណាឱ្យខ្លាំងក្លាដូចជាការចាញ់ក្តីជាមួយនឹងខ្លួនឯងនេះឡើយ ខំប្រឹងរកស៊ីហត់នឿយមួយជីវិត សន្សំទ្រព្យទុកដាក់ឱ្យខ្លួនឯង ទាំងខំកេងប្រវ័ញ្ច ទាំងខំកំណាញ់មិនធ្វើទាន ខំជួយខ្លួនឯងឱ្យបានជាអ្នកមាន ជាថៅកែ ជាសេដ្ឋី ទីបំផុតអត់មានបានអ្វី ថែមទាំងកម្មកាត់ក្តីឱ្យទៅជាប្រេតទៀតផង នេះមកពីស្រឡាញ់ខ្លួនខុសទំនង តាមពិត បើចេះស្រឡាញ់ខ្លួន

បានត្រឹមត្រូវ មានការអប់រំទូន្មានខ្លួនឱ្យបានល្អ ដូចជាការទូន្មានសេះដរី ខ្លួនហ្នឹងឯងរមែងបានជាទីពឹង ជាពាហនៈដ៏ប្រសើរ ដូចជាព្រះរាជធីតាឈ្មោះអសិតាភូសន្សំឧបនិស្ស័យជួយខ្លួនឯង រហូតបានមកជាកុលធីតាមានខ្លួនឯងជាទីពឹង ជួយខ្លួនឯងឱ្យបានដល់កោះគឺព្រះ-អរហត្តហើយបរិនិព្វាន ។

ត្រូវសិក្សាសច្ចៈដែលកំពុងប្រាកដ ដោយមិនចាំ-បាច់អាល័យអ្វីៗដែលកន្លងទៅហើយនោះទេ ។ ត្រូវចាំថា យើងមិនអាចបានអ្វីៗសុទ្ធតែត្រូវចិត្តជានិច្ចនោះឡើយ បើយើងចេះតែស្វែងរកនូវការពេញចិត្ត ការទាស់ចិត្តនឹងតាមយើងជានិច្ច ឧបាយមានតែម្យ៉ាងគត់គឺ សិក្សាសច្ចៈដែលបានមកដល់ជីវិតគ្រប់ពេលគ្រប់វេលា រហូតទាល់តែមានសេចក្ដីសុខជាមួយនឹងការពិតគ្រប់យ៉ាង ។

# ១១. មូលបរិយាយជាតក

(បិដកលេខ ៥៨, ទំព័រ ១៣៣)

**កាលោ ឃសតិ ភូតានិ សព្វានេវ សហត្តនា**
**យោ ច កាលឃសោ ភូតោ ស ភូតបចនឹ បចិ ។**

(អាចារ្យទិសាបាមោក្ខពោធិសត្វ សួរថា) ពេលវេលារមែងទំពាស៊ីនូវសព្វសត្វ ព្រមទាំងខ្លួនឯង តើសត្វណា ជាអ្នកស៊ីនូវពេលវេលានោះវិញ ទាំងដែលសត្វនោះឈ្មោះថា ដុតនូវតណ្ហា ដែលជាធម្មជាតិដុតសត្វ ?

ព្រះដ៏មានព្រះភាគទ្រង់គង់នៅសុភគវ័ន គឺជាព្រៃដែលជាទីត្រេកអរនៃពពួកជនច្រើន ក្រោមម្លប់សាលរាជព្រឹក្ស ជិតក្រុងឧក្កដ្ឋា ព្រះអង្គបានត្រាស់សម្តែងនូវមូលបរិយាយសូត្រ រួចហើយទ្រង់ត្រាស់សម្តែងនូវព្រះជាតកនេះ ។

បានស្តាប់មកថា ក្នុងកាលនោះមានព្រាហ្មណ៍

៥០០ នាក់ រៀនចប់ត្រៃវេទហើយ ចេញមកបួសក្នុងព្រះពុទ្ធសាសនា រៀនព្រះត្រៃបិដក ។ ភិក្ខុទាំង ៥០០ អង្គនោះ ជាអ្នកមានការតម្កើងខ្លួន ព្រោះគិតឃើញថា ព្រះសម្មាសម្ពុទ្ធទ្រង់ដឹងនូវព្រះត្រៃបិដក ចំណែកយើងក៏ដឹងនូវព្រះត្រៃបិដកដែរ កាលបើដូច្នេះ យើងជាមួយនឹងព្រះសម្មាសម្ពុទ្ធមានអ្វីផ្សេងគ្នា ។ ភិក្ខុទាំងនោះ មិនបានចូលគាល់ព្រះសម្មាសម្ពុទ្ធឡើយ តាំងខ្លួនជាបដិបក្ខ។

ថ្ងៃមួយ ព្រះបរមសាស្តា ទ្រង់ត្រាស់នូវមូលបរិយាយសូត្រ ប្រដាប់ដោយភូមិ ៨ ក្នុងពេលដែលភិក្ខុទាំងនោះកំពុងតែជួបជុំគ្នា (នៅក្នុងបិដកលេខ ២០ ព្រះសូត្រទី ១) ភិក្ខុទាំងនោះ កំណត់សេចក្តីអ្វីក៏មិនបាន ទើបមានសេចក្តីត្រិះរិះថា ពួកយើងលើកតម្កើងខ្លួនឯង ដោយគិតថា មិនមានអ្នកណាឆ្លាតស្មើពួកយើង ប៉ុន្តែឥឡូវនេះ ពួកយើងមិនចេះ មិនដឹងអ្វីឡើយ ឈ្មោះថាអ្នកណាៗ ឆ្លាតដូចជាព្រះសម្មាសម្ពុទ្ធ មិនមានទេ ឱ ! ព្រះពុទ្ធគុណអស្ចារ្យណាស់ ។ ចាប់តាំងពីនោះមក ពួក

ភិក្ខុទាំងនោះ អស់ការតម្កើងខ្លួន ឈប់វង្វេងខុសទៀត ដូចពស់មានពិសត្រូវគេដកចង្កូមហើយ ដូច្នោះឯង ។

កាលដែលចប់នូវមូលបរិយាយសូត្រ ព្រះបរមសាស្ដា ទ្រង់គង់ប្រថាប់នៅសុភគវ័ននោះនៅឡើយ ភិក្ខុទាំងឡាយ ប្រជុំសន្ទនាគ្នាថា អាវុសោទាំងឡាយ គួរអស្ចារ្យចំពោះពុទ្ធានុភាពណាស់ គឺព្រះអង្គបានញុំាងភិក្ខុទាំងនោះដែលមានសេចក្ដីស្រវឹង និងលើកតម្កើងខ្លួនឯងឱ្យមានការដាក់ចុះនូវសេចក្ដីស្រវឹង និងការលើកតម្កើងខ្លួនឯងនោះ ដោយមូលបរិយាយទេសនា ។

ព្រះបរមសាស្ដា ស្ដេចយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ តើអ្នកទាំងឡាយកំពុងសន្ទនាគ្នាដោយរឿងអ្វី ? កាលភិក្ខុទាំងនោះក្រាបទូលឱ្យទ្រង់ជ្រាបហើយ ទើបព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែន ទើបតែឥឡូវនេះទេ ក្នុងកាលមុនតថាគតក៏បានធ្វើឱ្យភិក្ខុទាំងនោះ ដែលធ្លាប់ជាអ្នកលើកតម្កើងខ្លួន ឱ្យអស់នូវការលើកតម្កើងខ្លួននោះទៅវិញដូចគ្នាដែរ។ កាល

ពួកភិក្ខុអារាធនា ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងនូវរឿងអតីតជាតិនោះ ។

ក្នុងអតីតកាល គ្រាដែលព្រះបាទព្រហ្មទត្តសោយ-រាជ្យសម្បត្តិក្នុងក្រុងពារាណសី ព្រះបរមពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ កាលដែលចម្រើនវ័យសម្រេចត្រៃ-វេទ ជាអាចារ្យទិសាបាមោក្ខ បង្រៀនមន្តដល់មាណព ៥០០ នាក់ ។ មាណពទាំង ៥០០ នាក់នោះ កាលដែលរៀនចេះចប់ហើយ ក៏កើតការលើកតម្កើងខ្លួន វាយឫកស្មើ មិនទៅកាន់សម្នាក់អាចារ្យ មិនធ្វើវត្តបដិបត្តិ ដោយគិតថា ពួកយើងចេះប៉ុនណា សូម្បីគ្រូអាចារ្យក៏ចេះតែប៉ុណ្ណឹងដែរ មិនមានភាពពិសេសអ្វីជាងគ្នាឡើយ ។ គ្រាមួយ កាលដែលព្រះបរមពោធិសត្វ អង្គុយនៅនឹងគល់ដើមពុទ្រា ពួកមាណពទាំងនោះ បំណងនឹងមាក់ងាយលោកគ្រូអាចារ្យរបស់ខ្លួន ទើបយកក្រចកដៃគោះដើមពុទ្រា ហើយនិយាយថា ដើមឈើនេះមិនមានខ្លឹម ។ ព្រះបរមពោធិសត្វ ក៏បានជ្រាបថា ពួកសិស្សមានការ

មាក់ងាយចំពោះគ្រូអាចារ្យដូច្នេះ ទើបពោលជាមួយនឹងពួកសិស្សទាំងនោះថា យើងនឹងសួរបញ្ហាមួយចំពោះពួកអ្នកទាំងឡាយ ។ ពួកមាណពទាំងនោះនាំគ្នាសប្បាយចិត្តពោលថា សួរមកចុះ ពួកយើងនឹងដោះស្រាយ ។ ព្រះបរមពោធិសត្វជាលោកគ្រូអាចារ្យ ក្នុងការសួរបញ្ហា បានពោលគាថាជាសំណួរដែលមានអដ្ឋកថាដូចតទៅ :

ក្នុងបទទាំងនោះ បទថា **កាលោ** បានដល់ ពេលវេលាមុនអាហារ ឬក្រោយអាហារជាដើម ។

បទថា **ឃសតិ** នេះជាឈ្មោះរបស់សត្វ ។ ពេលវេលា មិនមែនស៊ីសាច់ស៊ីឈាមរបស់សត្វ ដូចជាខ្លាស៊ីសាច់នោះទេ ប៉ុន្តែ ពេលវេលាបានញាំងអាយុ វណ្ណៈនិងពលៈជាដើមរបស់សត្វទាំងឡាយ ឱ្យអស់ទៅ បានញាំញីវ័យកំលោះក្រមុំ ធ្វើការមិនមានរោគឱ្យវិនាស បែបនេះហៅថា ស៊ីសត្វ គឺទំពាស៊ីនូវសព្វសត្វ ។ ចំពោះពេលវេលាដែលស៊ីនូវសត្វដូច្នេះ មិនវៀរនូវសត្វណាៗឡើយ រមែងទំពាស៊ីនូវសព្វសត្វ ។

មិនត្រឹមតែស៊ីសត្វទាំងឡាយប៉ុណ្ណោះទេ ពេលវេលារមែងស៊ីនូវខ្លួនឯងទៀត ដូចជាពេលមុនអាហាររមែងមិនមាននៅសល់ឡើយ ក្នុងពេលក្រោយអាហារនោះសោត ក៏មានន័យដូចគ្នា ។

ដែលថា សត្វអ្នកស៊ីនូវកាលវិញនោះ សំដៅដល់ព្រះខីណាស្រព ។ ពិតណាស់ ព្រះខីណាស្រពនោះ ហៅថាអ្នកស៊ីកាល ព្រោះញុំាងបដិសន្ធិកាលតទៅឱ្យអស់ដោយអរិយមគ្គ ។

បទថា **ស ភូតបចនឹ បចិ** ដោយសេចក្តីថា ព្រះខីណាស្រពនោះ អាស្រ័យភ្លើងគឺញាណបានធ្វើឱ្យឆេះវិនាសអស់នូវតណ្ហាដែលតែងតែដុតសត្វលោក ។

ពួកមាណពទាំងនោះ ស្តាប់នូវបញ្ហានេះហើយ មិនអាចនឹងដឹងសេចក្តីអ្វីទាំងអស់ សូម្បីតែម្នាក់។ លំដាប់នោះ ព្រះបរមពោធិសត្វ បានពោលចំពោះមាណពទាំងនោះថា ពួកអ្នកកុំយល់ថាបញ្ហានេះមាននៅក្នុងត្រៃវេទឡើយ ។ ពួកអ្នកសម្គាល់ថាអាចារ្យដឹងអ្វីណា

យើងក៏ដឹងនូវអ្វីនោះទាំងអស់ ទើបបានប្រៀបយើងទៅនឹងដើមពុទ្រា ។ ពួកអ្នកនៅអត់បានដឹងថា យើងជាអាចារ្យបានដឹងនូវអ្វីៗទៀតជាច្រើន ដែលពួកអ្នកមិនបានដឹង ។ ពួកអ្នកចូរទៅចុះ យើងឱ្យពេល ៧ ថ្ងៃ ចូរជួយគ្នាគិតបញ្ហានេះ តាមកាលកំណត់ ។

៧ ថ្ងៃកន្លងទៅ ពួកមាណពគិតអ្វីក៏មិនយល់ទាំងអស់ មិនឃើញសេចក្តីនៃពាក្យជាសុភាសិតដ៏ពីរោះក្រៃលែងនេះឡើយ ហើយក៏បានមករកលោកគ្រូអាចារ្យថ្វាយបង្គំហើយអង្គុយក្នុងទីដ៏សមគួរ ។ កាលដែលលោកគ្រូអាចារ្យសួរថា ពួកអ្នកមានមុខមាត់បានដឹងនូវបញ្ហានេះឬ ? ក៏នាំគ្នាពោលថា ពួកយើងអត់ដឹងទេ ពួកយើងនាំគ្នាគិតរកសេចក្តីអត់ឃើញឡើយ ។ ព្រះពោធិសត្វជាលោកគ្រូអាចារ្យបានពោលថា ក្បាលនរជនទាំងឡាយដ៏ច្រើន ក្បាលទាំងនោះ មានសក់ខ្មៅវែងគ្របមកដល់កបណ្តាមនុស្សទាំងឡាយនោះ នឹងរកមនុស្សដែលមានបញ្ញាស្មូម្បីតែម្នាក់ក៏មិនបានដែរ ។

ព្រះបរមពោធិសត្វ តិះដៀលពួកមាណពទាំងអស់នោះថា ពួកអ្នកជាមនុស្សល្ងង់ មានតែវន្ទត្រចៀកប៉ុណ្ណោះ មិនមានបញ្ញា រួចហើយទើបដោះស្រាយបញ្ហា ។ ពួកមាណពស្តាប់ហើយបានពោលថា ធម្មតាអាចារ្យជាបុគ្គលមានសភាពដ៏ធំ ជាបុគ្គលប្រសើរគួរឱ្យអស្ចារ្យណាស់ ។ រួចហើយ ពួកមាណពទាំងនោះក៏នាំគ្នាសូមខមាទោសចំពោះលោកគ្រូអាចារ្យ ឈប់តម្កើងខ្លួនដូចមុន ប្រណិប័តន៍លោកគ្រូអាចារ្យដូចដើម ។

ព្រះបរមសាស្តា ទ្រង់នាំព្រះធម៌ទេសនានេះមកហើយ ទ្រង់ប្រជុំជាតក ។ មាណពទាំង ៥០០ នាក់ក្នុងគ្រានោះ បានមកជាភិក្ខុទាំង ៥០០ អង្គនេះ ចំណែកលោកគ្រូអាចារ្យគឺ **តថាគត** ។

ព្រះបរមសាស្តា ទ្រង់គង់ប្រថាប់នៅសុភគវ័នជិតក្រុងឧក្កដ្ឋា តាមព្រះអធ្យាស្រ័យហើយ ស្តេចយាងទៅកាន់នគរវេសាលី ទ្រង់គង់នៅគោតមកចេតិយ ត្រាស់សម្តែងនូវគោតមកសូត្រ ។ កាលដែលព្រះអង្គទ្រង់ត្រាស់

នូវព្រះសូត្រនេះចប់ហើយ លោកធាតុទាំងពាន់កក្រើកញាប់ញ័រ ភិក្ខុទាំង ៥០០ អង្គ បានសម្រេចព្រះអរហត្តព្រមទាំងបដិសម្ភិទានៅនាគោតមកចេតិយនោះឯង ។

**សូមអនុមោទនា !**

## គោតមកសូត្រ

(បិដកលេខ ៤១, ទំព័រ ៤៣៤)

សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងគោតមកចេតិយ (ចេតិយនោះជាលំនៅរបស់យក្សឈ្មោះគោតមកៈ ។ អដ្ឋកថា ។) ជិតក្រុងវេសាលី ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតសម្ដែងធម៌ដើម្បីឱ្យចេះដឹង (**អភិញ្ញាយ**) មិនមែនដើម្បីមិនឱ្យចេះដឹងទេ ។ ម្នាលភិក្ខុ

ទាំងឡាយ តថាគតសម្តែងធម៌សមតាមហេតុ (**សនិទានំ**) មិនមែនមិនសមតាមហេតុទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតសម្តែងធម៌ប្រកបដោយសេចក្តីអស្ចារ្យ (**សប្បា-ដិហារិយំ** ) មិនមែនមិនប្រកបដោយសេចក្តីអស្ចារ្យទេ ។

ម្នាលភិក្ខុទាំងឡាយ កាលបើតថាគតនោះសម្តែងធម៌ ដើម្បីឱ្យចេះដឹង មិនមែនដើម្បីមិនឱ្យចេះដឹង សម្តែងធម៌សមតាមហេតុ មិនមែនមិនសមតាមហេតុ សម្តែងធម៌ប្រកបដោយសេចក្តីអស្ចារ្យ មិនមែនមិនប្រកបដោយសេចក្តីអស្ចារ្យ ដូច្នោះ អ្នកទាំងឡាយគួរធ្វើតាមឱវាទ គួរធ្វើតាមអនុសាសនី ។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត អ្នកទាំងឡាយ គួរត្រេកអរ គួរពេញចិត្ត គួររីករាយថា ព្រះដ៏មានព្រះភាគ ជាព្រះសម្មាសម្ពុទ្ធ ព្រះធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយដោយប្រពៃ ព្រះសង្ឃប្រតិបត្តិដោយប្រពៃ ។ លុះព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងនោះ

ក៏មានចិត្តត្រេកអរ រីករាយចំពោះភាសិតនៃព្រះដ៏មានព្រះភាគ ។

ក៏កាលដែលព្រះដ៏មានព្រះភាគ ត្រាស់សម្ដែងនូវវេយ្យាករណ៍នេះចប់ហើយ លោកធាតុទាំងពាន់ក៏កក្រើករញ្ជួយញាប់ញ័រ ។

អដ្ឋកថាពន្យល់ បទថា **អភិញ្ញាយ** ដោយសេចក្ដីថា ដឹង គឺចាក់ធ្លុះ បានដល់ធ្វើឱ្យប្រចក្សថា ធម៌ទាំងនេះ គឺខន្ធ ៥ , អាយតនៈ ១២ , ធាតុ ១៨ , ឥន្ទ្រិយ ២២ , អរិយសច្ចៈ ៤ , ហេតុ ៩ , ផស្សៈ ៧ , វេទនា ៧ , សញ្ញា ៧ , ចេតនា ៧ , ចិត្ត ៧ ។ អធិប្បាយថា ធ្វើឱ្យជាក់ច្បាស់នូវធម៌ទាំងនេះ ដោយការចម្រើននូវសតិប្បដ្ឋាន ៤ ។

បទថា **សនិទានំ** ដោយសេចក្ដីថា តថាគតសម្ដែងធម៌ព្រមទាំងបច្ច័យនោះឯង មិនមែនមិនមានបច្ច័យទេ ។

បទថា **សប្បាដិហារិយំ** ដោយសេចក្តីថា តថាគត សម្តែងធម៌មានបាដិហារ្យ គឺកម្ចាត់សត្រូវបាន មិនមែន មិនមានបាដិហារ្យនោះឡើយ ។

## គំនិតយល់ដឹង

បុគ្គលដែលជាបណ្ឌិតពិត មើលទៅហាក់ដូចជា មិនមានការចេះដឹងអ្វីឡើយ ព្រោះហេតុតែជាអ្នកសង្រួម និងមិនមែនជាអ្នកអួតអាង ប្រៀបដូចជាប៉ោតដែលពេញ ដោយទឹក គេរែកទៅមិនឮរ៉ូងរ៉ាង ។ សូម្បីបានទទួលការ ប្រមាថមើលងាយពីអ្នកដទៃក៏ដោយ បណ្ឌិតនៅតែរក្សា ប្រក្រតីនៃចិត្តស្ងប់ ព្រោះបានដឹងថា សេចក្តីល្អឬអាក្រក់ វានៅក្នុងចិត្តរបស់ខ្លួន មិនមែននៅលើការសរសើរឬ និន្ទានោះទេ ម្យ៉ាងទៀត មកអំពីបណ្ឌិតបានដឹងនូវការ ពិតក្នុងសត្វលោកទាំងឡាយ ដែលធ្វើឱ្យបណ្ឌិតមានការ ញញឹមស្រស់ស្រាយចំពោះការពិតនោះៗ ។

បណ្ឌិតទាំងឡាយ មិនបានសម្គាល់ថា ខ្លួនឯងជាបុគ្គលសំខាន់ពិសេសអ្វីទៅនោះទេ ព្រោះបានកំណត់ដឹងនូវបញ្ហាក្នុងឲ្យហើយ គ្រាន់តែថា មានពេលត្រូវសង្គ្រោះដល់អ្នកដទៃ ក៏សម្តែងឡើងនូវសមត្ថភាព ចំណេះដឹងនិង គុណធម៌ ក្នុងខ្លឹមសារគីណែនាំអប់រំ ឱ្យអ្នកដទៃបានស្គាល់ដឹ ស្គាល់ខ្យល់ជាដើមតាមពិត តែប៉ុណ្ណោះ ។

បុគ្គលល្ងង់ខ្លៅ អត់ទ្រាំមិនលើកតម្កើងខ្លួនឯងមិនបាន រ៉ូងរ៉ាងដូចប៉ោតអត់ទឹក ។ ចំណែកអ្នកមានបញ្ញាបានសាងសេចក្តីល្អដ៏ធំធេង សម្រេចប្រយោជន៍ដល់មនុស្សក្នុងពិភពលោក ទាំងដែលមិនមានបំណងទាមទារនូវការតបស្នងអ្វីឡើយ មានតែសម្តែងចេញនូវភាពទន់ភ្លន់ជាទីត្រេកអរជ្រះថ្លានៃពពួកជន ដូចជាផ្កាដែលមានពណ៌ល្អ និងរូបរាងស្អាត ព្រមទាំងមានក្លិនក្រអូប យ៉ាងនោះឯង ។

# ១២. មេត្តាត្រាប្រណី

កាលបើចិត្តមានមេត្តាត្រាប្រណី គឺបីដូចជាចិត្តបានឋិតនៅក្នុងមហាវិមានយ៉ាងហ្នឹងឯង រមែងសុខសប្បាយ មានភាពទូលំទូលាយ ប្រាសចាកការចង្អៀតចង្អល់ ។

ចិត្តទូលាយដោយមេត្តា រមែងថ្លាស្អាតដូចអន្លង់ទឹកធំជ្រៅ ឬរីកស្រស់ដូចជាផ្កាឈូករីក ធ្វើឱ្យសម្លឹងមើលលោកនេះ ដ៏ជាសុខក្នុងចិត្តដោយធម្មបីតិ ។

គ្រាន់តែចិត្តគិតឱ្យ គិតបូជាព្រះគុណប៉ុណ្ណឹង ក៏ហាក់ដូចជាបានអ្វីៗគ្រប់យ៉ាងទៅហើយ ព្រោះចិត្តមានសេចក្ដីសុខ ចាំបាច់ពោលថ្វី ចំពោះការធ្វើឱ្យសម្រេចនូវការឱ្យ ការបូជានោះៗ ។ ផ្ទុយមកវិញ គ្រាន់តែចិត្តគិតដោយអាទានតណ្ហា គឺប្រាថ្នានឹងចាប់យកមកជារបស់ខ្លួនប៉ុណ្ណឹង ក៏ធ្វើឱ្យមានសេចក្ដីដឹងខ្លួនថា ក្រវល់ក្រវាយ

មិនមានសេចក្ដីសុខទៅហើយ ។ កាលដែលមិនមានសេចក្ដីសុខ ក៏ដូចជាសាបសូន្យនូវអ្វីៗគ្រប់យ៉ាង ព្រោះថា អ្វីៗដែលកំពុងតែមាន មិនបានធ្វើឱ្យម្ចាស់មានសេចក្ដីសុខទៅបាន ។

នៅពេលមានទុក្ខក្នុងចិត្ត ត្រូវដឹងថា ព្រោះតណ្ហាជាបច្ច័យ កុំរវល់តែជ្រប់ក្នុងរឿង ហើយគិតខុសថា រឿងនោះៗ នាំឱ្យយើងកើតទុក្ខ ។ តណ្ហាវានាំឱ្យខ្វាយខ្វល់អន្ទះអន្ទែងអីចឹងឯង ហាក់ដូចជាថា បើមិនបានរបស់ហ្នឹងទេ វាត្រូវស្លាប់បាត់បង់ជីវិតអីចឹង ដល់ទៅខំប្រឹងឱ្យបានមក វាថាមិនមែនអាហ្នឹងទេ ត្រូវចោល ស្អប់ ឈ្លោះអំពល់ទុក្ខ ។ល។ ដូច្នេះ គប្បីអប់រំធម៌សន្ដោស ខន្ដីមេត្តា និង សិក្សាសច្ចធម៌ ។

# ១៣~ ដំណោះស្រាយបញ្ហា

បញ្ហាខ្វាយខ្វល់ទាំងអស់ ប្រជុំចុះនៅត្រង់ទុក្ខសច្ច ដូច្នេះ មិនមានបញ្ហាណាដែលមិនអាចដោះស្រាយបាន នោះទេ ព្រោះនៅក្នុងអរិយសច្ច ៤ យ៉ាង ទុក្ខនិរោធជា បរមត្ថមានពិតប្រាកដ ជាផលសម្រេចនៃការដោះស្រាយ បញ្ហា ។

អរិយមគ្គប្រកបដោយអង្គ ៨ ប្រការ ជាឧបាយក្នុង ការដោះស្រាយបញ្ហាយ៉ាងមានប្រសិទ្ធភាព ព្រោះអរិយ-មគ្គនេះ ជាតួកំណត់ដឹងនូវទុក្ខសច្ច ស្គាល់ទុក្ខតាមពិត ។

សត្វលោក ដែលមិនបានកំណត់ដឹងនូវទុក្ខតាមពិត ចង់ដោះស្រាយចំពោះតែទុក្ខណា ដែលកើតឡើងហើយ ព្រោះការកើតឡើងនៃបញ្ហាក្ខន្ធតែប៉ុណ្ណោះ របៀបដូច សត្វសុនខចេះតែខាំនូវដុំដី ឬដំបងដែលគេគប់គ្រវែងមក ហ្នឹងឯង មិនចេះស្ទុះទៅខាំអ្នកដែលគប់គ្រវែងមកនោះ

ឡើយ ម្ល៉ោះហើយ សត្វលោកមានតែការចម្រើនឡើងនូវតណ្ហា ក្នុងការដោះស្រាយនូវបញ្ហាបែបនេះ ។ តណ្ហាប្រាថ្នាសុខ ប្រាថ្នាស្រួល ក្នុងទុក្ខសច្ច ប្រាថ្នាកុំឱ្យចាស់ កុំឱ្យឈឺ កុំឱ្យស្លាប់ ក្នុងការដែលមានជាតិកំណើតបានកើតឡើងហើយ ។ តណ្ហាគ្រប់យ៉ាងកើតឡើង ព្រោះអវិជ្ជាដែលជាតួមិនដឹងនូវទុក្ខតាមពិតជាហេតុ ។ ទុក្ខជាសភាវៈមិនទៀង ដល់ទៅអវិជ្ជាមិនដឹងទុក្ខតាមពិត ក៏ជាហេតុ ជាឫសគល់នៃតណ្ហាប្រាថ្នារបស់ឱ្យទៀងក្នុងទុក្ខ ។ ទុក្ខជាសភាវទុក្ខពិតព្រោះមិនទៀង ដល់ទៅអវិជ្ជាមិនដឹងទុក្ខតាមពិត ក៏ជាហេតុ ជាឫសគល់នៃតណ្ហាប្រាថ្នាសុខក្នុងទុក្ខហ្នឹងឯង ។ ទុក្ខជាសភាវៈសូន្យទទេចាកតួខ្លួន ជាសង្ខតធម៌ ព្រោះថា របស់ណាជាទុក្ខ គឺរបស់នោះឯងរលត់ ដល់ទៅអវិជ្ជាមិនដឹងទុក្ខតាមពិត ក៏ជាហេតុ ជាឫសគល់នៃតណ្ហាប្រាថ្នាអារម្មណ៍ក្នុងលោក ឱ្យបានមកជារបស់ខ្លួន ។ សត្វលោកនឿយហត់មួយជីវិត ព្រោះតណ្ហា បានត្រឹមតែការដាក់គុកខ្លួនឯងក្នុងភពបី ព្រោះ

អំពើដែលសត្វលោកធ្វើដោយតណ្ហា គឺជាអភិសង្ខារ ជាបច្ច័យនៃភព ។

តាមពិត ទីពឹងនៅត្រង់ការរលត់តណ្ហា ព្រោះរលត់អវិជ្ជា។ ការរលត់ទៅនៃតណ្ហាគឺជាព្រះនិព្វាន ដូច្នេះបើមិនមានអរិយមគ្គជាហេតុទេ ទុក្ខនិរោធជាផលក៏ពុំមានដែរ ដោយហេតុថា អរិយមគ្គមានអង្គ ៨ ប្រការកើតឡើង ទើបដកបាននូវតណ្ហាព្រមទាំងឫសគល់គឺអវិជ្ជា ។

សរុបសេចក្តីក្នុងដំណោះស្រាយបញ្ហា គឺនៅត្រឹមតែកំណត់ដឹងទុក្ខប៉ុណ្ណោះ ។ បញ្ញាដែលកំណត់ដឹងទុក្ខកាលដែលចម្រើនឡើងហើយ រមែងលះនូវសមុទយៈ និងជាក់ច្បាស់នូវនិរោធ ។ បញ្ហាជាទុក្ខដែលកើតមានហើយនោះ វាមុខតែអស់ទៅខ្លួនឯង ព្រោះវាជាតួសង្ខារធម៌ ហើយកាលបើហេតុនៃទុក្ខមិនមាននេះឯង ជាការអស់បញ្ហាពិតប្រាកដ ព្រោះមិនមានភពថ្មីទៀត ។

# ១៤. បញ្ហាខកចិត្ត

បញ្ហាខកចិត្តនេះ មានទូទៅចំពោះសត្វលោក ដែលជាអ្នកមានសេចក្តីសង្ឃឹមទៅលើអ្វីមួយ ហើយមិនបានសម្រេច ។ សេចក្តីសង្ឃឹមក៏ជាចំណែកមួយនាំឱ្យមានកម្លាំងចិត្តក្នុងការងារដែរ ប៉ុន្តែ បើបុគ្គលអ្នកមាននូវសេចក្តីសង្ឃឹមនោះ មិនបានកំណត់ហេតុផលឱ្យជាក់-លាក់ ថែមទាំងមិនបានធ្វើទុកក្នុងចិត្តនូវសេចក្តីពិតរបស់សង្ខារលោកទេនោះ រោគខកចិត្តដែលជាបញ្ហាឈឺចាប់និងសោកសៅ ត្រូវបានកើតឡើងនៅពេលដែលមិនបានសម្រេចដូចក្តីសង្ឃឹម ។

សេចក្តីសង្ឃឹម ដែលមិនបានកំណត់ហេតុផលឱ្យជាក់លាក់ មានជាអាទិ៍ដូចជា :

- សង្ឃឹមថា មនុស្សគ្រប់គ្នានឹងមាននូវឧត្តមគតិ ឬមាននូវគតិធម៌ ជាមនុស្សល្អទាំងអស់គ្នា ។

- សង្ឃឹមថា មនុស្សក្នុងលោកនឹងស្រឡាញ់ខ្លួន ទទួលស្គាល់ខ្លួនគ្រប់ៗគ្នា ។

- សង្ឃឹមថា អ្នកដទៃមានសេចក្ដីស្រឡាញ់ស្មោះ ចំពោះខ្លួនរហូត មិនប្រែប្រួល ។

- សង្ឃឹមថា ខ្លួនឯងនឹងបានទៅជាបុគ្គលយ៉ាង នេះ យ៉ាងនោះតាមការតាំងចិត្ត ។

អ្វីៗក្នុងលោក សុទ្ធតែមានហេតុផលនិងការពិត កាលបើចេះតែមានសេចក្ដីសង្ឃឹម ដោយមិនបានកំណត់ ហេតុឱ្យបានច្បាស់លាស់ លុះដល់ហេតុអត់មាន ឬហេតុ មិនគ្រប់គ្រាន់ ផលក៏មិនបានសម្រេចតាមសេចក្ដីសង្ឃឹម នោះៗ រួចហើយមិនចេះកំណត់ដឹងទៅលើការពិតទៀត ថា អ្វីដែលកើតឡើង គឺវាត្រូវតែកើត និង អ្វីណាដែល មាន គឺវាត្រូវតែមាន ដូច្នេះការខកចិត្តព្រមទាំងសេចក្ដី ទុក្ខសោក រមែងគ្របសង្កត់ចិត្តខ្លាំង ។

មនុស្សយើងកាលណាជួបប្រទះនូវការខកចិត្ត គួរ គិតពិចារណាដូចតទៅនេះ :

- នេះឯងការពិតនៃជីវិតក្នុងលោក ។

- លោកនេះ មិនធ្លាប់មានការប្រព្រឹត្តទៅតាមសេចក្តីប្រាថ្នារបស់អ្នកណាឡើយ សូម្បីតែព្រះជាម្ចាស់ដែលគេប្រាប់ថាជាអ្នកសាងនូវលោក ក៏នៅតែគ្រប់គ្រងលោកនេះ និង គ្រប់គ្រងមនុស្សសត្វទាំងឡាយមិនបានផង ។

- សង្ខារធម៌ មិនបានឋិតនៅក្រោមអំណាចអ្នកណាមួយឡើយ សូម្បីតែព្រះព្រហ្ម ដែលគេប្រាប់ថាជាអ្នកលិខិតគ្រប់យ៉ាងគឺព្រហ្មលិខិតនោះឯង នៅតែធ្វើឱ្យមនុស្សល្អដូចព្រហ្ម ឬល្អតាមព្រះព្រហ្មប្រាថ្នានោះៗមិនបានផងដែរ ។

- ទោះជាមនុស្សណាខ្លាំងពូកែក្នុងលោកប៉ុនណាកាចសាហាវយ៉ាងណា ក៏មនុស្សនោះ មិនអាចចាត់ការចំពោះសង្ខារលោកបានដែរ ។ អ្នកដែលបានប្រកាន់ថាអញនិងរបស់អញកន្លងមក សុទ្ធតែធ្លាប់ឈឺចាប់ក្នុងដើមទ្រូង សោកសៅដំបៅចិត្តរួចមកហើយ ទាំងអ្នក

ដែលបាន អះអាងថាខ្លួនពូកែក្នុងការគ្រប់គ្រងប្រទេសនគរ ឬថាជាអ្នកខ្លាំងពូកែខាងផ្នែកសេដ្ឋកិច្ចពិភពលោកជាដើម សុទ្ធតែធ្លាប់ខកចិត្តឬកំពុងតែខកចិត្តហ្នឹងឯង ។

បុគ្គលណាមិនព្រមទទួលការពិត ត្រូវទទួលការឈឺចាប់ផ្លូវចិត្តជាពិតប្រាកដ ដូច្នេះកិច្ចការសំខាន់បំផុតរបស់យើងដែលបានកើតមកក្នុងលោកនេះ គឺត្រូវរៀនឱ្យបានចេះដឹងនូវការពិតនៃជីវិត និង ការពិតក្នុងលោក ។ បុគ្គលណាៗ ជំទាស់នឹងធម្មជាតិដែលប្រែប្រួល បុគ្គលនោះៗ ត្រូវទទួលការខកចិត្តនិងឈឺចាប់ខ្លោចផ្សាជាពិតប្រាកដ ។ ចំណែកបុគ្គលដែលដឹងទាន់ការពិត និង អប់រំចិត្តឱ្យព្រមទទួលការពិតនោះបាន ឈ្មោះថារៀនចេះនូវអនត្តលក្ខណសូត្រ មិនមានការខកចិត្ត ទាំងដែលប្រាសចាកនូវការសង្ឃឹមអ្វីៗពីលោកនេះ ហើយបានចូលដល់សេចក្ដីសុខស្ងប់ ទៀងទាត់មិនប្រែប្រួល ។

# ១៥~ បញ្ហាបែកបាក់គ្នា

កាលដែលមនុស្សយើង មិនអាចចុះចូលគ្នាបាន ដូចទឹកជាមួយនឹងប្រេង ក៏រមែងបែកបាក់គ្នា ចាប់ពីពីរនាក់ឡើងទៅ ។ អ្នកដែលបានជួបប្រទះរឿងនេះដោយផ្ទាល់ខ្លួនឯង រមែងដឹងខ្លួនថា ផ្លូវចិត្តមានរបួស បើរបួសក្រសះ ក៏ក្លាយទៅជាដំបៅរ៉ាំរ៉ៃ ។

លក្ខណៈនៃការបែកបាក់គ្នា គឺការមិនព្រមព្រៀងគ្នា មិននិយាយគ្នា មិនធ្វើការរួមគ្នា មិនគប់រកគ្នា មិនមើលមុខសម្លឹងភ្នែកឱ្យចំគ្នា មិនញញឹមដាក់គ្នា និង មិនបរិភោគអាហារជាមួយគ្នាជាដើម ។ ចំណែកផ្លូវចិត្តវិញមានសេចក្ដីដឹងខ្លួនថា ឈឺជ្រៅទៅក្នុងចិត្ត ពេលខ្លះក៏តាំងខ្លួនជាសត្រូវនឹងគ្នាទៀតផង ។ ក្នុងផ្នែកទំនាក់ទំនងដែលធ្លាប់តែមានមកពីមុន ក៏ប្រាកដជាការអស់សង្ឃឹមទាំងស្រុង ឯការឈឺចាប់ កើតទុក្ខទោមនស្ស ទៅតាម

ទំហំនៃការប្រកាន់ក្នុងគំនិត សើរើរឿងដែលខ្លួនធ្លាប់មានឧបការៈផ្សេងៗ ។ ប្រសិនបើការបែកបាក់គ្នានោះ ក្លាយទៅជារឿងប្រឈមមុខដាក់គ្នា ម្ខាងៗរមែងស្វែងរកគ្នាជាពួកជាបក្ស ហើយក៏ធ្លាក់ចូលទៅក្នុងជម្លោះ ។

នៅក្នុងដំណោះស្រាយរឿងបែកបាក់គ្នានេះ មានដូចតទៅ :

- គប្បីយល់អំពីការពិតថា ការកំណត់ទៅលើអំពើខុសឬត្រូវផ្សេងៗ ចំពោះបុគ្គលនោះៗ វាជារឿងដែលមនុស្សយើងសន្មតគ្នាលើកតម្កើងឬដាក់ទោស ឱ្យខុសឱ្យត្រូវទៅលើបុគ្គលតែប៉ុណ្ណោះ ។ ចំណែកបរមត្ថធម៌ ចិត្ត ចេតសិក រូប គឺជាធម្មជាតិដ៏បរិសុទ្ធចាកសត្វបុគ្គល ដូច្នេះត្រូវមើលឱ្យធ្លុះបញ្ញត្តិ ចូលដល់បរមត្ថសុទ្ធៗ ទើបចិត្តថ្លាស្អាត មិនវង្វេងទៅក្នុងសាច់រឿង ដែលគ្រាន់តែជាតួអង្គសម្តែងក្នុងរោងល្ខោននៃជីវិតនេះឡើយ ។

- គប្បីជ្រាបអំពីមនុស្សក្នុងសង្គមលោក ដ៏ធំនេះ ដែលមានសភាពផ្សេងគ្នាច្រើនបែបច្រើនយ៉ាង ទាំងផ្នែក

ការអប់រំចម្រើន ទាំងផ្នែកការនិយមចូលចិត្ត ទាំងផ្នែកឧបនិស្ស័យ ទាំងផ្នែកសតិបញ្ញា និង ទាំងផ្នែកការប្រព្រឹត្តទៅតាមកម្មជាដើម ។ គ្រប់ផ្នែកទាំងអស់គឺជាផលសម្រេចតាមបច្ច័យ វាជាអ្វីដែលតែងមាន រមែងមាន ដូចដែលវាមានហើយហ្នឹងឯង ។ ការដែលសម្លឹងមើលឃើញសេចក្តីពិតថា អ្វីៗសុទ្ធតែមានសិទ្ធិសម្រេចរបស់ខ្លួន ដែលមានហេតុបញ្ជាក់ដល់សិទ្ធិសម្រេចនោះៗយ៉ាងនេះ ការមិនប្រកាន់ ការមិនមើលងាយ ការមិនទាស់ចិត្ត បានកើតឡើងព្រមជាមួយនឹងការសម្លឹងឃើញសេចក្តីពិតនោះឯង ។ បើមិនគោរពចំពោះសិទ្ធិសម្រេចនៃធម៌ទាំងឡាយ ដែលមានហេតុឱ្យកើតឡើងនោះទេការឈ្លោះទាស់ទែង លែងលះបែកបាក់ ត្រូវកើតឡើងជំនួសសន្តិភាព ពោលគឺ ទាំងសន្តិភាពក្នុងចិត្ត ទាំងសន្តិភាពក្នុងសង្គមត្រូវខ្ទេចខ្ទាំខូចខាត ។

- គប្បីអប់រំគុណធម៌ ចរិយាមារយាទឱ្យបានប្រសើរ ។ ចំពោះក្រុមមនុស្សដែលមានទំនាក់ទំនងគ្នា

ក្នុងការរស់នៅ ទទួលខុសត្រូវចំពោះគ្នាទៅវិញទៅមក ទាំងកិច្ចការខ្លះត្រូវទទួលខុសត្រូវរួមគ្នា ដើម្បីរក្សាផល ប្រយោជន៍រួម ។ គប្បីមាននូវសេចក្តីស្មោះត្រង់ចំពោះ ការងារ ស្មោះត្រង់ចំពោះអ្នកដទៃ រក្សាការគោរពឱ្យបាន ខ្ជាប់ខ្ជួន និង ការយកចិត្តទុកដាក់លះបង់នូវអ្វីដែលជា ទម្លាប់មិនល្អ ព្រមទាំងអប់រំបណ្តុះបណ្តាលនូវគុណធម៌ ផ្សេងទៀត ដូចជា មេត្តាករុណា ឧស្សាហ៍ព្យាយាម សេចក្តីអត់ធន់ជាដើម ។ ម្នាក់ៗ គប្បីបង្វែរនូវគុណធម៌ និង ចរិយាមារយាទល្អឱ្យចូលគ្នាយ៉ាងមានរបៀបរៀបរយ និង យ៉ាងត្រជាក់ស្រទន់ ដូច្នេះការប៉ះទង្គិចគ្នារមែងមិន មានឡើយ ។ ប្រសិនបើយើងចេះតែបង្វែរនូវភាពខ្លាំង ភាពរឹងត្អឹង ការតាំងចិត្តមិនចុះសម្រុង និង ការមិន សុភាពរាបសាដាក់គ្នាទៅវិញនោះ ការប៉ះទង្គិចគ្នានឹង មានជាប្រាកដ ម្ល៉ោះហើយ សេចក្តីអាក្រក់ដែលដេក ជាអនុស័យ ក៏បានកើតឡើងដុតរោលចិត្តសន្តានខ្លួនឯង ហើយចាត់ការឃោសនានូវអ្វីៗ ដែលជារឿងមិនល្អរបស់

គួបដិបក្ខ ព្រមទាំងរឿងអាក្រក់ៗក្រៃលែងឡើងទៀតនឹងកើតមានតទៅ ដូច្នេះត្រូវចេះពិចារណាឱ្យឃើញភ័យក្នុងការសាងសត្រូវឱ្យខ្លួនឯង គ្រាន់តែសត្រូវគឺកិលេសក្នុងចិត្តរបស់ខ្លួន វាច្រើនណាស់ទៅហើយ ។

- គប្បីគិតឱ្យយល់ថា ការព្រមព្រៀងគ្នាសំខាន់ជាងការប្រកាន់ខុសត្រូវ ពោលគឺ ឱ្យតែនៅក្នុងការមិនទាន់បែកបាក់គ្នា រឿងខុសត្រូវនៅនិយាយគ្នាបាន ។ ដាច់ខាតកុំឆ្លៀតឱកាសយកគ្រាន់បើព្រោះតែអ្នកដទៃខុស ព្រោះវានាំឱ្យសង្កត់អ្នកដទៃថែម ដែលលំបាកនឹងឱ្យមានការព្រមព្រៀងគ្នាវិញណាស់ ព្រោះកាលបើបែកបាក់គ្នាហើយ វាមានតែការប្រហារគ្នាដោយលំពែងគឺមាត់ ដូច្នេះ រឿងខ្លះត្រូវលះបង់នូវទ្រព្យសម្បត្តិ ក៏លះទៅ ឱ្យតែនៅរក្សាការព្រមព្រៀងគ្នាបាន ទាំងត្រូវចេះលើកទឹកចិត្តឱ្យសេចក្តីសំខាន់ដល់អ្នកដទៃ ចំពោះអ្វីដែលគួរឱ្យសរសើរពិតៗ ដើម្បីរក្សាការព្រមព្រៀងគ្នានោះឯង ។

- គប្បីប្រព្រឹត្តធម៌ឱ្យបរិសុទ្ធ ដើម្បីប្រយោជន៍សុខ

ដល់គ្រប់គ្នាទាំងពីរពួក គឺពួកខ្លួនឯងនិងពួកបដិបក្ខ ព្រោះថាធម៌បរិសុទ្ធនេះ គ្រប់គ្នាត្រូវតែព្រមទទួលយក ទទួលស្គាល់ និង ទុកតម្កល់សម្រាប់បូជាទៀតផង ។

មិត្តរមែងរក្សាអាចិកំបាំងរបស់មិត្ត បើយើងបែកមិត្តសាងសត្រូវ រឿងអាចិកំបាំងប្រាកដជាត្រូវបែកធ្លាយ។ បើអ្នកណានិយាយរឿងដែលមិនល្អពីយើង យើងត្រូវតែព្យាយាមធ្វើល្អជាមួយនឹងអ្នកនោះឯង ឱ្យជាការល្អពិតៗប្រសើរជាងទៅស្អប់ ទៅឈ្លោះ តមមាត់គ្នា ។

តាមពិត មនុស្សយើងព្រមព្រៀងគ្នាល្អជាង រឿងខ្លះបានជាកើតទៅហើយ ត្រូវផ្សះផ្សាទៅ ឱ្យវាឆាប់ចប់ឆាប់អស់រឿងក្ដៅក្រហាយ ។ ត្រូវដឹងថាកិលេសទេដែលជាតួញុះញង់មនុស្សយើងឱ្យបែកបាក់គ្នានោះ ។

# ១៦. បញ្ហាចង់ឱ្យគេទទួលស្គាល់

បញ្ហា វានៅត្រង់ការមិនស្គាល់ខ្លួនឯងតាមពិត ទើបគិតចង់ឱ្យគេទទួលស្គាល់ថា ខ្លួនឯងពូកែយ៉ាងនេះ គ្រាន់បើយ៉ាងនោះ ព្រមជាមួយគ្នាហ្នឹងដែរ ក៏មិនចង់ឱ្យគេស្គាល់ប្រវត្តិមិនល្អ ចំណុចខ្វះខាតរបស់ខ្លួនឡើយ ។

កាលបើអ្នកណាៗ មិនព្រមទទួលស្គាល់នូវឋានៈស័ក្តិយសកេរ្តិ៍ឈ្មោះរបស់ខ្លួន ក៏ពោលថាគេនោះៗមិនល្អ ទាំងដែលខ្លួនឯងកំពុងតែចង់ឱ្យគេទទួលស្គាល់នោះ ក៏កំពុងតែមិនល្អហើយស្រេច ។

នឹកចង់ឱ្យគេហៅឈ្មោះបញ្ញត្តិ តាមឈ្មោះងាររបស់ខ្លួនដែលមាន ។ តាមពិតឈ្មោះងារមិនមានដោយបរមត្ថឡើយ ឯចំណែកមនុស្សម្នាក់ៗវិញមានត្រឹមតែបរមត្ថប៉ុណ្ណោះគឺចិត្ត ចេតសិក រូប អត់មានឈ្មោះអ្វីទាំងអស់ ។ ត្រូវចាំថា អ្វីណាដែលមាន គឺអ្វីនោះមានការ

កើតឡើង ដូច្នេះឈ្មោះបញ្ញត្តិគឺទទេ ព្រោះមិនមានការកើតឡើងអ្វីទាំងអស់ ប៉ុន្តែលោភៈល្ងង់ខ្លៅបែរទៅជាស្រឡាញ់របស់អត់ទទេ ត្រង់នេះឯងដែលពោលថាមនុស្សយើងមិនបានស្គាល់ខ្លួនឯងតាមពិតនោះ ។ តើខ្លួនឯងតាមពិតនោះវាជាអ្វី ? គឺចិត្ត ចេតសិក រូប ដែលកើតឡើងហើយ រលត់រលាយទៅវិញភ្លាមតែប៉ុណ្ណោះ ។

ការដែលចង់សម្តែងខ្លួនឱ្យប្រសើរជាងគេ ក្នុងទីប្រជុំជន ចង់ឱ្យគេរំលឹកឈ្មោះហើយសរសើរ នេះហៅថាចង់បានមុខមាត់ គឺជាជីវិតខ្វះខាត ត្រូវការអ្វីៗពីអ្នកដទៃច្រើនបែបច្រើនយ៉ាងរកទីបំផុតគ្មានឡើយ ។ សូម្បីតែចៅហ្វាយនាយហើយ ក៏បែរជាមកត្រូវការអ្វីៗអំពីទាសកម្មករដ៏ច្រើន ដូចជាត្រូវការឱ្យគេយកចិត្តទុកដាក់នឹងខ្លួន ត្រូវការឱ្យគេគោរពកោតខ្លាចខ្លួនជាដើម កាលដែលពុំបានតាមប្រាថ្នាក៏ក្រោធខឹង ជីវិតយ៉ាងនេះ ពិតជាត្រដាបត្រដួសមែនទែន ។

ដំណោះស្រាយបញ្ហាមានដូចតទៅ :

- គប្បីពិចារណាឱ្យយល់ថា បើចង់ឱ្យអ្នកដទៃទទួលស្គាល់ប៉ុនណា ចិត្តក៏រមែងទន់ខ្សោយប៉ុណ្ណោះដែរ ទន់ខ្សោយរហូតដល់ថ្នាក់ ជាទាសៈនៃកិលេសអ្នកដទៃនោះៗទៀតផង ។ តើជាទាសៈនៃកិលេសអ្នកដទៃដូចម្ដេច គឺវានៅក្នុងចំណុចដែលថា អ្នកដទៃឱ្យអ្វីយើង តើឱ្យដោយចិត្តបរិសុទ្ធ ឬឱ្យដោយកិលេសហ្នឹងឯង ។ អាការដែលជាទាសៈនៃកិលេសខ្លួនឯងផង ជាទាសៈនៃកិលេសអ្នកដទៃផង ដូច្នេះចិត្តរមែងវិវក់មែនទែន ។ បើពោលពីការមិនចង់បានអ្វីពីអ្នកដទៃវិញ រឹតតែមិនចង់បាន គឺរឹតតែមានចិត្តពេញ ពោលគឺចិត្តមានភាពជាធំ មានភាពជាឥស្សរៈ មានកម្លាំងមាំមួន ។ ត្រង់នេះមិនមែនបានសេចក្ដីថា មិនគប្បីទទួលអ្វីពីអ្នកដទៃសោះនោះទេ គ្រាន់តែការទទួលដោយសុជីវធម៌ ទទួលដោយអនុគ្រោះ ទទួលដោយសន្ដោស ទទួលរបស់ដែលគួរ និង ទទួលដោយល្មមប្រមាណតែប៉ុណ្ណោះ ។ ត្រូវចាំថា ការដោះស្រាយបញ្ហាខ្លួនឯងក្ដី បញ្ហាអ្នកដទៃក្ដី វានៅត្រង់រំលត់

តណ្ហា មិនមែនតាមបែបប្រកបខ្លួនក្នុងកាម ឬតាមបែបធ្វើខ្លួនឱ្យលំបាកឥតប្រយោជន៍នោះឡើយ ។

- អប់រំសតិប្បដ្ឋាន កំណត់ដឹងរូបធម៌និងនាមធម៌ដែលកំពុងមាន កំពុងប្រាកដ ។ ដោយបរមត្ថ នាមរូបមិនចេះខ្វះអ្វីដោយខ្លួនឯងនោះឡើយ ។ នាមរូបដែលជាសង្ខារធម៌ សុទ្ធតែអាស្រ័យបច្ច័យកើតឡើង អ្វីដែលកើតពីបច្ច័យមិនដែលមានខ្លួនឯងទេ គ្រាន់តែជាផលរបស់បច្ច័យប៉ុណ្ណោះ ។

កាលដែលពុទ្ធបរិស័ទ ចូលដល់ខ្លួនឯងដោយវិបស្សនា កំណត់ដឹងតួនាម តួរូប គ្រាន់តែជាតួធម៌ពិត ៗ ហើយឃើញសេចក្តីពិតរបស់នាមរូប គ្រប់គ្រាន់ដោយខ្លួនឯង មិនហួងហែងខ្លួនឯង ដូច្នេះពុទ្ធបរិស័ទក៏រមែងជាបុគ្គលស្គាល់ខ្លួនឯង ពេញលេញដោយខ្លួនឯង ។

វិបស្សនាកម្មដ្ឋាននេះ ដោះស្រាយបាននូវគ្រប់បញ្ហាទាំងអស់ ។

# ១៧. បញ្ហាមិនស្មោះត្រង់

បញ្ហានេះមានច្រើន នៅក្នុងសម័យដែលមនុស្ស ឃើញរបស់សន្មតផ្សេងៗ ដែលជារបស់ក្រៅខ្លួន ទៅជាសម្គាល់ថាសំខាន់ជាងខ្លួន និង សំខាន់ជាងអ្នកដទៃ ។ កាលណាដែលមនុស្សយើងឱ្យសេចក្ដីសំខាន់ទៅលើរបស់ខាងក្រៅជាង កាលនោះ គឺមនុស្សនឹងជាន់ឈ្លីខ្លួនឯង និងអ្នកដទៃ ដើម្បីអ្វីៗដែលជឿថាសំខាន់នោះឯង មិនថាវាជាតំណែងតែងតាំង មាសប្រាក់ កេរ្ដិ៍ឈ្មោះ ឬអ្វីៗផ្សេងទៀត ដែលជាការនិយមចូលចិត្តក្នុងលោកនោះឡើយ ។

ការមាក់ងាយ ជាន់ឈ្លីទម្លាយនូវសម្បជញ្ញៈរបស់ខ្លួនឯង ដើម្បីរបស់ខាងក្រៅ គឺជាការមិនស្មោះត្រង់នឹងខ្លួនឯង ទុយ៉សចំពោះខ្លួន ។

ការមាក់ងាយ ជាន់ឈ្លីទម្លាយនូវការស្មោះត្រង់

របស់អ្នកដទៃ ព្រោះតែអាស្រ័យរបស់អ្វីៗដែលជាសម្មតិក្នុងលោក ដើម្បីខ្លួនឯងមិនចេះគ្រប់ ឈ្មោះថា មិនស្មោះត្រង់ចំពោះអ្នកដទៃ ទុយ៏សចំពោះអ្នកដទៃ ។

អាការលក្ខណៈប្រាកដ វានៅត្រង់ដែលថា មិនបានយកការស្មោះត្រង់ជាគុណតម្លៃនៃជីវិត វាបែរទៅជាជាន់ឈ្លីជីវិតខ្លួនឯងនិងជីវិតអ្នកដទៃ ដើម្បីរបស់ខាងក្រៅដែលមិនមែនជាខ្លឹមសារពិតនៃជីវិតទៅវិញ ។

ម្យ៉ាងទៀត វាឋិតនៅក្នុងលក្ខណៈបញ្ឆោតអ្នកដទៃ ដើម្បីបំពេញតណ្ហាខ្លួនឯង ។

ជាអ្នក ដុតបំផ្លាញនូវគុណតម្លៃនៃជីវិតពិតប្រាកដជាចោរប្លន់ទំនុកចិត្ត លួចដូររបស់ពិត ឱ្យរបស់កាឡៃ ។

ដំណោះស្រាយបញ្ហា គឺគប្បីពិចារណានូវការស្មោះត្រង់ដោយធម៌សច្ចៈយ៉ាងនេះថា :

សច្ចធម៌ មានរសជាតិប្រសើរលើសអស់រសជាតិទាំងពួង ។ បុគ្គលស្មោះត្រង់ ជាបុគ្គលមានគុណគួរបូជាញ៉ាំងនូវទំនុកចិត្ត និង ភាពកក់ក្តៅដល់អ្នកដែលពាក់ព័ន្ធ

ទាំងឡាយ មានរសជាតិដែលមិនចេះសាបរលាប មិនចេះឱ្យធុញទ្រាន់ ។

ព្រះបរមពោធិសត្វ ហ៊ានលះបង់ជីវិតក្នុងការរក្សាសច្ចវាចារបស់ព្រះអង្គ រួចហើយបានត្រាស់ដឹងជាព្រះ-សម្មាសម្ពុទ្ធ ។

សេចក្តីស្មោះត្រង់ បានមកដោយការតាំងចិត្តយ៉ាងឧក្រិដ្ឋមាំមួន មានចិត្តបរិសុទ្ធចំពោះមនុស្សគ្រប់គ្នា ព្រមទាំងបានយល់ដឹងយ៉ាងច្បាស់ថា ការស្មោះត្រង់ គឺជាការផ្តល់កិត្តិយស ដ៏យ៉ាងសមរម្យចំពោះមនុស្សជាតិទាំងឡាយ ទាំងខ្លួនឯង ទាំងអ្នកដទៃ ។

ពិចារណា ឱ្យឃើញទោសនៃការមិនស្មោះត្រង់ថា មនុស្សមិនស្មោះត្រង់ជាមនុស្សអត់រសជាតិ ប្រាកដជាត្រូវគេបោះបង់ចោលមិនខានឡើយ ហើយខ្លួនឯងវិញនឹងជួបប្រទះនូវកម្មពៀរ ។

(បុគ្គលដែលបានទទួល ការមិនស្មោះត្រង់ពីអ្នកដទៃគប្បីដោះស្រាយក្នុងមាតិកាលេខ ១៤ **បញ្ហាខកចិត្ត** )។

# ១៨. បញ្ហាហួងហែងហួស

វាជាបញ្ហាលំបាកទាំងពីរខាង ទាំងអ្នកហួងហែងហួស ទាំងអ្នកដែលត្រូវហួងហែងនោះឯង ។

ហួងហែងខ្លាំងពេក រហូតដល់អ្នកដទៃមើលពុំឃើញគុណតម្លៃពិតប្រាកដ នេះក៏ដោយសារអ្នកដទៃមានសេចក្តីរំខាន មានការចង្អៀតចង្អល់ ខ្វះសេរីភាព ។

ម៉ែឪមើលឃើញកូនរបស់ខ្លួនដូចនៅតែក្មេង ទើបហួងហែងហួស ចំណែកកូនវិញស្រឡាញ់ម៉ែឪ ប៉ុន្តែពុំសូវចង់នៅជាមួយ ដូច្នេះ ការហួងហែងហួស ទើបដូចជាបានសាងនូវការនិរគុណឱ្យដល់កូន ដោយអចេតនា ។

ដល់ពេលការហួងហែងហួសត្រឡប់តបស្នង ត្រូវយំសោកសៅ បាយមិនបានសម្រាន្តមិនលក់ បិសាចនៃការគិតស្មានបានសាងរឿងគួរឱ្យស្លុតរន្ធត់ ឈឺចាប់ក្នុងដើមទ្រូង ។

ដំណោះស្រាយមានដូចតទៅ :

- ដើម្បីប្រយោជន៍និងភាពកក់ក្តៅដល់គ្នាទៅវិញទៅមក គប្បីបន្ថយការហួងហែង ដូច្នេះសម្ពន្ធភាពរមែងយឺនយូរ ។

- គប្បីពិចារណាថា ការហួងហែងដូចជាការឱបរឹត បើវាតឹងពេកទៅ វាពិតជានាំឱ្យលំបាកដកដង្ហើម ។

- ត្រូវរំលឹកខ្លួនឯងថា មនុស្សយើងចាញ់បោកតែគំនិតខ្លួនឯងរហូត ព្រោះគំនិតប្រកបដោយកិលេស ជាធម្មជាតិសាងនូវរឿងឱ្យវង្វេងច្រឡំ ។ ដើម្បីកុំឱ្យគំនិតបោកខ្លួនឯងបាន ត្រូវអប់រំសតិប្បដ្ឋាន កំណត់ដឹងការពិតក្នុងលោក ។

- ត្រូវពិចារណាថា អ្នកណាៗក៏គេចមិនផុតពីចាស់ឈឺស្លាប់ព្រាត់ប្រាសនិងកម្មឱ្យផលដែរ ខ្លួនយើងក៏គេចមិនផុត ។

- បើយើងស្លាប់ទៅ យើងនៅហួងហែងស្អីបានទៀត ដូច្នេះត្រូវប្រញាប់រៀបចំ កុំចាំបាច់ហួងហែងវែង

ឆ្ងាយ សប្បាយៗមុនពេលស្លាប់ ព្រោះគ្មានអ្វីសម្រាប់ឱ្យហួងហែង ដល់ពេលស្លាប់ទៅបិទភ្នែកជិត ។

- ត្រូវចូលដល់ការពិតនៃបរមត្ថ ព្រោះបរមត្ថធម៌ជាធម៌មិនគប្បីហួងហែងឡើយ មានតែចិត្ត ចេតសិក រូប សូន្យចាកតួខ្លួនឯង ។

គប្បីសិក្សាថា មនុស្សទាំងឡាយតែងសោកសៅ ព្រោះហេតុតែអ្វីៗដែលខ្លួនឯងហួងហែង ។ របស់ដែលហួងហែងក្តី ការហួងហែងក្តី សុទ្ធតែមិនទៀងទាត់ ។ មនុស្សដ៏ច្រើនបានបាត់បង់ជីវិត ព្រោះតែរបស់ដែលខ្លួនហួងហែង ។ សម្បត្តិមនុស្សមិនមែនជាសម្បត្តិផុតចាកបញ្ហាឡើយ ដូចជាមាសប្រាក់ រហូតដល់ភរិយាស្វាមី ទាសាទាសី ។ល។ សុទ្ធតែជាសម្បត្តិនាំមកនូវអន្តរាយក្រវល់ក្រវាយទាំងអស់ ។ អ្នកប្រាជ្ញ សម្លឹងឃើញទោសនៃសម្បត្តិទាំងនោះហើយ រមែងលះបង់សេចក្តីអាល័យដោយការប្រព្រឹត្តនូវនេក្ខម្មៈ ។

# ១៩~ បញ្ហាលោភៈ

លោភៈគឺជាការជាប់ជំពាក់ ការចង់បាន មានលក្ខណៈប្រាកដក្នុងចិត្តដូចតទៅ :

- មានសេចក្ដីត្រេកអរដោយការជាប់ស្អិត ក្នុងអារម្មណ៍ ឬក្នុងសត្វនិងសង្ខារណាមួយ ។

- មានការចង់ឃើញ ចង់ជួប ចង់ប៉ះ ។ល។ ហើយចង់បានយកមកដើម្បីគ្រប់គ្រង ។

- កាលដែលយកមកគ្រប់គ្រងបានហើយ រមែងត្រេកអរ ព្រមទាំងហួងហែងរក្សា ។

- កាលដែលបាត់បង់ រមែងស្ដុតរន្ធត់ យំសោកបោកខ្លួន ទាំងដែលចង់បានមកវិញឬចង់បានថ្មីទៀត ។

- មានគំនិតគិតសាងរឿងនេះ រឿងនោះ ដោយការពេញចិត្ត ទាំងដែលមិនមានរបស់ដែលពេញចិត្តណាមួយ មកបញ្ចប់ការចង់បានថ្មីទៀតឡើយ ។

ជាមួយគ្នានឹងចិត្តស្រឡាញ់ ជាប់ជំពាក់ចំពោះរបស់ក្នុងលោក រាងកាយរមែងធ្វើការច្រើន ស្ទុះស្ទាទៅគ្រប់ពេលនិងគ្រប់ទិស មិនថាយប់ថ្ងៃ ក្ដៅរងា ព្រោះការចង់បានជាហេតុ សូម្បីតែដេកលក់ក៏យល់សប្តិចង់បាន អង្គុយស្ងៀមៗក៏ចិត្តគិតទៅដោយការជាប់ជំពាក់ដែរ ។ លោភៈជាថ្នាំពិសដែលមានអានុភាពចំពោះចិត្តកាយ គួរឱ្យសង្វេគដូច្នេះឯង ។

លោភៈដែលជាឧបនិស្សយប្បច្ច័យនៃការប្រព្រឹត្តល្អក៏មានដែរ គឺ

- ចង់ឱ្យខ្លួនឯងបានជាមនុស្សល្អ ។ ក្នុងចំណុចនេះត្រូវប្រយ័ត្នសេចក្ដីល្អនោះៗ ត្រឡប់មកជាអារម្មណ៍នៃលោភៈវិញ។ កាលបើសេចក្ដីល្អត្រឡប់មកជាអារម្មណ៍របស់លោភៈ បានសេចក្ដីថា ធ្វើល្អដើម្បីចិញ្ចឹមលោភៈ ហើយក៏ចិញ្ចឹមមោហៈផងដែរ ។

- ចង់រួចផុតចាកទុក្ខក្នុងវដ្ដសង្សារ ។ ក្នុងចំណុចនេះ ដូចជាបុគ្គលលិចទូកហើយ ខំប្រឹងហែលទឹកប្រាថ្នា

រកកោះរកត្រើយ ដើម្បីឱ្យខ្លួនបានទីពឹងផុតពីលង់ទឹកស្លាប់ ដូច្នោះឯង ។ ចំណង់ដែលជាលោភៈនេះ នាំឱ្យកុសលផ្សេងៗកើតឡើង មានព្យាយាម មានសតិប្បដ្ឋានរហូតដល់សម្រេចបានអរិយមគ្គ ។ ទីបំផុត ចំណង់ដែលជាលោភៈត្រូវអស់មិនមានសល់ ដូចជាបុគ្គលហែលទឹកដល់ត្រើយហើយ ការចង់ដល់ត្រើយក៏លែងមានទៀតដូច្នោះដែរ ។

ត្រូវប្រយ័ត្នចំណង់ក្នុងរឿង ដែលអត់មានខ្លឹមសារផ្សេងៗ ចំណង់កាម ចំណង់ភព វាជាការហត់នឿយខាតទុន និង ខាតពេលក្នុងរយៈដ៏សែនវែងឆ្ងាយឥតប្រយោជន៍ ចាំបាច់ត្រូវបំបាត់ត្រូវរារាំងតាមគោលការណ៍ពិចារណាទោស និង កំណត់ដឹងនូវទុក្ខដូចខាងក្រោមនេះ គឺ

- គប្បីពិចារណាថា ចំណង់លោភៈនេះឯង បាននាំជីវិតចូលទៅរកបញ្ហារាប់មិនអស់ រវល់តែដោះស្រាយបញ្ហាដែលលោភៈខ្លួនឯងបានសាងឡើងមិនចេះចប់ ទាំង

លោភៈនេះទៀតសោត បានសាងកម្មដែលជាពូជនៃភពថ្មី កាលដែលភពថ្មីកើតហើយ ត្រូវជរាមរណៈកម្ចាត់ចោលអស់ ត្រូវសាងថ្មីទៀត នេះជាអំពើខាតទុនប្រកបដោយភាពល្ងង់ខ្លៅ ។

- កំណត់បញ្ចក្ខន្ធថាជាភារៈធ្ងន់ ជាផុងភ្លើង ការចាប់ប្រកាន់បញ្ចក្ខន្ធគឺជាទុក្ខផងល្ងង់ខ្លៅផង ឯការដែលមិនចាប់ប្រកាន់ជាការអស់ទុក្ខ អស់បញ្ហា ជាព្រះនិព្វានដោយអត់ចាំបាច់រកសុខអ្វីដទៃផ្សេងទៀតទាំងអស់ នេះជាការចាក់ផ្លុះក្នុងទុក្ខនិរោធ ។

- ដើម្បីការមិនចាប់ប្រកាន់អ្វីៗទៅបាន ត្រូវហ្វឹកហាត់ដកចិត្តចេញអំពីរបស់ដែលប្រែប្រួល ដូចជាការដកចិត្តចេញពីមនុស្សមិនស្មោះត្រង់ ដូច្នោះឯង ។ ព្រះពុទ្ធ-អង្គទ្រង់ត្រាស់ថា របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាដែលជាទុក្ខមានការប្រែប្រួលជាធម្មតា ត្រូវឃើញថា នោះមិនមែនជារបស់យើងឡើយ ។

- បំពេញតួនាទីខ្លួនឯងប្រកបដោយធម៌ ដ៏បរិសុទ្ធ

មិនជាទាសៈនៃកិលេសខ្លួនឯង និងមិនវង្វេងយកកិលេសអ្នកដទៃមកទូលនោះឡើយ ។ ក្នុងចំណុចបំពេញតួនាទីនេះ គឺជាការសង្គ្រោះ មេត្តាករុណាពិតៗមិនទាមទារផលតបស្នងអ្វីទាំងអស់ ចិត្តស្ងប់មានទីពឹងដោយខ្លួនឯង ។

- មានជីវិតរស់នៅយ៉ាងសុភាពរាបសា សាមញ្ញធម្មតា ស្រួលងាយ សមរម្យជាមួយនឹងធម្មជាតិ ដីទឹកភ្លើងខ្យល់ ក្តៅត្រជាក់ថ្ងៃយប់ ជោរនាច ភ្លៀងរាំង លាស់ស្លឹកហើយជ្រុះ ។ល។ ជីវិតជាធាតុពិតដោយបរមត្ថ ចិត្តចេតសិក រូប ។

- រស់នៅជាមួយនឹងចិត្ត ចេតសិក រូប ដោយសតិប្បដ្ឋានប្បដិបត្តិ ។ ដែលថាខ្លួនយើងគឺមិនមានអ្វីក្រៅអំពីបរមត្ថទាំងបីនេះឡើយ ។ បរមត្ថទាំងបីអាស្រ័យបច្ច័យកើតឡើង មិនត្រូវការអ្វីទាំងអស់ពីក្នុងលោកនេះមិនប្រកាន់ខ្លួនឯង ព្រោះខ្លួនឯងមិនមានហើយស្រេចគ្រាន់តែជាផលនៃបច្ច័យប៉ុណ្ណោះ មិនតក់ស្លុតនឹងការរលត់បាត់បង់ទៅវិញនោះឡើយ ។ បើមិនស្គាល់ខ្លួនឯង

តាមពិតជាបរមត្ថ ចិត្ត ចេតសិក រូបទេ គឺពិតជាមិនអាច ស្ងប់ស្ងៀមក្នុងចិត្តបានឡើយ ហើយក៏មិនអាចឈ្នះលោក នេះបានដែរ ត្រូវពឹងលោកនេះ រស់នៅក្នុងភាពជាទាសៈ រហូតហ្នឹងឯង ។

គប្បីសិក្សាថា មានឬក្រ គឺនៅនឹងចិត្ត កុំមើលទៅ លើទ្រព្យសម្បត្តិ មាសប្រាក់លុយកាក់ ទោះជាមានប្រាក់ ច្រើនប៉ុនណា បើចិត្តនៅស្រេកឃ្លានដោយតណ្ហា ឈ្មោះ ថា នៅក្ររហេមរហាម ដោយពិត ។ បើចេះល្មមក្នុងចិត្ត វិញ ពេលណាក៏ដោយ គឺជាអ្នកមាន ជាអ្នកគ្រប់គ្រាន់ ពេលនោះឯង ។

## ២០. បញ្ហាទោសៈ

លក្ខណៈនៃសេចក្តីក្រោធយ៉ាងណា យើងដឹងជាទូទៅគ្រប់គ្នាហើយ ។ សេចក្តីក្រោធគឺជាទោសៈប្រទូស្តចំពោះអារម្មណ៍ រាល់ពេលដែលកើតឡើង សុទ្ធតែមានលោភៈជាឧបនិស្សយប្បច្ច័យជានិច្ច ។ គប្បីសិក្សាលះបង់ទោសៈគឺការខឹងក្រោធនេះ ដូចតទៅ :

- តាំងចិត្តទុកជាមុនថា យើងនឹងមិនក្រោធព្រោះការខឹងក្រោធទៅរកគេ គឺដុតចិត្តខ្លួនឯង ។

- អ្នកណាៗ ដែលធ្វើអ្វីៗល្មមឱ្យយើងខឹងបាន ប៉ុន្តែយើងត្រូវអាណិតគេនោះៗភ្លាម កុំឱ្យសេចក្តីក្រោធកើតមុន ។ មនុស្សណា ដែលធ្វើអ្វីៗដោយមិនចេះកោតក្រែង ចង់ឱ្យគេឈឺចិត្ត ចង់អ្នកណាខឹងអីខឹងទៅដោយមិនគិតឡើយថា គេខឹងគឺគេកើតទុក្ខ ដូច្នេះមនុស្សនោះគឺជាមនុស្សល្ងង់ដែលគួរឱ្យអាណិតហ្នឹងឯង ។

- ចម្រើនមេត្តាចិត្តឱ្យជំនាញ ត្រូវគិតថា អ្នកណាៗក៏ចង់បានសុខដូចយើងដែរ ។ ចិត្តមានមេត្តា ជាចិត្តធំទូលាយ មិនមានពៀរ មិនមានព្យាបាទ បើចិត្តចង្អៀតវិញ រមែងខឹងក្រោធងាយៗ ។

- ប្រសិនបើសេចក្តីក្រោធកើតឡើងនោះ ត្រូវប្រញាប់នាំចិត្តឱ្យចូលទៅកាន់កន្លែងស្ងប់ស្ងាត់ មានគុណព្រះរតនត្រៃ ឬមានបុណ្យដែលខ្លួនបានបំពេញហើយ ជាអារម្មណ៍ព្រះកម្មដ្ឋាន រហូតបានឃើញថា សេចក្តីក្រោធគ្រាន់តែជារបស់គ្រោតគ្រាតខាងក្រៅ វិវក់ឥតប្រយោជន៍ វិវេកធម៌ទើបជាប្រយោជន៍ ស្ងប់ស្ងាត់ត្រជាក់ រួចហើយផ្សាយភាពត្រជាក់ កម្ចាត់បង់នូវអាការក្តៅចិត្តព្រោះក្រោធនោះ ចេញឱ្យអស់ទៅ ។

- សេចក្តីក្រោធវាមានអារម្មណ៍របស់វា ដូច្នេះការដូរអារម្មណ៍ជាវិធីមួយទៀតដ៏មានប្រសិទ្ធភាព ។

- សេចក្តីក្រោធកើតឡើង ព្រោះគិតខុសក្នុងអារម្មណ៍នោះជាពិតប្រាកដ ដូច្នេះការទទួលយកចំណេះដឹង

